ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា



# ស្វែងរក ការពិត

# ៣៥

- ឌុច នឹងមិនអាចមានសេរីភាពទេ
- ឌុច ដែលត្រូវកាត់ទោសឱ្យជាប់ពន្ធនាគាររយៈពេល ៣៥ឆ្នាំ

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា
លេខ១២៨ ខែសីហា ឆ្នាំ២០១០

# ស្វែងរកការពិត

ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ១២៨ ខែសីហា ឆ្នាំ២០១០


## មាតិកា


◆ឌុច នឹងមិនអាចមានសេរីភាពទេ ........................................១


### ធំព័រពិសេស


◆កាំង ហ្កេកអ៊ាវ ហៅ ឌុច ........................................៣

◆សាក្សីឡើងផ្តល់សក្ខីកម្មទាក់ទងនឹងជនជាប់ចោទ ........................................៨

◆អតីតអ្នកទោស និង សាច់ញាតិគោរពដល់អ្នកស្លាប់ ........................................៣៩

◆សាលក្រម ឌុច ........................................៤២

◆ឌុច ដែលត្រូវកាត់ទោសឲ្យជាប់ពន្ធនាគាររយៈពេល៣៥ឆ្នាំ........................................៤៦

◆ភាពច្របូកច្របល់ និងការមិនពេញចិត្ត បន្ទាប់ពីការប្រកាស ........................................៤៩

◆ប្រតិកម្មចំពោះសាលក្រម ឌុច ........................................៥៩




មេធាវីអន្តរជាតិ ហ្វ្រង់ស័រ រ៉ូហ្ស



មេធាវីជាតិ ការ សាវុត្ថ


## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ

ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន

លេខ០២៩១ពម/៩៩

ចុះថ្ងៃទី២ ខែសីហាឆ្នាំ១៩៩៩

រូបថតឯកសារៈមជ្ឈមណ្ឌលឯកសារកម្ពុជា

និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង



**ស្នេរលេខនេះ :** ចន ឆរឌីអារី, កែវ ដាស៊ីល, ម៉ៃឃើល សាលីបា និង ផៃលើ នីមស៍ **អ្នកនិពន្ធនិងស្រាវជ្រាវ :** គាត លក្ខិណា, សោម ប៊ុនថន, ស៊ិន សុធីតា **អ្នកបកប្រែៈ** ជា ផល្លា **និពន្ធនាយកទូទៅៈ** ឆាំង យុ **ជំនួយការនិពន្ធនាយកៈ** ទេព ម៉េងឃាន, ញាណ សុជាតិ **ក្រាហ្វិកកុំព្យូទ័រៈ** ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយៈ** ម៉ម សុផាត Email: dccam@online.com.kh, Homepage: www.dccam.org

*សំបុត្រ:*

# ឌុច នឹងមិនអាចមានសេរីភាពទេ: ឆាំង យុ

ក្រោយពីបានចំណាយពេលជិតពីរទសវត្សរ៍ដើម្បីចងក្រងឯកសារអំពីរបបខ្មែរក្រហម នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ ២០១០ លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា បានមើលការប្រកាសសាលក្រមជាប្រវត្តិសាស្ត្ររបស់អតីតប្រធានមន្ទីរស-២១របស់ខ្មែរក្រហមឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច តាមប្រព័ន្ធទូរទស្សន៍នៅក្នុងការិយាល័យរបស់លោកនាទីក្រុងភ្នំពេញ។ ឌុច ត្រូវបានផ្លាស់ប្តូរពីជនជាប់ចោទមកជាជាពិរុទ្ធជនវិញ ក្នុងការប្រព្រឹត្តបទល្មើសឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ ដោយតម្រូវឲ្យជាប់ទោស៣៥ឆ្នាំ រួមបញ្ចូលទាំងថិរវេលាដែលគាត់បានជាប់ឃុំខ្លួនមុនតុលាការខ្មែរក្រហមនេះត្រូវបានបង្កើតផង។

លោក ឆាំង យុ មានទស្សនៈចំពោះលទ្ធផលនៃសាលក្រមនេះថា «សាលក្រមនេះពិតជាមិនខុសទេ។ បើសិនជារយៈពេលដែល ឌុច ត្រូវបានឃុំខ្លួនមានចំនួនច្រើនជាងនេះបន្តិច នោះប្រហែលជាធ្វើឲ្យមានការពេញចិត្តច្រើនពីសំណាក់ជនរងគ្រោះភាគច្រើន។ ប៉ុន្តែគ្មានអ្វីមួយ ឬសាលក្រមណាមួយដែលអាចបំពេញចិត្តដែលបាក់បែករបស់ជនរងគ្រោះទាំងស្រុងនោះទេ»។ លោក ឆាំង យុ ក៏មានជំនឿផងដែរថា «ឌុច នឹងមិនអាចមានសេរីភាពទេ ហើយ ឌុច នឹងស្លាប់នៅក្នុងគុក»។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានជួយដល់តុលាការខ្មែរក្រហមតាំងពីឆ្នាំ២០០៦មក។ មជ្ឈមណ្ឌលឯកសារកម្ពុជាមិនត្រឹមតែផ្តល់សេវាកម្មបកប្រែ ចម្លងឯកសារ និងការដឹកជញ្ជូនទៅកាន់តុលាការទេ ប៉ុន្តែថែមទាំងអនុញ្ញាតឲ្យអង្គភាពជាច្រើនដែលរួមមានជាពិសេស ព្រះរាជអាជ្ញា អង្គភាពការពារក្តី និងអង្គភាពសហចៅក្រមស៊ើបសង្កេតឲ្យប្រើប្រាស់ឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាសម្រាប់ការផារស្រាវជ្រាវ។ ចៅក្រមនិងមេធាវីជាច្រើនបានប្រើប្រាស់សេវាកម្មរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដោយពេញចិត្ត លើកលែងតែលោក ការ សាវុត្ថ មេធាវីការពារក្តីកម្ពុជារបស់ ឌុច។ ជារឿងគួរឲ្យចម្លែកណាស់ដែលលោក ការ សាវុត្ថ បាននិយាយថា លោកមិនអាចប្រើប្រាស់សម្ភារ ឬ ធនធានរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ ប៉ុន្តែការិយាល័យសហចៅក្រមស៊ើបអង្កេតនិងការិយាល័យសហព្រះរាជអាជ្ញា ព្រមទាំងមេធាវីការពារក្តី នួន ជា, អៀង សារី និង អៀង ធីរិទ្ធ មិនមានបញ្ហាក្នុងការប្រើប្រាស់ជំនួយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាទេ។



លោក ឆាំង យុ នៅក្នុងបន្ទប់ពិសោធន៍សារមន្ទីរទួលស្លែង ឆ្នាំ២០០៦

**កែវ ជាស៊ីល និង ញាណ សុជាតិ**


អ្នកភូមិតម្រង់ជួរចូលស្តាប់ការប្រកាសសាលក្រម ឌុច


អ្នកភូមិពិភាក្សាគ្នាក្រោយពីស្តាប់សាលក្រម ឌុច


ឌុច នៅក្នុងបន្ទប់សវនាការ


ទិដ្ឋភាពនៅក្នុងបន្ទប់សវនាការ នៅថ្ងៃប្រកាសសាលក្រម ឌុច

# កាំង ហ្កេកអ៊ាវ ហៅ ឌុច

*(ដកស្រង់ចេញពីឯកសាររបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានិងសៀវភៅ «សំឡេងពីមន្ទីរស-២១» របស់អ្នកនិពន្ធ ដេវីដ ឆេនដល័រ)*

កាំង ហ្កេកអ៊ាវ ហៅ ឌុច កើតនៅថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ ១៩៤២ នៅភូមិពៅវ៉ើយ ឃុំពាមបាង ស្រុកស្ទោង ខេត្តកំពង់ធំ ។ ឪពុករបស់គាត់ស្លាប់នៅក្នុងឆ្នាំ១៩៩០ ហើយម្តាយរបស់គាត់នៅរស់រហូតដល់សព្វថ្ងៃ ។ អ្នកទាំងពីរមានកំណើតឈាមជ័រកាត់ចិន ។ ឈ្មោះនៅក្នុងបញ្ជីអត្រានុកូលដ្ឋានរបស់ ឌុច គឺ កាំង ជាវ ។ ក្រោយមក ឪពុករបស់គាត់បានប្តូរទៅជា យឹម គាវ វិញព្រោះហោរាទាយថាឈ្មោះនេះមិនមានសំណាងល្អទេ ។ ឈ្មោះ កាំង ជាវ មានន័យថា «ស្ពឹក ចាស់គំរិល» ។ ឌុច នៅតែមិនពេញចិត្តនឹងឈ្មោះថ្មីនេះដដែល ។ ហេតុដូច្នេះ ពេលដែលគាត់មានអាយុ១៥ ឆ្នាំ គាត់បានស្នើសុំឪពុករបស់គាត់ឲ្យប្តូរឈ្មោះថ្មីមួយទៀតទៅជា កាំង ហ្កេកអ៊ាវ វិញ ។ ឆ្លៀតឱកាសនោះដែរ ឌុច បានកែប្រែថ្ងៃខែឆ្នាំកំណើតរបស់គាត់ដោយបន្ថយអាយុបីឆ្នាំផងដែរ ព្រោះអាយុពិតរបស់គាត់ច្រើនពេកមិនអាចចុះឈ្មោះចូលរៀនបាន ។ ដូច្នេះ អត្តសញ្ញាណថ្មីរបស់គាត់គឺ កាំង ហ្កេកអ៊ាវ កើតនៅថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ១៩៤៥ ។ ទូទាំងរបបកម្ពុជាប្រជាធិបតេយ្យ កាំង ហ្កេកអ៊ាវ ត្រូវបានស្គាល់ជាទូទៅថា ឌុច ។ ឈ្មោះនេះត្រូវបានប្រើប្រាស់រហូតដល់ពាក់កណ្តាលទសវត្សរ៍៨០ នៅពេលដែលឈ្មោះរបស់គាត់ត្រូវប្តូរទៅជា ហង់ ពិន វិញ ។



ឌុច នៅមន្ទីរស-២១ ឬ គុកទួលស្លែង

ឌុច ជាកូនច្បង និងជាកូនប្រុសទោលក្នុងចំណោមបងប្អូនប្រាំនាក់ ។ គាត់មានទំនាក់ទំនងល្អជាមួយនឹងឪពុកម្តាយនិងជាមួយបងប្អូនរបស់គាត់ ។ ឌុច ជាមនុស្សខ្សោះខ្សាយឈឺណាស់កាលគាត់នៅតូច ។ វាជាជំងឺដែលគាត់ហៅថា ជំងឺបក្កទ្បើងដោយភាពក្រីក្រ និងជំងឺនៅជនបទ ។ គាត់ចូលរៀនយឺតពេលទៅហើយក្រោមអាយុកំណត់ គឺនៅអាយុ៩ឆ្នាំ ដោយសារគាត់ជាសិស្សល្អពោរពេញទៅដោយការកោតក្រែង និងការគោរពស្រឡាញ់ដ៏ជ្រាលជ្រៅចំពោះលោកគ្រូ-អ្នកគ្រូទាំងអស់ ។ គាត់បានបញ្ចប់ការសិក្សារបស់គាត់ជាបន្តបន្ទាប់នៅខេត្តកំពង់ធំ កំពង់ចាម និងបន្ទាប់មកនៅវិទ្យាល័យព្រះស៊ីសុវត្ថិក្រុងភ្នំពេញ ដែលជាកន្លែងគាត់ទទួលសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិក្នុងឆ្នាំ១៩៥៦ កាលនោះ ឌុច ជាប់ចំណាត់ថ្នាក់លេខពីរខាងផ្នែកគណិតវិទ្យា ។

យោងតាមសៀវភៅ «សំឡេងពីមន្ទីរស-២១» របស់សាស្ត្រាចារ្យ ដេវីដ ឆេនដល័រ បានឲ្យដឹងថា ម្តាយរបស់ កាំង ហ្កេកអ៊ាវ ដែលត្រូវបានសម្ភាសកាលពីឆ្នាំ១៩៨០ បានឲ្យដឹងថាខួរក្បាលរបស់កូនប្រុសគាត់គឺ «ជាប់នឹងសៀវភៅជានិច្ច» ។ ក្រោយមក ឌុច បានទៅរៀននៅវិទ្យាល័យព្រះស៊ីសុវត្ថិក្រោមការជួយជ្រោមជ្រែងពីអ្នកមានឥទ្ធិពលម្នាក់ ។ មិត្តរួមថ្នាក់របស់ កាំង

ហុកអ៊ាវ ម្នាក់បានរំឭកឡើងវិញថាក្នុងសម័យនោះ កាំង ហុកអ៊ាវ គឺជាយុវជនវ័យក្មេងដែលប្រកាន់ខ្ជាប់នូវភាពឧស្សាហ៍ព្យាយាមដោយពុំមានអារម្មណ៍ទៅលើការកម្សាន្តអ្វីផ្សេងឬលើបញ្ហានយោបាយទាល់តែសោះ ។

ពីរបីឆ្នាំបន្ទាប់មកទៀត កាំង ហុកអ៊ាវ បានចាប់យកអាជីពជាគ្រូបង្រៀនមុខវិជ្ជាគណិតវិទ្យានៅវិទ្យាល័យកំពង់ធំ ។ សិស្សម្នាក់ក្នុងចំណោមអតីតសិស្សរបស់ កាំង ហុកអ៊ាវ ទាំងអស់ក្រោយមកបានរំឭកថា «កាំង ហុកអ៊ាវ ត្រូវបានគេទទួលស្គាល់ចំពោះភាពច្បាស់លាស់នៅក្នុងការបង្រៀន ហាក់បីដូចជាគាត់ផ្ដិតចម្លងនូវអត្ថបទទាំងមូលចេញពីខួរក្បាលរបស់គាត់ដាក់នៅលើក្ដារខៀនអ៊ីចឹង» ។ សហការីម្នាក់ដែលរួមអាជីពជាគ្រូបង្រៀនផ្នែកជីវវិទ្យានៅវិទ្យាល័យនោះដែរ គឺជាមនុស្សម្នាក់ដែលមានរូបរាងខ្ពស់ស្រឡះជាងគេឈ្មោះ ម៉ម ណៃ (ហៅ ចាន់) ។ ក្នុងអំឡុងពេលប៉ុន្មានឆ្នាំក្រោយមក នៅពេលដែលបុរសទាំងពីរនេះបានក្លាយជាសមាជិកនៃបក្សកុម្មុយនីស្តកម្ពុជា កាំង ហុកអ៊ាវ បានហៅ ម៉ម ណៃ មកធ្វើជាប្រធានអង្គភាពសួរចម្លើយនៅមន្ទីរស-២១ ។ កាំង ហុកអ៊ាវ និង ម៉ម ណៃ ត្រូវបានដឹងតាមរយៈឯកសារដែលបានបន្សល់ទុកថាជាគ្រូបង្រៀនដែលមាន


ឌុច និង បុគ្គលិក នៅមន្ទីរស-២១

លក្ខណៈសម្បត្តិឈ្លាសវៃ ម៉ឺងម៉ាត់និងបានលះបង់ទាំងស្រុងទៅលើការងារ ។ លក្ខណៈទាំងនេះហើយដែលអ្នកទាំងពីរបានពាំនាំជាមួយនឹងខ្លួនទៅបម្រើគោលដៅផ្សេងនៅពេលដែលអ្នកទាំងពីរមកធ្វើការជាមួយគ្នានៅមន្ទីរស-២១ ។

ក្នុងឆ្នាំ១៩៦៤ កាំង ហុកអ៊ាវ បានទទួលតំណែងនៅវិទ្យាស្ថានគរុកោសល្យបន្ទាប់ពី សុន សេន ចាកចេញទៅ ។ យោងតាមសម្ដីរបស់លោក នេត ប៊ុនអន ដែលជាមិត្តរួមថ្នាក់របស់ កាំង ហុកអ៊ាវ នៅឯវិទ្យាល័យព្រះស៊ីសុវត្ថិ យុវជនវ័យក្មេងដែលពូកែខាងគណិតវិទ្យារូបនេះត្រូវបានអូសទាញឆ្ពោះទៅរកលទ្ធិកុម្មុយនីស្តដោយនិស្សិតចិនមួយក្រុមដែលបានចូលមកសិក្សាអក្សរសាស្ត្រខ្មែរនៅឯសាកលវិទ្យាល័យភ្នំពេញ ។ នៅឯសាកលវិទ្យាល័យ កាំង ហុកអ៊ាវ មានការចាប់អារម្មណ៍ និងទទួលការអប់រំនយោបាយពីបុរសស្ត្រីវ័យក្មេងៗដែលសម្បូរទៅដោយទស្សនៈនិងការយកចិត្តទុកដាក់ដ៏ស្រួចស្រាល់ទៅលើលទ្ធិកុម្មុយនីស្ត ។ កាំង ហុកអ៊ាវ មើលឃើញថា បុរសស្ត្រីវ័យក្មេងទាំងនោះនឹងដើរតួនាទីដ៏សំខាន់ក្នុងទំនាក់ទំនងកម្ពុជា-ចិន នៅអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ និងបន្ទាប់ពីរបបនេះទៅទៀត ។

ឆ្នាំ១៩៦៥ ឌុច ត្រូវបានតែងតាំងជាគ្រូបង្រៀនផ្នែកគណិតវិទ្យានៅអនុវិទ្យាល័យស្គន់បន្ទាប់ពីគាត់ចេញពីវិទ្យាស្ថានគរុកោសល្យ ។ កូនសិស្សរបស់គាត់ពិពណ៌នាអំពីគាត់ថាជាមនុស្សស្មោះត្រង់ គស្លូត និងជានិច្ចជាកាលតែងតែជួយដល់សិស្សទីទ័លក្រ ។ គាត់ណែនាំយ៉ាងហោចណាស់សិស្សម្នាក់ក្នុងចំណោមសិស្សរបស់គាត់ឈ្មោះ គី សុខហ៊ី ឲ្យចូលបដិវត្តន៍ ហើយក្រោយមក គាត់ក៏ត្រូវចាប់ខ្លួនដោយកងកម្លាំងប៉ូលិសរបស់សម្ដេច សីហនុ ដោយចោទប្រកាន់ថាជាជនកុម្មុយនីស្ត ។ កាំង ហុកអ៊ាវ បានជាប់ឃុំដោយពុំមានការជំនុំជម្រះទោសអស់រយៈពេលជាច្រើនខែ ដែលជាទីតិវិធីធម្មតាមួយសម្រាប់អ្នកទោសនយោបាយក្នុងជំនាន់នោះ ។ ក៏ប៉ុន្តែគាត់បានរិះរកមធ្យោបាយដោយជោគជ័យក្នុងការដោះខ្លួនចេញពីគុកតាមរយៈការធ្វើអន្តរាគមន៍ពីអ្នកអាណាព្យាបាលរបស់គាត់កាលពីកុមារភាព ។ មិនយូរប៉ុន្មាន បន្ទាប់ពីសម្ដេច សីហនុ ត្រូវផ្ដួលរំលំពីអំណាច កាំង ហុកអ៊ាវ ហៅ ឌុច បានរត់ចូលព្រៃម៉ាគី ។

តាំងតែពីអាយុ១៥ឆ្នាំមក គាត់ចាប់ផ្តើមមានចំណាប់អារម្មណ៍ចំពោះការតស៊ូផ្នែកនយោបាយ ដោយសារគាត់មានការអាក់អន់ចិត្តចំពោះការប្រមាថលើស្ថានភាពក្រីក្ររបស់គ្រួសារគាត់ ។ ជាពិសេសដោយសារការប្រឈមមុខនឹងការទារសំណងឥតស្រាកស្រាន្តពីសំណាក់ពួករបស់គាត់ដែលជាអ្នករកស៊ីចងការប្រាក់ក្នុងអត្រាមួយខ្ពស់ ។ ដូចគ្នានេះដែរ គាត់អាចនឹងទទួលឥទ្ធិពលនយោបាយពីសំណាក់គ្រូៗជាច្រើនរបស់គាត់ដែលបានបរិហារពីអំពើពុករលួយ និងភាពអយុត្តិធម៌នៅក្នុងសង្គម ហើយជាពិសេសតាមរយៈគ្រូបង្រៀនរបស់គាត់ម្នាក់ឈ្មោះ កែ គឹមហួត ដែលក្រោយមកគាត់ត្រូវបានសម្លាប់នៅមន្ទីស-២១ ។

នៅដើមទសវត្សរ៍៧០ កាំង ហ្កេកអ៊ាវ បានទទួលខុសត្រូវផ្នែកសន្តិសុខនៅតំបន់៣៣ ភាគខាងជើងទីក្រុងភ្នំពេញ ។ លោក ហ្វ្រង់ស័រ ប៊ីហ្សូ ដែលជាអ្នកជំនាញផ្នែកជាតិពន្ធត្រូវបានចាប់ខ្លួនដោយពួកទ័ពព្រៃកុម្មុយនីស្តនៅក្នុងតំបន់៣៣នេះក្នុងអំឡុងឆ្នាំ១៩៧០ ។ ឌុច ធ្លាប់បានសួរចម្លើយលោក ហ្វ្រង់ស័រ ម្តងហើយម្តងទៀតសាចុះសាឡើងអស់រយៈពីរខែ ដោយចោទប្រកាន់លោក ហ្វ្រង់ស័រ ថាជាភ្នាក់ងារ សេ.អ៊ី.អា ហើយបានបង្ខំឲ្យគាត់សរសេរជីវប្រវត្តិលម្អិតជាច្រើនលើកមុនពេលដោះលែង ។ លោក ហ្វ្រង់ស័រ បានរួចចេញមកវិញដោយមានការតក់ស្លុតចំពោះភាពងប់ងុលរបស់ ឌុច ។ នៅក្នុងទស្សនៈរបស់លោក ហ្វ្រង់ស័រ «ឌុច ជឿថា ជនទាំងឡាយដែលមានទស្សនៈផ្សេងគឺជាជនក្បត់ និងជាកូនភូតភរ» ។

នៅក្នុងឆ្នាំ១៩៧៣ ឌុច បានផ្លាស់មកតំបន់២៤ ភាគខាងជើងទីក្រុងភ្នំពេញវិញ ។ ថ្នាក់លើរបស់ ឌុច ឈ្មោះ សុក ធួក (ហៅ វន វេត) គឺជាជនកុម្មុយនីស្តចាប់តាំងពីទសវត្សរ៍៥០មកម្ល៉េះ ។ សុក ធួក ត្រូវបានប្រហារជីវិតនៅមន្ទីរស-២១ ក្នុងឆ្នាំ១៩៧៨ ។ នៅក្នុងឆ្នាំ ១៩៧៣ សុន សេន ជាអនុរបស់ សុក ធួក ទទួលបន្ទុកកិច្ចការយោធា ។ បន្ទាប់ពីការប្រហារជីវិត សុក ធួក, ឌុច ប្រហែលជាបានទទួលការចាប់អារម្មណ៍ចូលចិត្តយ៉ាងខ្លាំងពីសំណាក់ សុន សេន ។ ក្នុងរយៈកាលបំពេញការងារកន្លងមក ឌុច បានទទួលបទពិសោធន៍ខាងបញ្ហាសន្តិសុខបានយ៉ាងច្រើន ។ ភ័ស្តុតាងបង្ហាញថា ឌុច មិនធ្លាប់ធ្វើដំណើរទៅបរទេសឬទទួលការបណ្តុះបណ្តាលណាមួយពីអ្នកជំនាញបរទេសទេ ។ នៅចន្លោះឆ្នាំ១៩៧២និងឆ្នាំ១៩៧៣ ឌុច ប្រហែលជាជួយបង្កើតនូវសញ្ញាណនៃ «ខ្សែក្បត់» ។ នៅចន្លោះពេលនោះ កិច្ចប្រតិបត្តិការសម្ងាត់មួយត្រូវបានបង្កើតឡើងដោយខ្មែរក្រហមដើម្បីធ្វើវិសុទ្ធកម្មក្រុមដែលហៅថា ខ្មែរហាណូយ (ជនជាតិខ្មែរដែលបានចូលរួមហ្វឹកហ្វឺននយោបាយ និងកងទ័ពនៅវៀតណាមខាងជើង) ។ សមាជិកខ្មែរក្រុមនេះរាប់រយនាក់ ត្រូវបានចាប់ខ្លួនជាសម្ងាត់និងយកទៅសម្លាប់ចោលនៅក្នុងឆ្នាំ១៩៧៣ បន្ទាប់ពីវៀតណាមដកទ័ពរបស់ខ្លួនទាំងស្រុងចេញពីកម្ពុជា ។ សមាជិកនៅសេសសល់ពីរបីនាក់បានសម្រេចជោគជ័យក្នុងការគេចខ្លួនទៅប្រទេសវៀតណាមបន្ទាប់ពីការជាប់ឃុំឃាំង ហើយសមាជិកភាគច្រើននៃក្រុមនេះត្រូវបានចាប់ខ្លួននៅក្នុងភូមិភាគពិសេស ។ ភាពដាច់ខាត និងភាពគ្មានមេត្តានៃយុទ្ធនាការធ្វើវិសុទ្ធកម្មនេះមានការទាក់ទងគ្នាជាមួយនឹងរបៀបគ្រប់គ្រងរដ្ឋបាលរបស់ ឌុច ដែរ ។ តាមពិត យុទ្ធនាការនេះបង្ហាញអំពីដំណើរដូចគ្នាដែលប្រព្រឹត្តទៅនៅមន្ទីរស-២១ ។

ជីវិតគ្រួសារនិងជីវិតស្នេហារបស់ ឌុច ប្រព្រឹត្តទៅប្រកបដោយស្ថិរភាពធម្មតា លើកលែងតែការខកចិត្តស្នេហាកាលនៅយុវវ័យដែលគាត់បានចាត់ទុកជារឿងសំខាន់សម្រាប់គាត់ ។ ឌុច បាននិទានអំពីនារីម្នាក់តែប៉ុណ្ណោះនៅក្នុងជីវិតរបស់គាត់ គឺប្រពន្ធរបស់គាត់ឈ្មោះ ឈឹម សុផល ហៅ រុំ ដែលជាជាងកាត់ដេរសម្លៀកបំពាក់ ។ គាត់បានពន្យល់ថា ដោយសារតែមានការអនុញ្ញាតពី សុន សេន ទើបគាត់អាចជ្រើសរើសយកប្រពន្ធរបស់គាត់ ដែលគាត់បានស្គាល់នៅក្នុងឆ្នាំ១៩៧៤ ។

ឌុច បានរៀបការជាមួយនាងនៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៧៥ គឺនៅពេលដែលគាត់ជាប្រធានមន្ទីស-២១ ។ គាត់មានកូនចំនួន ៤នាក់ កូនស្រីទីមួយកើតនៅថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៧៧ ។ កូនប្រុសទីពីរ កើតនៅថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ១៩៧៨ ។ កូនស្រីទីបី កើតនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៨១ និងកូនប្រុសទីបួន កើតនៅថ្ងៃទី ២៨ ខែតុលា ឆ្នាំ១៩៨៥ ។

កិច្ចការសន្តិបាលត្រូវបានផ្ទេរនិងផ្លាស់មករដ្ឋធានីភ្លាមៗ បន្ទាប់ពីខ្មែរក្រហមទទួលជ័យជម្នះនៅខែមេសា ឆ្នាំ១៩៧៥

ប៉ុន្តែអស់រយៈពេលជាច្រើនខែក្រោយមក អង្គភាពនេះបានស្ថិតនៅក្រោមឈ្មោះមន្ទីរ១៥ ។ ចំណារ ឌុច ទំនងជាមាននៅលើឯកសារជាច្រើនដែលមានប្រភពចេញមកពីមន្ទីរនេះ ។ ឯកសារដំបូងបំផុតដែលភ្ជាប់ទៅនឹងមន្ទីរស-២១ មានកាលបរិច្ឆេទតាំងពីខែតុលា ឆ្នាំ១៩៧៥រហូតមក ។ នៅក្នុងរយៈពេល៦ខែបន្ទាប់មកទៀត ឌុច បានបែកវែកពេលវេលារបស់ខ្លួនដើម្បីធ្វើការគ្រប់គ្រងមន្ទីរសន្តិបាលនៅតាខ្មៅខាងត្បូងភ្នំពេញនិងមណ្ឌលសួរចម្លើយជាច្រើនទៀតដែលនៅរាយពាសពេញទូទាំងទីក្រុងភ្នំពេញ ។ មន្ទីរសន្តិបាលនៅតាខ្មៅហៅថាស-២១«ខ» មានទីតាំងនៅក្នុងបរិវេណមន្ទីរពេទ្យវិកលចរិត (ពេទ្យឆ្កួត) តែមួយគត់របស់ប្រទេសកម្ពុជា ។

ជាអ្នកគ្រប់គ្រងមន្ទីរស-២១ ឌុច បានខំប្រឹងប្រែងធ្វើការយ៉ាងសកម្មដើម្បីគ្រប់គ្រងរាល់កិច្ចការទាំងអស់របស់មន្ទីរនេះ ។ បទពិសោធន៍និងសភាវគតិឈ្លាសវៃដែលបានបណ្តុះតាមរយៈការបង្រៀន បានជួយសម្រួលកិច្ចការរបស់ ឌុច យ៉ាងខ្លាំង ។ ឌុច ធ្លាប់ធ្វើកិច្ចការចុះបញ្ជីកត់ត្រាផ្សេងៗ ដាក់ចេញនូវចម្លើយដោះបញ្ហាទាំងឡាយទទួលការគោរពនិងដាក់វិន័យអប់រំមនុស្សជាច្រើនក្រុម ។ ឌុច បានកំណត់ខ្លួនឯងនិងអ្នកនៅក្រោមបង្គាប់ឲ្យប្រឹងប្រែងធ្វើការយ៉ាងខ្លាំង ។ ហ៊ឹម ហ៊ុយ ដែលជាអតីតអ្នកយាមនៅមន្ទីរស-២១ បានរំឭកឡើងវិញថា «ឌុច ជាមនុស្សខ្លាំង ច្បាស់លាស់ និយាយអីធ្វើហ្នឹង ។ ជារឿយៗ ឌុច ធ្វើឲ្យបុគ្គលិកនៅក្នុងមន្ទីរស-២១ភ័យខ្លាចញ័រខ្លួន» ។ នៅពេលដែលសួរថា ឌុច ជាមនុស្សមានចរិតយ៉ាងដូចម្តេច កងការពារម្នាក់បានឆ្លើយថា «មនុស្សយ៉ាងម៉េច អ្ហ៊ែះ? ឌុច គឺជ្រុលហួសហេតុតែម្តង» នៅក្នុងគំនិតរបស់កងការពាររូបនេះយល់ថា ភាពសាហាវឃោរឃៅបំផុតនៃឧក្រិដ្ឋកម្មរបស់ ឌុច គឺមិនមែនដោយសារ ឌុច ជាអ្នកនៅពីលើបញ្ជាឲ្យយកអ្នកទោសចំនួនប្រមាណដប់បួនពាន់នាក់ទៅសម្លាប់នោះទេ ប៉ុន្តែភាពភាពឃោឃៅបំផុតគឺពេលដែល ឌុច អនុញ្ញាតឲ្យអ្នកនៅក្រោមបង្គាប់យកប្អូនថ្លៃរបស់គាត់ពីរនាក់ទៅដាក់នៅមន្ទីរស-២១ និងយកទៅសម្លាប់ចោល ។ អតីតកងការពារនេះបានរំឭកឡើងវិញថា «ឌុច មិនដែលសម្លាប់អ្នកណាដោយផ្ទាល់ទេ» ប៉ុន្តែជួនពេលខ្លះ ឌុច បើកឡានទៅវាលពិឃាតនៅជើងឯកដើម្បីពិនិត្យមើលការប្រហារជីវិតនៅទីនោះដោយផ្ទាល់ខ្លួនឯងតែម្តង ។

សំណួរនិងចំណារជាច្រើនដែលសរសេរយ៉ាងស្អាតដោយ ឌុច ដោយប៊ិចពណ៌ក្រហមត្រូវបានឃើញនៅលើចម្លើយសារភាពជារឿយៗ ។ ជាញឹកញយ ចំណារនិងការចោទសំណួរដែល ឌុច ធ្វើឡើងច្រើនតែកែតម្រូវឬបញ្ជាក់ការសង្ស័យទៅលើអ្វីដែលអ្នកទោសបានសារភាពជូនយោបល់ឲ្យវាយដំធ្វើទារុណកម្មនិងជំរុញឲ្យអ្នកសួរចម្លើយជីកឫសជីកគល់រក «ការពិត» ដែលអ្នកទោសបានលាក់ ។ មិនតែប៉ុណ្ណោះ ឌុច បានធ្វើសេចក្តីសង្ខេបលើឯកសារចម្លើយសារភាពមួយចំនួនដោយបានចង្អុលបង្ហាញពីខ្សែបណ្តាញដែល ឌុច ក្តាប់ពីចម្លើយសារភាពមុនៗ ហើយជូនយោបល់ឲ្យធ្វើការតាមដានខ្សែបណ្តាញនោះ ។ សេចក្តីរៀបរាប់សង្ខេបដែលត្រូវបានសរសេរឡើងនៅក្នុងឆ្នាំ១៩៧៨ មានចំណងជើងថា «ផែនការចុងក្រោយ» មានបំណងចងក្រងនូវចម្លើយសារភាពក្នុងរយៈពេលកាលប្រាំឆ្នាំកន្លងមកដើម្បីបង្ហាញអំពីការសមគំនិតក្នុងទ្រង់ទ្រាយធំនិងយូរអង្វែងដែលពាក់ព័ន្ធទៅនឹងសហរដ្ឋអាមេរិក សហភាពសូវៀត តៃវ៉ាន់ និងវៀតណាម ។ ដូចជាក្នុងករណីលោក ដេម ដេស៊ីស អាន់គ្លេថុន នៃក្រុម សេ.អ៊ី.អា ជាដើម ឌុច បានព្យាយាមតាំងខ្លួនប្រើប្រាស់គំនិតនេះក្នុងការស្រាវជ្រាវរកជនបង្កប់ក្នុងអង្គការ ។ ជាអ្នកគណិតវិទ្យា ឌុច ចូលចិត្តយកមកធ្វើនូវអ្វីដែលខ្លួនគិតថាសមហេតុសមផល ។ «ផែនការចុងក្រោយ» គឺជាសៀវភៅគំរូមួយរបស់ ឌុច ។

ឌុច រស់នៅក្បែរមន្ទីរស-២១ជាមួយប្រពន្ធនិងកូនតូចៗពីរនាក់ ។ ឌុច ស្ថិតនៅមន្ទីរស-២១ រហូតដល់ល្ងាចថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ នៅពេលដែល ឌុច ដើរចេញពីក្រុងភ្នំពេញ ហើយក៏បាត់ស្រមោល ។

បន្ទាប់ពីមានការដួលរលំនៅក្នុងឆ្នាំ១៩៧៩ ឌុច បន្តរស់នៅនិងធ្វើការជាមួយខ្មែរក្រហមអស់រយៈពេលជាងដប់ឆ្នាំទៀត ។ គាត់បានបង្ហាញថា គាត់ធ្លាប់មានបំណងចាកចេញពីចលនានេះដែរ ប៉ុន្តែគាត់ស្ថិតនៅក្នុងស្ថានភាពមួយដែលមិនអាចធ្វើទៅបានឡើយ ។ ដោយសារតែតាំងពីពេលមកដល់សំឡុតនៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៧៩ គាត់ហាក់ដូចជាត្រូវបានគេចាត់ទុកជាអ្នក

ទោសនៃរបបអ៊ីចឹង នៅទីនោះគាត់មានមុខងារសំខាន់ជាគ្រូបង្រៀន ។

នៅខែតុលា ឆ្នាំ១៩៨៦ ប្រធានរបស់គាត់ឈ្មោះ សុន សេន ប្រធានមន្ទីរក១៨ ជាកន្លែងដែល ឌុច ធ្វើការ បានបញ្ជូនគាត់ឲ្យទៅប្រទេសចិនដើម្បីបង្រៀនភាសាខ្មែរដល់និស្សិតចិន ។ គាត់រស់នៅនិងធ្វើការក្រោម បញ្ជារបស់ប្រពន្ធ សុន សេន ឈ្មោះ យុន យ៉ាត នៅក្នុងប្រទេសនោះរយៈពេលជាងពីរឆ្នាំ ។

នៅក្នុងឆ្នាំ១៩៩២ នៅពេលដែល ប៉ុល ពត ចាត់តាំងឲ្យគាត់ទទួលបន្ទុកផ្នែកសេដ្ឋកិច្ចនៅភូមិផ្កាំ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ឌុច ចាប់ផ្តើមបាត់បង់ទំនាក់ទំនងជាមួយថ្នាក់លើរបស់គាត់ ។ គាត់បានពន្យល់ថា ការបែកបាក់គ្នាចេះតែរីកធំឡើងៗ ទាហានខ្មែរក្រហមចាប់ផ្តើមបែកខ្ញែកគ្នាបន្តិចម្តងៗក្នុងខណៈពេលដែលសង្គ្រាមចេះតែបន្ត ។ គាត់បានប្រកបការងារជាគ្រូបង្រៀន រួមផ្សំជាមួយនឹងការរកស៊ីលក់អង្ករនិងចិញ្ចឹមជ្រូក ។ នៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៩៥ នៅភូមិផ្កាំ គាត់ទទួលរងគ្រោះពីអំពើប្លន់ក្នុងផ្ទះដ៏អាថ៌កំបាំងមួយដែលក្នុងពេលនោះប្រពន្ធរបស់គាត់ត្រូវបានចោរចាក់មួយកាំបិតចំដើមទ្រូងបណ្តាលឲ្យស្លាប់ តែគាត់វិញគ្រាន់តែមានរបួសបន្តិចបន្តួចប៉ុណ្ណោះ ។

ចំពោះព្រឹត្តិការណ៍នេះ ឌុច គិតថា វាជាការប៉ុនប៉ងធ្វើឃាតកម្មគិតទុកជាមុនដែលរៀបចំឡើងដោយ ប៉ុល ពត ។ បន្ទាប់ពីការស្លាប់របស់ប្រពន្ធគាត់ ឌុច បានចាប់ផ្តើមចូលរួមក្នុងការជួបជុំរបស់ព្រះវិហារផ្សព្វផ្សាយសាសនាគ្រិស្តនៅខេត្តបាត់ដំបង ។ គាត់ប្តូរមកកាន់សាសនាគ្រិស្តនៅក្នុងឆ្នាំ១៩៩៦ ហើយគាត់ក៏បាននាំកូនប្រុសស្រីរបស់គាត់ចូលសាសនានេះផងដែរ ។

ក្នុងឆ្នាំ១៩៩៦ ឌុច លែងនៅក្នុងចលនាខ្មែរក្រហមទៀតហើយ ។ ឌុច បានជួបជាមួយនឹងក្រុមផ្សព្វផ្សាយសាសនាគ្រិស្តជនជាតិអាមេរិកនៅភាគពាយព្យប្រទេសកម្ពុជា ហើយក៏ក្លាយខ្លួនជាអ្នកប្រតិបត្តិសាសនាគ្រិស្តម្នាក់ ។ ឌុច ធ្វើការជាអ្នករៀបចំសណ្តាប់ធ្នាប់នៅមន្ទីរពេទ្យមួយកាលពីខែមេសា ឆ្នាំ១៩៩៩ នៅពេលដែលអ្នកកាសែតម្នាក់បានរកឃើញអត្តសញ្ញាណពីអតីតកាលរបស់គាត់ ។ ក្រោយមក ឌុច ត្រូវបានសម្ភាសដោយអ្នកកាសែតអាមេរិកាំង ណេត ថាយ័រ ហើយបាននិយាយជាចំហអំពីអតីតកាលរបស់គាត់ ។

ក្រោយមក គាត់បានត្រឡប់ទៅសំឡូតវិញ ។ ដោយសារមានការចាប់ផ្តើមជាថ្មីក្នុងការប្រយុទ្ធគ្នារវាងខ្មែរក្រហមជាមួយនឹងកម្លាំងខាងរដ្ឋាភិបាល គេបានជម្លៀសប្រជាជនចេញពីក្នុងឃុំនោះ ហើយគាត់ក៏បានឆ្លងទៅរស់នៅក្នុងប្រទេសថៃជាមួយនឹងប្រជាជនទាំងអស់នោះដែរ ។

នៅខែកក្កដា ឆ្នាំ១៩៩៧ គាត់បានចាប់ផ្តើមធ្វើការឲ្យសមាគមមួយ ដែលមានឈ្មោះថា គណៈកម្មាធិការអាមេរិកទទួលបន្ទុកជនភៀសខ្លួន និងបានបន្តការងារនេះរហូតដល់ក្រុមអ្នកសារព័ត៌មានស្គាល់អត្តសញ្ញាណរបស់គាត់ ដែលនាំឲ្យមានការចាប់ខ្លួនគាត់ ប៉ុន្មានថ្ងៃក្រោយមកគឺនៅខែឧសភា ឆ្នាំ១៩៩៩ ។


ឌុច ផ្តល់សម្ភាសឲ្យអ្នកយកព័ត៌មានមុនពេលចាប់ខ្លួន

**ញាណ សុជាតិ**

# សាក្សីឡើងផ្តល់សក្ខីកម្មទាក់ទងនឹងជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច អតីតប្រធានមន្ទីរស-២១ ឬ គុកទួលស្លែង

អស់រយៈពេលជិតប្រាំបីខែនៃការកាត់ក្តីករណី០០១នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលមានជនជាប់ចោទឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច ជាអតីតប្រធានមន្ទីរស-២១ កាលពីរបបកម្ពុជាប្រជាធិបតេយ្យ មានប្រជាជនប្រមាណជា២៨ម៉ឺននាក់បានចូលទស្សនាអង្គសវនាការនេះដោយផ្ទាល់នៅក្នុងបន្ទប់សវនាការ។ ការជំនុំជម្រះ ឌុច បានចាប់ផ្តើមដំបូងនៅថ្ងៃទី៣០ ខែមីនា ហើយសេចក្តីសន្និដ្ឋានបញ្ចប់ការដេញដោលគឺប្រព្រឹត្តទៅនៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៩។ ក្នុងរយៈពេលនោះ អង្គសវនាការជម្រះក្តី ឌុច មានចំនួន៧៧លើក។ សាក្សីចំនួន២៤រូប ដើមបណ្តឹងរដ្ឋប្បវេណីចំនួន២២នាក់និងសាក្សីជំនាញចំនួន៩នាក់ ដែលសរុបទាំងអស់មានចំនួន៥៥នាក់បានចូលមកធ្វើសក្ខីកម្មក្នុងរយៈពេលនៃការជំនុំជម្រះក្តី ឌុច។ ខាងក្រោមនេះគឺជាសេចក្តីសង្ខេបរបស់សាក្សីនីមួយៗដែលផ្តល់សក្ខីកម្មនៅក្នុងអំឡុងពេលនៃការជម្រះក្តី ឌុច នេះ។

## ហ្វ្រង់ស័រ ប៊ីហ្សូ



នៅថ្ងៃទី៨ ខែមេសា ឆ្នាំ២០០៩ លោក ហ្វ្រង់ស័រ ប៊ីហ្សូ បានឡើងផ្តល់សក្ខីកម្មទាក់ទងនឹងមន្ទីរម-១៣ ដែលមានទីតាំងនៅភូមិអមលាំង ឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ។ លោក ហ្វ្រង់ស័រ ប៊ីហ្សូ អាយុ៦៩ឆ្នាំមានសញ្ជាតិបារាំងសព្វថ្ងៃរស់នៅឈៀងម៉ៃក្នុងប្រទេសថៃភាគខាងជើងមានតួនាទីជាអ្នកស្រាវជ្រាវជាសាស្ត្រាចារ្យ និងជាសមាជិកនៃសាលាបារាំងចុងបូព៌ា។ លោក ហ្វ្រង់ស័រ ប៊ីហ្សូ បានរៀបរាប់ថា នៅថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៧១ គាត់បានធ្វើដំណើរទៅកាន់តំបន់ឧត្តុង្គ បន្ទាប់មកក៏មានឈ្លបពីរនាក់បានចាប់គាត់ចងស្លាបសេក រួចចោទគាត់ថាជាភ្នាក់ងារសេអ៊ីអា។ ពេលបណ្តើរគាត់ទៅដល់ភូមិមួយគាត់ក៏បានជួបជនួយការរបស់គាត់ពីរនាក់ទៀតឈ្មោះ ហុក ឡាយ និង បាំង សុន ដោយឃើញជើងរបស់គាត់ទាំងពីរនាក់ដាក់ខ្នោះរួចទៅហើយ។ បន្ទាប់មក គាត់ត្រូវបានបញ្ជូនមកឃុំខ្លួននៅមន្ទីរម-១៣ ប៉ុន្តែមិនបានយកសហការីរបស់គាត់ទៅជាមួយទេ។ នៅទីនោះ កជើងរបស់គាត់ត្រូវបានដាក់ខ្នោះដែលមានអ្នកទោសប្រហែល១,០១៥នាក់ជាប់ជាមួយគាត់ដែរ។ ប៉ុន្មានថ្ងៃក្រោយមក ឌុច បានមកសួរចម្លើយគាត់ដោយផ្ទាល់ ប៉ុន្តែក្នុងរបៀបទន់ភ្លន់និងមិនមានធ្វើទារុណកម្មទេ។ ចំណែកគាត់ក៏ព្យាយាមរៀបរាប់ឲ្យ ឌុច ជឿថាគាត់ជាបញ្ញវន្តដែលមកធ្វើការអំពីគម្ពីរសាសនានិងពុទ្ធសាសនាមែន។ ក្រោយមកទៀត គាត់ជឿថាគាត់នឹងត្រូវបានដោះលែង ដោយ ឌុច បានសួរគាត់ថា «តើគាត់អាចទុកសៀវភៅកំណត់ហេតុដែលគាត់បានសរសេរជារៀងរាល់យប់ឲ្យគាត់បានទេ?» ហ្វ្រង់ស័រ ប៊ីហ្សូ ក៏សម្រេចផ្តល់ឲ្យ។ ក្រោយមក ឌុច ឲ្យសៀវភៅកំណត់ហេតុនេះទៅ ហ្វ្រង់ស័រ ប៊ីហ្សូ វិញ។ ថ្ងៃមួយ ឌុច បានប្រាប់គាត់ថា គាត់នឹងមានដំណឹងល្អសម្រាប់គាត់។ ពេល ឌុច មកជួប ហ្វ្រង់ស័រ ប៊ីហ្សូ ម្តងទៀត ឌុច ក៏បានប្រាប់ថាគាត់អាចត្រឡប់ទៅជួបគ្រួសារវិញបានហើយ។ ប៉ុន្តែ ពេលនោះគាត់មិនជឿទេព្រោះអ្វីៗជាការកុហកទាំងអស់។ ហ្វ្រង់ស័រ ប៊ីហ្សូ ត្រូវបានដោះលែងនៅខែធ្នូ ឆ្នាំ១៩៧១ ដោយនៅថ្ងៃនោះ ឌុច បានរៀបចំអាហារថ្ងៃត្រង់ដល់អ្នកឃុំឃាំងទាំងអស់ទៀតផង។

## អ៊ុស ស៊ិន



នៅថ្ងៃទី៩ ខែមេសា ឆ្នាំ២០០៩ អ៊ុស ស៊ិន អាយុ៧២ឆ្នាំបានឡើងផ្តល់សក្ខីកម្មទាក់ទងនឹងមន្ទីរម-១៣។ អ៊ុស ស៊ិន បានរៀបរាប់ថា ដំបូងគាត់មិនស្គាល់មន្ទីរម-១៣ទេ រហូតដល់ថ្ងៃ២កើត ខែចេត្រ ឆ្នាំ១៩៧៣ ពេលដែលគាត់ត្រូវបានចាប់ខ្លួនមកមន្ទីរនេះដោយចោទថាជាគិញទើបគាត់ដឹងថាជាមន្ទីរឃុំឃាំងម-១៣។ ពេលដែលចាប់មកទីនេះ គាត់មានគ្នាបីនាក់ម្នាក់ឈ្មោះ តាគុល និងម្នាក់ទៀតឈ្មោះ តាទឹម ដែលអ្នកទាំងពីរស្លាប់អស់ហើយ នៅសល់តែគាត់ដែលត្រូវបានដោះលែងឲ្យមកធ្វើការនៅខាងក្រៅ។ អ៊ុស សន បន្តថាមន្ទីរនេះមានទំហំមួយរយម៉ែត្របួនជ្រុងមានរណ្តៅជាច្រើនកន្លែងហើយមានប្រក់ស្លឹកត្នោតពីលើនិងមានអ្នកទោសប្រហែល២-៣ពាន់នាក់ ជាបុរស ស្ត្រី ចាស់ និងក្មេង។ លើសពីនេះទៅទៀត អ៊ុស ស៊ិន បានឃើញអ្នកយាមចងមនុស្សប្រាំនាក់នឹងបង្គោល បន្ទាប់មកបាញ់សម្លាប់ម្នាក់ចំក្បាលនៅសល់បួននាក់ទៀតដោយអ្នកបាញ់នោះ ឈ្មោះ តាចាន់។ ក្រៅពីហេតុការណ៍នេះ គាត់បានឃើញអ្នកទោសត្រូវបានវាយនឹងត្បូងចបនិងដំបងគល់ឫស្សី ចាប់អ្នកទោសជ្រមុជទឹកក្នុងត្រពាំងប្រាបដើម្បីសួរចម្លើយ។ ថ្ងៃក្រោយទៀត ស៊ិន ឃើញសន្តិសុខវាយមនុស្សស្រីម្នាក់ដោយរំពាត់មានទំហំប៉ុនមេដៃ។ ពេលវាយរួច ឌុច ទះគូអ្នកទោសស្ត្រីនោះរួចស្រែកហោ។ ក្រោយមក ថ្ងៃមួយ ស៊ិន បានឃើញអ្នកយាមចងមនុស្សស្រីម្នាក់ និងប្រុសម្នាក់ដោយចងខ្សែប្រវាក់ជាមួយគ្នា បន្ទាប់មក វាយទម្លាក់រណ្តៅដែលគាត់ជីក។ នៅក្នុងគុកនោះ ស៊ិន បានឃើលសកម្មភាពដកក្រចក និងម្ជុលចាក់សម្រាប់ធ្វើទារុណកម្មអ្នកទោសទៀតផង។

នៅឆ្នាំ១៩៧៤ អ៊ុស ស៊ិន ត្រូវបានដោះលែងឲ្យទៅធ្វើការនៅខេត្តពោធិ៍សាត់វិញ។ ពេលនោះ កូន និងប្រពន្ធរបស់គាត់គិតថាគាត់ស្លាប់ហើយ រហូតដល់ឆ្នាំ១៩៧៩ទើបគាត់ត្រឡប់មកផ្ទះវិញ។ ក្រោយពី អ៊ុស សន និយាយចប់ ឌុច បានអះអាងថា គាត់មិនស្គាល់អ្នកផ្តល់សក្ខីកម្មនេះទេ។ គាត់បានបដិសេធថាគាត់មិនដែលវាយមនុស្សស្រីនោះទេនិងគ្មានអ្នកណាយកអ្នកទោសទៅជ្រមុជទឹកត្រពាំងប្រាបឡើយ ហើយប្រសិនបើធ្វើទារុណកម្មមែនក៏មិនដែលឲ្យអ្នកទោសផ្សេងឃើញដែរ។ ចំណែក នៅក្នុងគុកក៏គ្មានដង្កាប់ដកក្រចក និងម្ជុលចាក់ម្រាមដៃធ្វើទារុណកម្មដែរ។ ក្រៅពីនេះ មានចម្លើយមួយចំនួនដែល ឌុច បដិសេធថាមិនត្រឹមត្រូវដែរ។

## ចាន់ វឿន



នៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៩ លោក ចាន់ វឿន ឡើងផ្តល់សក្ខីកម្មទាក់ទងនឹងអគ្គហេតុមន្ទីរ ម-១៣។ ចាន់ វឿន មានអាយុ៥៦ឆ្នាំរស់នៅឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ សព្វថ្ងៃមានមុខរបរធ្វើស្រែចម្ការ។ ចាន់ វឿន បានរៀបរាប់ថា គាត់ធ្លាប់ជាបុគ្គលិកនៅមន្ទីរម-១៣ នៅឆ្នាំប្រហែល១៩៧៤ ដោយបានធ្វើការនៅទីនោះរយៈពេលមួយឆ្នាំ។ វឿន ដំបូងធ្វើការនៅអគ្គភាពទ័ព ក្រោយបាក់ទ័ពក៏មកធ្វើការនៅមន្ទីរនេះដោយមានតួនាទីកាន់ខាងសេដ្ឋកិច្ច។ វឿន អះអាងថា នៅក្នុងមន្ទីរនេះមានរណ្តៅគុកដែលជីកលុងក្នុងដីនោះមានបីកន្លែងជាប់ៗគ្នាហើយអ្នកទោសទាំងអស់សុទ្ធតែត្រូវបានដាក់ច្រវាក់ជើង ដៃ និង ក។

គាត់បានឃើញ ឌុច សួរចម្លើយអ្នកទោស គឺថាប្រសិនបើអ្នកទោសប្រុសនឹងឲ្យឈ្លបវាយធ្វើទារុណកម្ម បើអ្នកទោសស្រីនឹងឲ្យដោះអាវដុតដោះទៀត (យកក្រណាត់រំប្រេងកាតរុញទៅចំដោះ) ។ លើសពីនេះទៅទៀត គាត់បានឃើញអ្នកទោសត្រូវបានចងស្លាបសេកព្យួរទៅដើមឈើនិងជ្រមុជទឹកអ្នកទោសក្នុងអូរ ។ អ្នកទោសខ្លះទៀតត្រូវបានចងជាប់បង្គោល រួចបាញ់កាំភ្លើងអាកាពីរគ្រាប់ដោយមួយគ្រាប់ចំដៃនិងមួយគ្រាប់ទៀតចំទ្រូង ។ គាត់បន្តថា ថ្ងៃមួយ ដោយសារតែខ្វះកម្លាំង ឌុច បានឲ្យគាត់ទៅយាមអ្នកទោស ។ ដោយសារគាត់អស់កម្លាំងខ្លាំងពេកក៏ដេកលក់រហូតធ្វើឲ្យអ្នកទោសកាត់ច្រវាក់រត់រួចបីនាក់ ។ បន្ទាប់មក គាត់ត្រូវបានចាប់ដាក់ក្នុងគុកដោយដកហូតសម្លៀកបំពាក់របស់គាត់និងកាំភ្លើងផង ។ នៅយប់មួយគាត់ក៏ហែករបងគុកឫស្សីនៅម៉ោង១២យប់ រួចរត់ទៅពួននៅសហករណ៍ ។ ក្រោយមក គាត់មិនដែលបានជួប ឌុច ទៀតទេ ។

ឌុច បដិសេធថា ចាន់ វឿន មិនមែនជាបុគ្គលិកនៅមន្ទីរស-២១ទេ ព្រោះ ចាន់ វឿន បានរៀបរាប់ថា ប៉ុន ជាអ្នកសួរចម្លើយដែរ ប៉ុន្តែ ប៉ុន បានស្លាប់នៅឆ្នាំ១៩៧៤ ទៅហើយ ។ ឌុច និយាយបន្ថែមទៀតថា សក្ខីកម្មរបស់ វឿន មានមានរឿងខ្លះករទាំងស្រុង ចំណែករឿងខ្លះគាត់ឮតាមគេហើយយកមកប្រឌិតថែម ។

### ចាន់ ខន

នៅថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៩ ចាន់ ខន បានឡើងមកផ្តល់សក្ខីកម្មទាក់ទងនឹងមន្ទីរម-១៣ ។ ចាន់ ខន សព្វថ្ងៃរស់នៅភូមិទេពភិរម្យ ឃុំវាលពន់ ស្រុកថ្ពង ខេត្តកំពង់ស្ពឺ មានមុខរបរធ្វើស្រែ ។ ចាន់ ខន បានអះអាងថា គាត់ជាបុគ្គលិកនៅមន្ទីរម-១៣ ដោយមានតួនាទីយាមអ្នកទោស ។ គាត់បានបន្តថា ពេលដែលទៅដល់មន្ទីរម-១៣ គាត់បានឃើញរណ្តៅចំនួនពីរឬបីសម្រាប់ដាក់អ្នកទោសដែលមានកំហុស ដោយរណ្តៅនោះក្រាលក្តារនិងមានប្រក់ស្លឹកពីលើ ។ នៅទីនោះ អ្នកទោសជាច្រើនស្លាប់ដោយសារអត់អាហារហូបនិងខ្លះក៏ស្លាប់ដោយសារតែលង់ទឹកផងដែរនៅពេលដែលមានភ្លៀងខ្លាំងព្រោះយកអ្នកទោសចេញមិនទាន់ ។ នៅទីនោះ គាត់មិនដែលឮសំឡេងអ្នកទោសស្រែកឬឃើញឧបករណ៍សម្រាប់ធ្វើទារុណកម្មអ្នកទោសទេ ប៉ុន្តែគ្រាន់តែដឹងថាក្រោយពីអ្នកទោសត្រូវបានសួរចម្លើយហើយ អ្នកទោសទាំងនោះមានឈាមប្រឡាក់ពេញខ្លួនដោយសារត្រូវរំពាត់ឫស្សីឬផ្តៅ ។ ចាន់ ខន ក៏អះអាងថា ចាន់ វឿន ជាអ្នកយាមនៅ ម-១៣ដែរ ដោយពេលនោះគាត់បានធ្វើឲ្យអ្នកទោសរត់រួច ។ ចុងក្រោយ ចាន់ ខន រៀបរាប់ថា ក្រោយមក ឌុច ក៏ដកគាត់ចេញឲ្យទៅធ្វើស្រែវិញ ។

ឌុច បានទទួលស្គាល់ថា ចាន់ ខន ពិតជាបុគ្គលិកនៅមន្ទីរម-១៣ ។ ឌុច បន្តថា នៅពេលឃើញមុខរបស់ ខន គាត់មានទឹកចិត្តរំជើបរំជួលជាខ្លាំង ។ គាត់នឹកឃើញដល់ឪពុករបស់ ខន ឈ្មោះ ខុម ដែលធ្លាប់លេងជាមួយគ្នានិងសេចក្តីមេត្តាករុណារបស់ប្រជាជនបីភូមិគឺ ត្រពាំងគ្រោក ភូមិទំនាប និងភូមិថ្នគប់ ដោយប្រជាជនទាំងអស់នេះបានឲ្យកូនចៅរបស់គេមកធ្វើកងការពារ ។

### ក្រេក អេតឆេសាន់



ក្រេក អេតឆេសាន់ ជនជាតិអាមេរិក អាយុ៥៣ឆ្នាំ បច្ចុប្បន្នជាអ្នកស៊ើបអង្កេតនៅការិយាល័យសហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ លោក អេតឆេសាន់ ទទួលសញ្ញាប័ត្រអនុបណ្ឌិតផ្នែកវិទ្យាសាស្ត្រនយោបាយពីសកលវិទ្យាល័យអ៊ីលីណយ និងសញ្ញាប័ត្របណ្ឌិតផ្នែកទំនាក់ទំនងអន្តរជាតិពីសកលវិទ្យាល័យសៅខើនកាលីហ្វ័រញ៉ា ។

នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៩ លោក អេតឆេសាន់ ត្រូវអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាកោះអញ្ជើញឲ្យមកធ្វើជាសាក្សីជំនាញទាក់ទងនឹងរចនាសម្ព័ន្ធនៃបក្សកុម្មុយនីស្តកម្ពុជាឬកម្ពុជាប្រជាធិបតេយ្យនិងរចនាសម្ព័ន្ធគ្រប់គ្រងអ្នកទោសនៅ

មន្ទីរស-២១ ។ លោក អេតឆេសាន់ បានសិក្សាពីរចនាសម្ព័ន្ធនៃបក្សកុម្មុយនីស្តកម្ពុជាអស់រយៈពេលប្រមាណជាង៣០ឆ្នាំដោយលោកបានប្រើប្រាស់ឯកសារសំខាន់ៗដូចជា សេចក្តីសម្រេចក្នុងការកម្មេចក្នុងជួរបក្សនិងក្រៅជួរបក្ស លក្ខន្តិកៈរបស់បក្សកុម្មុយនីស្តកម្ពុជា កំណត់ហេតុប្រជុំនៃគណៈអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា កំណត់ហេតុទីស្តីការគណៈរដ្ឋមន្ត្រី ទូរលេខ ទស្សនាវដ្តីទង់បដិវត្តន៍ យុវជនបដិវត្តន៍ និងឯកសារនៅមន្ទីរស-២១ ។ នៅក្នុងការសិក្សារបស់គាត់ អេតឆេសាន់ បានធ្វើការវិភាគឯកសារដោយយោងទៅលើឯកសារទូរលេខមួយចំនួនដែលផ្ញើចេញ និងផ្ញើចូលគណៈមជ្ឈិមនិងមេដឹកនាំពីភូមិភាគផ្សេងៗដូចជា ញឹម រស់ ភូមិភាគពាយ័ព្យ កែ ពក ភូមិភាគកណ្តាល និង សោ ភឹម ភូមិភាគបូព៌ា និងរបាយការណ៍របស់តំបន់ ស្រុក និងសហករណ៍ផ្សេងៗទៀត ។

លោករៀបរាប់ថា បក្សកុម្មុយនីស្តកម្ពុជាគឺជាគណៈមជ្ឈិមដែលមានតួនាទីក្នុងការអនុវត្តមាគ៌ារបស់បក្សក្នុងប្រទេសនិងផ្តល់សេចក្តីណែនាំទៅភូមិភាគ តំបន់ និងអង្គភាពនានា ។ គណៈមជ្ឈិមមានតួនាទីចាត់ចែងកម្មាភិបាលសមាជិកនៅក្នុងបក្សពិនិត្យទៅលើប្រវត្តិរូប មនោគមន៍វិជ្ជានយោបាយ ការបង្រៀន និងអប់រំនយោបាយ និងអង្គការចាត់តាំង ។

លោក អេតឆេសាន់ បញ្ជាក់ថា ភារកិច្ចរបស់គណៈមជ្ឈិមគឺអនុវត្តដោយគណៈអចិន្ត្រៃយ៍ ឬ អង្គការលើ អង្គការថ្នាក់លើមជ្ឈិមបក្ស មជ្ឈិម និងបងៗថ្នាក់លើដែលរួមមាន ប៉ុល ពត ជាលេខាបក្ស, នួន ជា អនុលេខា, អៀង សារី, វ៉ន វ៉េត, សោ ភឹម និង ញឹម រស់ សមាជិកគណៈអចិន្ត្រៃយ៍ ចំណែក សុន សេន និង គង់ សុផល ជាសមាជិកបម្រុង ។ ប៉ុន្តែ ក្រោយមក សុន សេន បានឡើងជាសមាជិកគណៈអចិន្ត្រៃយ៍ ជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកខាងការពារជាតិនិងជានាយអគ្គសេនាធិការកងទ័ព ។

អេតឆេសាន់ បន្តថាចាប់ពីខែមីនាឆ្នាំ១៩៧៦ ដល់ខែកញ្ញា ឆ្នាំ១៩៧៧ ឌុច ប្រធានមន្ទីរស-២១ បានរាយការណ៍ពីចម្លើយសារភាពរបស់អ្នកទោសដោយផ្ទាល់ទៅ សុន សេន ។ ប៉ុន្តែ ក្រោយខែកញ្ញានៅពេល សុន សេន បានទទួលការចាត់តាំងឲ្យទៅបញ្ជាកងទ័ពបដិវត្តន៍កម្ពុជាដែលមានជម្លោះប្រដាប់អាវុធជាមួយវៀតណាម ឌុច បានរាយការណ៍ដោយផ្ទាល់ទៅឲ្យ នួន ជា ដែលជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា ។

**ណាយ៉ាន់ ចាន់ដា**



ណាយ៉ាន់ ចាន់ដា អាយុ៦៣ឆ្នាំ ដើមកំណើតឥណ្ឌាបច្ចុប្បន្នរស់នៅរដ្ឋកូណិកធីឃឹតសហរដ្ឋអាមេរិក ។ លោកជាបណ្ឌិតការនៅសាកលវិទ្យាល័យយ៉េល ហើយក៏ជាអ្នកឆ្លងឆ្លើយព័ត៌មានឲ្យទស្សនាវដ្តីសេដ្ឋកិច្ចចុងបូព៌ាដែរ ។ ចាប់ពីឆ្នាំ១៩៨៩ ដល់ឆ្នាំ១៩៩០ លោក ណាយ៉ាន់ ចាន់ដា ធ្វើជាសមាជិកជាន់ខ្ពស់នៅមជ្ឈមណ្ឌលខេនឌីស៊ីអេនដលមេនសម្រាប់កម្មវិធីសន្តិភាពអន្តរជាតិ និងពីឆ្នាំ១៩៩០ ដល់ឆ្នាំ១៩៩២ លោកជាអ្នកបោះពុម្ពកាសែតអេស៊ាវ៉ លស្រ្ទីត ។ បច្ចុប្បន្ន លោកជានាយកបោះពុម្ពផ្សាយនៅមជ្ឈមណ្ឌលសិក្សាស្រាវជ្រាវភាវូបនីយកម្មនៅសាកលវិទ្យាល័យយ៉េល ។ លោកបានសរសេរសៀវភៅមួយក្បាលគឺ «សត្រូវបងប្អូនឯង ៖ សង្គ្រាមបន្ទាប់ពីសង្គ្រាម» បោះពុម្ពនៅឆ្នាំ១៩៨៦ ដោយលោកចុះប្រមូលឯកសារ ហើយទៅសម្ភាសន៍ជាមួយប្រជាជននៅកន្លែងកើតហេតុផ្ទាល់និងបានដកស្រង់ព័ត៌មានពីការសែតញូវយ៉កថែមស៍ និងអេភី ។

នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៩ លោក ណាយ៉ាន់ ចាន់ដា ត្រូវអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាកោះអញ្ជើញឲ្យមកធ្វើជាសាក្សីជំនាញទាក់ទងនឹងខ្លឹមសារនិងអំណះអំណាងដែលលោកបានសរសេរនៅក្នុងសៀវភៅមានចំណងជើងថា «សត្រូវបងប្អូនឯង ៖ សង្គ្រាមបន្ទាប់ពីសង្គ្រាម» ។

នៅក្នុងការផ្តល់សក្ខីកម្មលោក ចាន់ដា បានបញ្ជាក់ថា

លោកធ្លាប់សម្អាសសម្តេចសីហនុ លោក ផាម វ៉ាន់ដុង នាយករដ្ឋមន្ត្រីវៀតណាម លោក អៀង សារី ឧបនាយករដ្ឋមន្ត្រី លោក ង្វៀង កូថាច់ រដ្ឋមន្ត្រីក្រសួងការបរទេសវៀតណាម ។ លោក ចាន់ដា បន្តថា សៀវភៅ «សត្រូវបងប្អូនឯង» បានរៀបរាប់ពីប្រទេសវៀតណាម ឡាវ ថៃ និងគោលនយោបាយបរទេស និងជម្លោះនៅប្រទេសចិន ។ លោកបាននិយាយថា ជម្លោះប្រដាប់អាវុធរវាងកម្ពុជាប្រជាធិបតេយ្យនិងវៀតណាមនៅលើកោះពូលូវៃ កោះក្រចកសេះ ការបណ្តេញជនជាតិវៀតណាមចេញពីប្រទេសកម្ពុជានិងការវាយប្រហាររបស់កងទ័ពខ្មែរក្រហមទៅលើប្រជាជនស៊ីវិលក្នុងខេត្តតៃនិញ និងនៅតាមបណ្តោយព្រំដែននៃប្រទេសវៀតណាមថាជារឿងមនោគមន៍វិជ្ជា ។ លោក ចាន់ដា បានធ្វើការបញ្ជាក់បន្ថែមពីការវាយលុកទ្រង់ទ្រាយធំដំបូងរបស់វៀតណាមមកលើកម្ពុជាប្រជាធិបតេយ្យនៅខែតុលា ឆ្នាំ១៩៧៧ ។ កងទ័ពអាមេរិកដែលមានមូលដ្ឋានទ័ពតាំងនៅលើប្រទេសថៃបានវាយប្រហារមកលើកងទ័ពខ្មែរក្រហមដោយចោទខ្មែរក្រហមថាបានចាប់កប៉ាល់របស់ខ្លួនឈ្មោះម៉ាយ៉ាហ្គេ ។ ជម្លោះរវាងកម្ពុជាប្រជាធិបតេយ្យនៅតាមព្រំដែនថៃបានកើតឡើងដោយខ្មែរក្រហមចោទថាប្រទេសថៃបានធ្វើការទម្លាក់គ្រាប់បែកមកលើប្រទេសកម្ពុជា ។ នៅពេលចុងក្រោយលោកបានរៀបរាប់រាប់ពីការវាយប្រហារជាទ្រង់ទ្រាយធំរបស់វៀតណាមនៅខែធ្នូ ឆ្នាំ១៩៧៨ រហូតកាន់កាប់បានទីក្រុងភ្នំពេញទាំងស្រុងនៅខែមករា ឆ្នាំ១៩៧៩ ។

**វ៉ាន់ ណាត**



មុនឆ្នាំ១៩៧៥ វ៉ាន់ ណាត ជាជាងគំនូររស់នៅខេត្តបាត់ដំបង ។ នៅខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានជម្លៀស ណាត ឲ្យទៅរស់និងធ្វើស្រែនៅភូមិអូរមុន្នី ស្រុក៤១ តំបន់៤ ភូមិភាគពាយ័ព្យ ។ នៅថ្ងៃ៣០ ខែធ្នូ ឆ្នាំ១៩៧៧ ប្រធានសហករណ៍ឈ្មោះ មិត្តលួម បានចាត់តាំង ណាត ឲ្យទៅបោចផ្កានៅខេត្តពោធិ៍សាត់ ប៉ុន្តែត្រូវកងឈ្លបខ្លួនបញ្ជូនទៅឃុំឃាំងនៅវត្តសំរោងបុគ្គក ស្រុក៤១ ដោយចោទថាខ្មាំង ។ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៨ ណាត ត្រូវបានអង្គការបញ្ជូនតាមរថយន្តមកឃុំឃាំងនៅគុកទួលស្លែង ។ រយៈពេលមួយខែក្រោយមក កងការពារបានទៅយក ណាត ពីបន្ទប់ឃុំឃាំងមកជួបនឹង ឌុច ។ នៅពេលនោះ ឌុច បានយករូបថតមេដឹកនាំកម្ពុជាប្រជាធិបតេយ្យ (ប៉ុល ពត) ឲ្យ ណាត គូរតាមឲ្យដូច ។ បន្ទាប់ពីឃើញរូបគំនូររបស់ ណាត រួចហើយ ឌុច បានបញ្ជាឲ្យកងការពារយក ណាត មកធ្វើការក្នុងក្រុមគូរគំនូរ ទើប ណាត នៅរស់ជីវិត ។ សព្វថ្ងៃ ណាត អាយុ៦៣ឆ្នាំ រស់នៅសង្កាត់មិត្តភាព ខណ្ឌ៧មករា ក្រុងភ្នំពេញ ។

នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានកោះអញ្ជើញ ណាត ឲ្យមកធ្វើជាសាក្សីទាក់ទងនឹងអង្គការចាប់ខ្លួនគាត់និងរឿងរ៉ាវដែលគាត់បានជួបប្រទះនៅពេលគាត់រស់នៅក្នុងមន្ទីរស-២១បុគ្គកទួលស្លែង ។ នៅពេលផ្តល់សក្ខីកម្ម ណាត បានរៀបរាប់ពីវិធីដឹកជញ្ជូនអ្នកទោសពីខេត្តបាត់ដំបងមកមន្ទីរ ស-២១ លក្ខខណ្ឌរស់នៅនិងរបបអាហាររបស់អ្នកទោសនៅមន្ទីរស-២១ ការងារគូរគំនូរនិងធ្វើពុម្ពរូបចម្លាក់របស់គាត់នៅមន្ទីរស-២១ ។ ណាត បញ្ជាក់ថាអ្នកសួរចម្លើយនៅមន្ទីរស-២១ បានប្រើវិធីដកក្រចកនិងយកសត្វអសិរពិសឲ្យទិចអ្នកទោសនិងជ្រមុជអ្នកទោសចូលទៅក្នុងអាងទឹកដើម្បីទាញយកចម្លើយសារភាព ។ ក្រោយរបបខ្មែរក្រហមដួលរលំ ណាត បានគូរគំនូរជាច្រើនផ្ទាំងឆ្លុះបញ្ចាំងពីរឿងរ៉ាវដែលគាត់ឃើញដោយផ្ទាល់ភ្នែកនិងស្តាប់ឮដោយផ្ទាល់ត្រចៀកនិងតាមរយៈអ្នកទោសនៅមន្ទីរស-២១និយាយប្រាប់គាត់ ។

**ជុំ ម៉ី**

នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ ជុំ ម៉ី បានមកផ្តល់សក្ខីកម្មនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ជុំ ម៉ី បានរៀបរាប់ថា គាត់មានស្រុកកំណើតនៅស្រុកបាភ្នំ ខេត្ត

ព្រៃវែង ។ នៅមុនថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ជុំ ម៉ី ធ្វើជាជាង



ជួសជុលត្រាក់ទ័រនិងឡាននៅភ្នំពេញ ។ ជុំ ម៉ី និងប្រពន្ធត្រូវកងទ័ពខ្មែរក្រហមជម្លៀសចេញពីទីក្រុងទៅទីជនបទក្រោយមកកម្មាភិបាលខ្មែរក្រហមបានហៅគាត់បានមកធ្វើការនៅភ្នំពេញវិញ ។ បន្ទាប់ពីធ្វើការនៅភ្នំពេញរយៈពេលបីឆ្នាំកម្មាភិបាលខ្មែរក្រហមមកហៅ ជុំ ម៉ី ដោយកុហកថាទៅជួសជុលម៉ាស៊ីនឡាននៅប្រទេសវៀតណាម ប៉ុន្តែគាត់ត្រូវបានបញ្ជូនមកមន្ទីរស-២១ទៅវិញ ។

ជុំ ម៉ី បានប្រាប់អង្គជំនុំជម្រះថានៅមន្ទីរស-២១ ខ្មែរក្រហមបានសម្រាតខោអាវគាត់ចេញអស់នៅសល់តែខោខ្លីមួយប៉ុណ្ណោះ ។ ជុំ ម៉ី ត្រូវបានចោទប្រកាន់ថាបានរួមគំនិតជាមួយ សេ.អ៊ី.អា ឬ កា.ហ្សេ.បេ ដើម្បីផ្តួលរលំបដិវត្តន៍ ។ ជុំ ម៉ី បានប្រាប់អ្នកសួរចម្លើយនៅមន្ទីរស-២១ថា គាត់មិនដែលស្គាល់ ឬពាក្យ សេ.អ៊ី.អា ឬ កា.ហ្សេ.បេ ទេ ហើយបានទទួលរងនូវទារុណកម្មដកក្រចកជើង ឆក់ខ្សែភ្លើង ដោយសារតែប្រកែកមិនព្រមឆ្លើយតាមការចង់បានរបស់អ្នកសួរចម្លើយ ។

ជុំ ម៉ី ត្រូវកងសួរចម្លើយវាយធ្វើទារុណកម្មរយៈពេល១២ថ្ងៃ ។ ដោយសារទទួលរងនូវទារុណកម្មធ្ងន់ធ្ងរពេក ជុំ ម៉ី បានសារភាពថាជាខ្សែក្បត់ សេ.អ៊ី.អា ហើយបានរៀបរាប់ឈ្មោះមនុស្សជាច្រើនទៀតដែលស្ថិតនៅក្នុងខ្សែក្បត់របស់គាត់ទោះបីជាឈ្មោះទាំងនោះមិនដែលចូលរួមពាក់ព័ន្ធជាមួយអំពើក្បត់ក៏ដោយ ។ ជុំ ម៉ី បាននិយាយថាគាត់ធ្វើបែបនេះដោយសារតែគាត់ទទួលទារុណកម្មធ្ងន់ធ្ងរពេក ។ ជុំ ម៉ី បានបាត់បង់ប្រពន្ធម្នាក់និងកូនបួននាក់នៅក្នុងរបបខ្មែរក្រហម ។

នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ជុំ ម៉ី ជាដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ ។ ជុំ ម៉ី សូមឲ្យតុលាការជួយរកយុត្តិធម៌ដល់គាត់និងជនរងគ្រោះជាច្រើននាក់ទៀតដែលបានបាត់បង់គ្រួសារនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

**ប៊ូ ម៉េង**



ប៊ូ ម៉េង អាយុ៦៨ឆ្នាំមានស្រុកកំណើតនៅឃុំកំពង់កុង ស្រុកកោះធំ ខេត្តកណ្តាល ។ នៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៩ ប៊ូ ម៉េង បានមកផ្តល់សក្ខីកម្មនៅក្នុងអង្គជុំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

នៅឆ្នាំ១៩៧៦ ខ្មែរក្រហមបានជម្លៀស ប៊ូ ម៉េង និងប្រពន្ធរបស់គាត់ឈ្មោះ ម៉ា យឿន ឲ្យទៅនៅសហករណ៍តាឡីដែលស្ថិតនៅក្នុងខេត្តកណ្តាល ។ នៅទីនោះ អង្គការបានឲ្យ ប៊ូ ម៉េង ធ្វើការជាមួយប្រជាជនដទៃទៀតដូចជា ជីកប្រឡាយ លើកទំនប់ ធ្វើស្រែនិងដាំបន្លែជាដើម ។ ថ្ងៃមួយ កម្មាភិបាលខ្មែរក្រហមបានបើកឡានហ្ស៊ីបមកហៅ ប៊ូ ម៉េង និងប្រពន្ធរបស់គាត់ឲ្យទៅបង្រៀនក្មេងនៅសាលារចនា ។ នៅពេលនោះ ប៊ូ ម៉េង នឹកគិតថានៅពេលខ្លួនមានជំនាញខាងគូរគំនូរ គាត់មានការត្រេកអរជាខ្លាំង ដោយគិតថាត្រូវនឹងអាជីពរបស់ខ្លួនហើយ ។ ក៏ប៉ុន្តែរថយន្តហ្ស៊ីបនោះមិនទៅសាលារចនាទេ បែរជាបត់ចូលទៅកន្លែងមួយនៅក្បែរគុកទួលស្លែងទៅវិញ ដែលមានរៀបចំកៅអីជាច្រើនជួរ ហើយក្រុមសន្តិសុខបានហៅប្រពន្ធរបស់គាត់ឲ្យចុះពីលើឡាន និងបានយកខ្នោះដៃមកដាក់ថែមទៀត ។ ប៊ូ ម៉េង ចាំថា ពេលនោះប្រពន្ធរបស់គាត់ស្រែកយំយ៉ាងខ្លាំង ។ ប៊ូ ម៉េង ត្រូវបានកងសន្តិសុខយក

ក្រណាត់ពណ៌ខ្មៅមកចងរុំភ្នែកទាំងសងខាង ហើយបណ្តើរចូលទៅក្នុងមន្ទីរស-២១ ។ អ្នកថតរូបបានថតរូបគាត់និងប្រពន្ធគាត់ ។ បន្ទាប់ពីថតរូបហើយ កងសន្តិសុខបានបញ្ជូន ប៊ូ ម៉េង ទៅកាន់អគារ «គ» នៅជាន់ទីបី ចំណែកប្រពន្ធរបស់គាត់ត្រូវកងសន្តិសុខយកទៅឃុំឃាំងនៅកន្លែងផ្សេង ។ ក្រោយមក កងសន្តិសុខបានបញ្ជា ប៊ូ ម៉េង ឲ្យដេកផ្កាប់មុខ ហើយយករំពាត់វាយទៅលើខ្នងគាត់យ៉ាងខ្លាំង ។ នៅពេលនោះ ម៉ម ណៃ ដែលជាអតីតអនុប្រធានរបស់ ឌុច បានស្ទុះចាប់យករំពាត់មកវាយខ្នងរបស់គាត់ ហើយបានសួរថាចូល សេ.អ៊ី.អា និង កា.ហ្សេ.បេ តាំងពីឆ្នាំណា? ប៊ូ ម៉េង បានឆ្លើយប្រាប់ថាគាត់មិនដែលដឹងថាពាក្យ សេ.អ៊ី.អា និង កា.ហ្សេ.បេ មានន័យអ្វីផង ។

នៅឆ្នាំ១៩៧៧ កម្មាភិបាលខ្មែរក្រហមបានប្រកាសសួររកអ្នកចេះគូរគំនូរ ។ ពេលនោះ ប៊ូ ម៉េង ក៏បានលើកដៃ ។ កម្មាភិបាលនោះបាននាំ ប៊ូ ម៉េង ទៅជួប ឌុច រួចហើយ ឌុច បានបញ្ជាឲ្យគាត់គូរគំនូរ ប៉ុល ពត និង ម៉ៅ សេទុង ព្រមទាំងព្រមានថាបើគូរមិនដូចនឹងយកទៅវាយចោល ។ ប៉ុន្តែដោយសារ ប៊ូ ម៉េង មានជំនាញខាងគំនូរនិងគូរស្អាតទើបគាត់អាចរស់រានមានជីវិតមកដល់សព្វថ្ងៃនេះ ។

**នង ចាន់ផល**



នង ចាន់ផល អាយុ៣៩ឆ្នាំសព្វថ្ងៃរស់នៅក្រុងភ្នំពេញ ។ នៅថ្ងៃទី២ ខែកក្កដា ឆ្នាំ២០០៩ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានកោះអញ្ជើញ នង ចាន់ផល មកផ្តល់សក្ខីកម្ម ។ នៅក្នុងសវនាការ នង ចាន់ផល បានរៀបរាប់ថា នៅឆ្នាំ១៩៧៨ គាត់មានអាយុប្រាំពីរឆ្នាំ រស់នៅភូមិក្រែងត្រយឹង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ។ ឪពុក នង ចាន់ផល ជាអតីតកម្មាភិបាលខ្មែរក្រហមនិងជាជាងឈើ ។ នៅឆ្នាំ១៩៧៨ ខ្មែរក្រហមបញ្ជូនឪពុក នង ចាន់ផល មកភ្នំពេញ ។ ពីរខែក្រោយមក រថយន្តហ្ស៊ីបពីរគ្រឿងរបស់យោធាខ្មែរក្រហមបានមកទទួលម្តាយនិងបងប្អូនគាត់ដោយប្រាប់ថាទៅជួបឪពុកនៅភ្នំពេញ ។ នង ចាន់ផល និងម្តាយរបស់គាត់បានសម្រាកនៅស្ថានីយរថភ្លើងរយៈពេលបីថ្ងៃ ទើបយោធាខ្មែរក្រហមបញ្ជូនមកមន្ទីរស-២១ ។ នង ចាន់ផល បានឃើញដោយផ្ទាល់ភ្នែកពេលដែលកងសន្តិសុខវាយម្តាយរបស់គាត់ដែលកំពុងមានជំងឺ ។ នង ចាន់ផល និងបងប្អូនរបស់ខ្ញុំបីនាក់ទៀតដេកនៅលើកម្រាលឥដ្ឋបែកពីម្តាយ ។ នង ចាន់ផល និងប្អូនរស់នៅរោងជាងខាងក្រោយមន្ទីរស-២១ដោយមានស្ត្រីម្នាក់ជាអ្នកមើលថែទាំ ។ នង ចាន់ផល បានសម្លឹងឃើញម្តាយរបស់គាត់ឈរនៅជិតចម្រឹងបង្អួច ហើយចាប់តាំងពីនោះមកគាត់បែកពីម្តាយរហូត ។

នៅឆ្នាំ១៩៧៩ពេលដែលវៀតណាមចូលមកដល់នៅទីក្រុងភ្នំពេញ នង ចាន់ផល និងកុមារដទៃទៀតបានលាក់ខ្លួនក្បែរគំនរខោអាវអ្នកទោសនៅមន្ទីរស-២១ ។ នៅពេលនោះ មានកងទ័ពវៀតណាមជាច្រើននាក់បានចូលមកតាមខ្លោងទ្វារខាងកើតមន្ទីរស-២១ រួចយក នង ចាន់ផល ចេញពីទីនោះ ។

ដំបូង ឌុច បានបដិសេធថា ម្តាយរបស់ នង ចាន់ផល បានស្លាប់នៅកន្លែងផ្សេងមិនមែននៅមន្ទីរស-២១ទេ ។ ប៉ុន្តែបន្ទាប់ពីគាត់ឃើញឯកសារប្រវត្តិរូបរបស់ម្តាយ នង ចាន់ផល ទើបគាត់ទទួលស្គាល់ថាម្តាយរបស់ នង ចាន់ផល បានជាប់ឃុំនៅមន្ទីរស-២១ពិតប្រាកដមែន ។

**លី ហ៊ិ**

លី ហ៊ិ អាយុ៥៧ឆ្នាំរស់នៅខេត្តបន្ទាយមានជ័យ ។ នៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៩ លី ហ៊ិ បានមកផ្តល់សក្ខីកម្មនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទាក់ទងនឹងជនត្រូវចោទ ឌុច នៅមន្ទីរស-២១និងមន្ទីរពេទ្យឆ្កតតាខ្មៅ ។ លី ហ៊ិ បាននិយាយថា នៅឆ្នាំ១៩៧៥គាត់ត្រូវខ្មែរក្រហមជម្លៀសឲ្យទៅស្រុកកោះធំ តំបន់២៥ មានតួនាទីជាទាហានវរៈ១១៩ ។

នៅឆ្នាំ១៩៧៦ លី ហ៊ិ ត្រូវបានអង្គការចាប់ខ្លួនយកទៅ

ដាក់នៅពោធិ៍ទន្ទេ ឃុំមន្ទីរ១៥មួយរយៈ។ នៅចុងឆ្នាំ១៩៧៦ អង្គការបានផ្លាស់គាត់យកមកដាក់ក្នុងមន្ទីរពេទ្យឆ្កួតនៅតាខ្មៅវិញ ដោយមានគ្នាប្រហែលបួននាក់។ នៅទីនោះ អង្គការបានសួរចម្លើយគាត់និងបានវាយធ្វើទារុណកម្មគាត់និងដាក់ខ្នោះទាំងយប់ទាំងថ្ងៃ។ នៅពេលយប់មួយ លី ហ៊ា ត្រូវកងសន្តិសុខបញ្ជូនតាមរថយន្តធំមួយគ្រឿងមកកាន់មន្ទីរស-២១។ នៅពេលមកដល់ស-២១ លី ហ៊ា ត្រូវកងសន្តិសុខដាក់ខ្នោះដដែល។ ក្រោយមក គាត់ត្រូវបញ្ជូនទៅកន្លែងកសាងខ្លួនទៅព្រៃស ឃុំមន្ទីរស-២៤។ លី ហ៊ា ហាក់បីដូចជាមានភាពស្រពេចស្រពិលពេលផ្តល់សក្ខីកម្មដោយសារគាត់ភ្លេចច្រើន។

មិត្តលឿន, មិត្តនន់ ដែលអ្នកទាំងអស់ជាកម្មាភិបាលអនុសេនាធំ ចំណែក ឡាយ ចាន់ ដោយសារតែនៅតូចពេក អង្គការបានឲ្យគាត់ធ្វើជានិរសារ។ ក្រោយមក យោធាខ្មែរក្រហមបញ្ជូន ឡាយ ចាន់ ទៅមន្ទីរឃុំឃាំងដែលគាត់ជឿថាជាមន្ទីរស-២១។ ក្នុងរយៈពេលពីរបីខែ ឡាយ ចាន់ ត្រូវបានសួរចម្លើយ និងវាយធ្វើទារុណកម្មចំនួនពីរលើកដោយចោទគាត់ថាបានលួចស្រូវទុកឲ្យខ្មាំង។ ឡាយ ចាន់ ត្រូវបានឃុំខ្លួននៅក្នុងបន្ទប់ធំមួយហើយគាត់ត្រូវកងសន្តិសុខរុំមុខរួចនាំចេញពីអគារ។ នៅពេលយប់ គាត់ត្រូវឆ្មាំគុកបញ្ជាឲ្យដឹករណ្តៅដើម្បីដាំចេក។ ឡាយ ចាន់ បាននិយាយថា ពេលខ្លះគាត់ស្រេកទឹកយ៉ាងខ្លាំង រហូតធ្វើឲ្យគាត់ផឹកទឹកនោមខ្លួនឯង។





នៅមន្ទីរពេទ្យឆ្កួតតាខ្មៅ លី ហ៊ា បញ្ជាក់ថាគាត់ត្រូវបានសួរចម្លើយចំនួនបីដងនិងទទួលរងការវាយធ្វើបាបយ៉ាងខ្លាំងដើម្បីឲ្យឆ្លើយសារភាពមុននឹងត្រូវបញ្ជូនទៅកាន់មន្ទីរស-២១។ លី ហ៊ា ត្រូវបានជាប់ឃុំនៅមន្ទីរស-២១រយៈពេលមួយខែមុននឹងគាត់បញ្ជូនទៅកាន់មន្ទីរស-២៤។ ក្រោយមក លី ហ៊ា បានលួចរត់ចេញពីមន្ទីរស-២៤ ដោយហែលឆ្លងទឹកស្ទឹង។ លី ហ៊ា មិនអាចចាំបានថាគាត់ត្រូវបានគេថតរូបមុននឹងចូលទៅដល់មន្ទីរស-២១ទេ។

## ឡាយ ចាន់

នៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០០៩ ឡាយ ចាន់ មកពីស្រុកសូទ្រនិគម ខេត្តសៀមរាប បានឡើងមកផ្តល់សក្ខីកម្មនៅក្នុងតុលាការទាក់ទងនឹងការធ្វើទារុណកម្មនៅស-២១។ ឡាយ ចាន់ បានរៀបរាប់ថា មុនដំបូងគាត់គ្រាន់តែជាអ្នកលីសែងនៅកំពង់ផែកីឡូម៉ែត្រលេខ៦ប៉ុណ្ណោះ។ ក្រោយមក អង្គការបានស្នើមិត្តឃឹន

មួយរយៈក្រោយមក ឡាយ ចាន់ ត្រូវកងសន្តិសុខដឹកតាមរថយន្តទៅដាក់មន្ទីរមួយទៀតស្ថិតនៅជាយក្រុងដែលជាមណ្ឌលអប់រំកែប្រែខ្លួនសាជាថ្មី។ នៅទីនោះ អង្គការចាត់តាំងឲ្យ ឡាយ ចាន់ ដើររើសឪសសម្រាប់ដុតរម្ងាស់ស្ករត្នោត ទើបគាត់អាចរស់ជីវិតរហូតមកដល់សព្វថ្ងៃ។

## ភោគ ខន

ភោគ ខន បានរៀបរាប់ថា នៅឆ្នាំ១៩៧៥ គាត់មានឈ្មោះ ភោគ សាខុន ប៉ុន្តែ ក្រោយមក គាត់ក៏បានប្រែឈ្មោះទៅជា ភោគ ខន វិញ។ ភោគ ខន បានចូលបម្រើកងទ័ពខ្មែរក្រហមពេលដែលគាត់មានអាយុ១៥ឆ្នាំ ហើយនៅឆ្នាំ១៩៧៦គាត់ជាអ្នកយាមការពារនៅមន្ទីរសេនាធិការរបស់ សុន សេន។ ក្រោយមកទៀតគាត់ត្រូវបានបង្ខំឲ្យរៀបការជាមួយនឹងនារីម្នាក់ដែលគាត់មិនដែលបានស្គាល់ពីមុនមក។ នៅឆ្នាំ១៩៧៨ ភោគ ខន ត្រូវបានចាប់ខ្លួន

នឹងបញ្ជូនមកកាន់មន្ទីរឃុំឃាំងដែលគាត់ជឿថាជាមន្ទីរស-២១ ។ ខន ត្រូវបានសួរចម្លើយនិងទទួលរងការធ្វើទារុណកម្មចំនួនបីដង ដែលពេលនោះក៏មានវត្តមាន ឌុច ប្រមាណដប់ប្រាំទៅម្ភៃនាទីដែរ ។ ខន អះអាងថា ឌុច មានឈ្មោះមួយទៀតគឺ «បងខាងកើត» ។ ថ្ងៃមួយ ភោគ ខន និងអ្នកទោសប្រហែលសាមសិបនាក់ទៀតត្រូវបានបញ្ជូនទៅកាន់កន្លែងមួយដែលគាត់ជឿថាជាបឹងជើងឯក ។

ក្រោយពីបានចំណាយពេលនៅក្នុងផ្ទះឈើមួយរយៈមក គាត់ត្រូវបាននាំចេញមកកាន់រណ្តៅជាមួយនឹងអ្នកទោសប្រាំនាក់ផ្សេងទៀត ។ ភោគ ខន បានរងនូវការវាយចំដងកនិងឆ្អឹងជំនីរមុននឹងធ្លាក់ចូលក្នុងរណ្តៅទាំងមិនដឹងខ្លួន ។ គាត់បានដឹងខ្លួនឡើងវិញដោយឃើញសាកសពពីរបីនាក់ទៅនៅលើគាត់ ។ ភោគ ខន បានព្យាយាមរត់មកកាន់ស្ទឹងមួយហើយបានប្រើឈើបណ្តែតខ្លួនមកកាន់ទីក្រុងភ្នំពេញរួចបានជួបនឹងកងទ័ពវៀតណាមដែលជួយសង្គ្រោះគាត់ដាក់លើទូក ។



បងប្អូនជីដូនមួយនិងប្រពន្ធរបស់ ភោគ ខន បានស្លាប់នៅមន្ទីរស-២១ ។ នៅឆ្នាំ២០០៨ ភោគ ខន បានមកទស្សនាគុកទួលស្លែង ។ គាត់បានខំស្វែងរកមើលប្រវត្តិរូបរបស់អ្នកទាំងពីរដែរប៉ុន្តែគាត់រកមិនឃើញ ។ ភោគ ខន បានសន្និដ្ឋានថាគាត់ពិតជាជាប់ឃុំនៅមន្ទីរស-២១មែន ។ គាត់ជឿទៀតថាគាត់រត់គេចខ្លួនរួចពីបឹងជើងឯកយ៉ាងពិតប្រាកដ ។ គាត់បាននិយាយថាៈ «ខ្ញុំសូមសន្មតថាកន្លែងដែលខ្ញុំត្រូវគេសម្លាប់ចោលនោះគឺបឹងជើងឯក បើទោះបីជា ខ្លួនខ្ញុំមិនដែលបានទៅទីនោះពីមុនមកក៏ដោយ» ។

## ឈិន ម៉េត



នៅថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០៩ ឈិន ម៉េត បានឡើងមកផ្តល់សក្ខីកម្មនៅក្នុងអង្គជំនុំជម្រះក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងទៅនឹងមន្ទីរស-២១ ។ ឈិន ម៉េត មានតួនាទីជានារីភូមិសព្វថ្ងៃរស់នៅក្នុងសង្កាត់បឹងទំពុន ខណ្ឌមានជ័យ ក្រុងភ្នំពេញ ។ ឈិន ម៉េត មានស្រុកកំណើតនៅភូមិជន្លួស ឃុំទួលគ្រើល ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ។ ឪពុកឈ្មោះ ឃឹម ឈិន ស្លាប់ និងម្តាយឈ្មោះ ឡី មន ស្លាប់ ។

នៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ១៩៧៧ ឈិន ម៉េត ត្រូវបានចាប់ខ្លួននិងបញ្ជូនមកកាន់មន្ទីរឃុំឃាំងស-២១ ។ ក្នុងរយៈពេលដប់ប្រាំថ្ងៃគាត់បានជាប់ឃុំជាមួយនឹងនារីពីរនាក់ទៀតដែលគាត់ស្គាល់គ្នាពីមុនមក ។ ឈិន ម៉េត ត្រូវបានសួរចម្លើយនិងរងការធ្វើទារុណកម្ម ហើយក្រោយមកក៏ត្រូវបញ្ជូនមកកាន់កន្លែងឃុំឃាំងមួយទៀតដែលគាត់ជឿថាជាមន្ទីរស-២៤ ។ គាត់ត្រូវបានបង្ខំឲ្យធ្វើការយ៉ាងធ្ងន់ធ្ងរនៅវាលស្រែមុននឹងបញ្ជូនមកកងដាំបន្លែ ។ ឈិន ម៉េត បានរត់ភៀសខ្លួនចេញពីទីកន្លែងនោះនៅពេលដែលកងទ័ពវៀតណាមបានមកដល់ ហើយគាត់ក៏ត្រូវស្ត្រីចំណាស់ម្នាក់ទទួលយកទៅចិញ្ចឹម ។

ឌុច បានបដិសេធ ឈិន ម៉េត ថាមិនមែនជាអតីតអ្នកទោសនៅមន្ទីរស-២១ទេ ។ តែ ឈិន ម៉េត បានបញ្ជាក់ថាគាត់ពិតជាបានជាប់នៅមន្ទីរស-២១មែន ហើយមានទាំងរូបថតមួយសន្លឹកជាភស្តុតាងផង ។

## ណាំ ម៉ុន



សព្វថ្ងៃ ណាំ ម៉ុន រស់នៅស្រុកកំពង់សៀម ខេត្តកំពង់ចាម ។ ណាំ ម៉ុន បានឃើញរូបថតឪពុករបស់គាត់នៅក្នុងមន្ទីរ ស-២១ ។ គាត់បានសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ។ នៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៩ ណាំ ម៉ុន បានរៀបរាប់នៅក្នុងអង្គសវនាការថា ចាប់តាំងពីឆ្នាំ១៩៧៥ ណាំ ម៉ុន ត្រូវបានប្រែឈ្មោះ រឿន ចន្ទា វិញ ។ នៅពាក់កណ្តាលឆ្នាំ១៩៧៥ ពេលអាយុ១៥ឆ្នាំ ណាំ ម៉ុន ត្រូវបានអង្គការចាត់តាំងឲ្យធ្វើពេទ្យនៅក្នុងមន្ទីរស-២១ ជាមួយ មិត្តលន និង មិត្តឃឹម ។ ណាំ ម៉ុន បាននិយាយថា នៅទីនោះប្រធានពេទ្យបែងចែកបុគ្គលិកជាបីក្រុមដើម្បីមើលអ្នកជំងឺនៅតាមអគារ ។ នៅពេលនោះ អង្គការបានឲ្យគាត់ទទួលខុសត្រូវនៅក្នុងអគារបណ្តោយថ្ងៃមួយ ។ ចំណែកមិត្តពីរនាក់ទៀត ជាអ្នកមើលការខុសត្រូវនៅក្នុងអគារផ្សេងទៀត ។ ឪពុកម្តាយ ណាំ ម៉ុន ជាអ្នកគ្រប់គ្រងលើការថតចម្លងឯកសារសម្រាប់ខ្មែរក្រហម ។ ចំណែកឯបងប្រុសពីរនាក់របស់ ណាំ ម៉ុន គឺជាអ្នកយាមនៅមន្ទីរស-២១ ។ នៅឆ្នាំ១៩៧៧ ណាំ ម៉ុន បានឃើញឪពុកគាត់ជាប់ខ្នោះនិងឃើញអ្នកយាមបណ្តើរចូលក្នុងបរិវេណមន្ទីរស-២១ ។ ឪពុករបស់ ណាំ ម៉ុន ជាប់ឃុំនៅក្នុងគុកជាមួយនឹងកម្មាភិបាលខ្មែរក្រហមផ្សេងទៀត ។ ណាំ ម៉ុន បានទៅសួរសុខទុក្ខឪពុកបានម្តង ហើយឃើញឪពុកគាត់បានទទួលរងនូវទារុណកម្មយ៉ាងធ្ងន់ធ្ងរ ។ ឪពុកគាត់បានប្រាប់គាត់ឲ្យនៅឆ្ងាយពីគាត់ ។ រយៈពេលប្រាំមួយខែក្រោយមក គ្រូពេទ្យម្នាក់ប្រាប់ ណាំ ម៉ុន ថាបងប្រុស ណាំ ម៉ុន ម្នាក់ត្រូវបានចាត់តាំងឲ្យសម្លាប់ឪពុករបស់ខ្លួន ។ បីថ្ងៃក្រោយមក បងប្រុស ណាំ ម៉ុន ដែលសម្លាប់ឪពុកខ្លួនឯងត្រូវកងសន្តិសុខយកទៅសម្លាប់ចោលដែរ ដោយចោទថាមានការស្ទាក់ស្ទើរមិនហ៊ានបាញ់សម្លាប់ឪពុកខ្លួនដែលជាខ្មាំង ។ ចំណែកឯបងប្រុសម្នាក់ទៀតរបស់ ណាំ ម៉ុន ដែលធ្វើជាអ្នកយាមរួមទាំងម្តាយនិងប្អូនប្រុសគាត់ត្រូវបានចាប់ខ្លួនភ្លាមៗផងដែរ ។ ណាំ ម៉ុន មិនដែលបានជួបមុខអ្នកទាំងនោះម្តងទៀតឡើយ ។

## ម៉ម ណៃ



នៅរសៀលនៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៩ចៅក្រមមានគម្រោងស្តាប់នូវសក្ខីកម្មរបស់សាក្សី ម៉ម ណៃ ដែលជាអតីតអនុប្រធានម្នាក់របស់ ឌុច ។ យ៉ាងណាមិញ ការជំទាស់ពីសំណាក់មេធាវីការពារក្តីស្តីពីបញ្ហាសិទ្ធិប្រឆាំងនឹងការដាក់ពិរុទ្ធភាពលើខ្លួនឯងបានបង្អាក់ដំណើរការនីតិវិធីដើម្បីប្រគល់ពេលវេលាទៅឲ្យ ម៉ម ណៃ ស្វែងរកអ្នកជំនួយផ្នែកច្បាប់ទាក់ទិននឹងបញ្ហាសិទ្ធិរបស់សាក្សីនេះ ។ ម៉ម ណៃ បាននិយាយថា បើទោះបីជាគាត់ចង់បានអ្នកតំណាងផ្នែកច្បាប់ក៏ដោយ ក៏គាត់គ្មានលទ្ធភាពនឹងរកអ្នកតំណាងដែរ ។ ដូច្នេះហើយបានជាគាត់មិនមានអ្នកតំណាងផ្នែកច្បាប់ ។ ជាក់ស្តែង ម៉ម ណៃ មានការទទួលខុសត្រូវលើផ្នែកសួរចម្លើយកម្មាភិបាលជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជាដែលជាប់ឃុំនៅមន្ទីរស-២១ ។ ម៉ម ណៃ អតីតអ្នកសួរចម្លើយកម្មាភិបាលជាន់ខ្ពស់របស់បក្សកុម្មុយនីសកម្ពុជាបានចូលខ្លួនមកធ្វើសក្ខីកម្មនាពេលរសៀលនេះ ប៉ុន្តែគាត់មិនបានផ្តល់នូវសក្ខីកម្មដែលមានសារសំខាន់នោះទេ ។ បន្ទាប់ពីលោកប្រធានចៅក្រមសួរសំណួរ

ទាក់ទិននឹងប្រវត្តិរូបដូចជា ឈ្មោះ អាយុ មុខរបរ និងទីកន្លែងរស់នៅ មេធាវីអន្តរជាតិ ហ្វ្រង់ស័រ រូហ្ស បានលើកឡើងពីការជំទាស់របស់ខ្លួន ។ ខណៈពេលដែលសាក្សីដូចជា ម៉ម ណៃ ត្រូវបានចៅក្រមរំឭកពីពាក្យសម្បថឲ្យនិយាយការពិត សិទ្ធិមិនធ្វើការឆ្លើយតបនិងសិទ្ធិប្រឆាំងនឹងការឆ្លើយដាក់ពិរុទ្ធភាពលើខ្លួនឯង ហ្វ្រង់ស័រ រូហ្ស បានអះអាងថាដោយសារតែចៅក្រមមិនទាន់បានសម្រេចលើសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញាទាក់ទិននឹងការចាត់ទុកការប្រព្រឹត្តឧក្រិដ្ឋកម្មរួមជាមធ្យោបាយនៃការទទួលខុសត្រូវសម្រាប់អង្គជំនុំជម្រះ នោះមានន័យថា ម៉ម ណៃ បានប្រឈមមុខនឹងគ្រោះថ្នាក់ដែលថាគាត់អាចនឹងត្រូវបានកាត់ទោសដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាឬក៏តុលាការជាតិដោយសារតែ ម៉ម ណៃ ជាអ្នកនៅក្រោមបង្គាប់របស់ ឌុច ដែលអាចនឹងប្រព្រឹត្តឧក្រិដ្ឋកម្មរួមជាមួយនឹង ឌុច ។ រូហ្ស បាននិយាយថា លុះត្រាព្រះរាជអាជ្ញាច្រានចោលញត្តិស្តីពីការប្រព្រឹត្តឧក្រិដ្ឋកម្មរួម ទើប ម៉ម ណៃ អាចត្រូវបានជម្រាបពីសិទ្ធិរបស់គាត់ និងអាចអនុញ្ញាតឲ្យពិភាក្សាជាមួយនឹងមេធាវីបាន ។ នាពេលថ្មីៗនេះ ចៅក្រមបានប្រកាសថាខ្លួននឹងចេញសេចក្តីសម្រេចស្តីពីការប្រព្រឹត្តឧក្រិដ្ឋកម្មរួមស្របពេលធ្វើសេចក្តីសម្រេចលើសំណុំរឿង ។ សហព្រះរាជអាជ្ញាអន្តរជាតិ វីល្មៀម ស្មិត បានប្រាប់ចៅក្រមថាយោងតាមវិធានផ្ទៃក្នុងទី២៨.៤ព្រះរាជអាជ្ញាបានជម្រាបដល់សហចៅក្រមស៊ើបអង្កេតក្នុងដំណើរការស៊ើបអង្កេតសំណុំរឿងថាព្រះរាជអាជ្ញានឹងមិនធ្វើការកាត់ទោស ម៉ម ណៃ ឡើយ ។ ហ្វ្រង់ស័រ រូហ្ស បានបន្តលើកឡើងដោយកត់សម្គាល់ឃើញថាសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញាស្តីពីការប្រព្រឹត្តឧក្រិដ្ឋកម្មរួមត្រូវបានបង្កើតឡើងបន្ទាប់ពីមានការធ្វើជាតំណាងចំពោះមុខសហចៅក្រមស៊ើបអង្កេតហើយបន្ថែមលើនេះការធ្វើជាតំណាងដើម្បីការពារ ម៉ម ណៃ ពីសំណាក់ព្រះរាជអាជ្ញានៅ អ.វ.ត.ក មិនបានការពារដល់ ម៉ម ណៃ ពីតុលាការជាតិឡើយ ។ ដោយចាប់អារម្មណ៍លើហេតុផលទាំងនេះ លោកព្រះរាជអាជ្ញាបានគូសបញ្ជាក់យ៉ាងច្បាស់ថាភាគីរបស់ខ្លួនមិនបដិសេធចំពោះការអនុញ្ញាតឲ្យ ម៉ម ណៃ ធ្វើការពិភាក្សាជាមួយនឹងមេធាវីទេ ។ ព្រះរាជអាជ្ញាបានបន្តសង្កត់ធ្ងន់ម្តងទៀតថា ព្រះរាជអាជ្ញានឹងមិនព្យាយាមធ្វើការកាត់ទោស ម៉ម ណៃ នៅចំពោះមុខ អ.វ.ត.ក ឡើយ មិនថាចៅក្រមសម្រេចលើការប្រព្រឹត្តឧក្រិដ្ឋកម្មរួមដោយវិធីសាស្ត្រណាក៏ដោយ ។ ក្រោយពីចៅក្រមបាននាំគ្នាពិភាក្សាមួយរយៈពេលខ្លីមក លោកប្រធានចៅក្រមបានសួរ ម៉ម ណៃ ថាតើគាត់បានពិភាក្សាជាមួយនឹងមេធាវីរបស់គាត់ហើយឬនៅ ។ ម៉ម ណៃ បាននិយាយថាគាត់មិនមានមេធាវីទេនៅពេលនេះ ប៉ុន្តែគាត់បានពន្យល់ប្រាប់ថា គាត់ធ្លាប់បានពិភាក្សាជាមួយនឹងមេធាវីម្នាក់ក្នុងអំឡុងពេលដំណើរការស៊ើបអង្កេតលើសំណុំរឿង ។ លោកប្រធានសួរ ម៉ម ណៃ ថាតើគាត់ត្រូវការមេធាវីទេ ម៉ម ណៃ បានឆ្លើយទៅវិញថា «ខ្ញុំចង់បានមេធាវីដែរ ប៉ុន្តែខ្ញុំមិនមានលទ្ធភាពជួលមេធាវីឡើយ» ។

ក្រោយពីការពិភាក្សាម្តងទៀត លោកប្រធានចៅក្រមបានផ្អាកដំណើរការនីតិវិធីនៅក្នុងថ្ងៃនេះ ។ លោកប្រធានបានកត់សម្គាល់ឃើញថា ចៅក្រមបានទាក់ទងជាមួយនឹងអង្គភាពរបស់ អ.វ.ត.ក ដែលអាចផ្តល់មេធាវីម្នាក់ជូន ម៉ម ណៃ រួចហើយ ប៉ុន្តែគោលបំណងនេះ «មិនអាចសម្រេចបានទេ» ។ លោកប្រធានបន្ថែមទៀតថាដោយសារតែ ម៉ម ណៃ មិនបានពិភាក្សាជាមួយនឹងមេធាវីនិងដោយសារសេចក្តីសន្និដ្ឋានពីកាប្រព្រឹត្តឧក្រិដ្ឋកម្មរួមត្រូវបានប្រគល់ជូនចៅក្រមរួចហើយនោះ ម៉ម ណៃ គួរតែទទួលបានឱកាសពិភាក្សាជាមួយនឹងមេធាវីជាមុនសិនមុននឹងមកធ្វើសក្ខីកម្ម ។ ការដែលថា ម៉ម ណៃ ត្រូវបានអនុញ្ញាតឲ្យមកធ្វើសក្ខីកម្មដោយគ្មានមេធាវីបានបង្កឲ្យមានបញ្ហាខ្លះ ។ បើទោះបីជាសាក្សីផ្សេងទៀតបានធ្វើសក្ខីកម្មដោយគ្មានមេធាវីក៏ដោយ ក៏សាក្សីទាំងនោះគ្រាន់តែជាសាក្សីជនរងគ្រោះដែលជ្រើសរើសមិនធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីដូចជា វ៉ាន់ ណាត ឬដែលមិនបានដាក់ពាក្យស្នើសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីទាន់ពេលដូចជា នង ចាន់ផល ជាដើម ។ សាក្សីទាំងនេះមិនមែនជាអតីតបុគ្គលិកមន្ទីរ ស-២១ ដែលបានចូលរួមក្នុងសកម្មភាពសួរចម្លើយ ធ្វើទារុណកម្ម និងសម្លាប់អ្នកទោសឡើយ នេះគឺជាលក្ខណៈខុសគ្នាដ៏សំខាន់រវាងសាក្សី ។ វិធានផ្ទៃក្នុងទី២៨ចែងពី «សិទ្ធិប្រឆាំងនឹងការដាក់ពិរុទ្ធភាពលើខ្លួនឯងរបស់សាក្សី» និងអនុញ្ញាតឲ្យសហចៅក្រមមេធាវី ឬចៅក្រមផ្តល់ការធានាថា «អ.វ.ត.ក នឹងមិនធ្វើការកាត់ទោសសាក្សីដោយផ្ទាល់ឬប្រយោលឡើយ» បើទោះបីជាការ

កាត់ទោសមានលក្ខណៈត្រឹមត្រូវតាមផ្លូវច្បាប់ក៏ដោយ ។ ប៉ុន្តែ វិធាននេះមិនបានចែងថា សាក្សីក៏នឹងត្រូវបានការពារឲ្យរួចផុតពីការកាត់ទោសដោយតុលាការជាតិដែរ ។ វិធាននេះបានអនុញ្ញាតឲ្យសាក្សីធ្វើសក្ខីកម្មដោយសម្ងាត់ដែលអត្តសញ្ញាណនិងការរៀបរាប់របស់សាក្សីត្រូវបានរក្សាជាសម្ងាត់ ។

យោងតាមវិធាន២៨(៨) សាក្សីអាចស្នើសុំឲ្យមានដំណើរការនីតិវិធីដោយសម្ងាត់មុននឹងឡើងមកធ្វើសក្ខីកម្មបាន ។ ដើមបណ្តឹងរដ្ឋប្បវេណីឡើងមកបង្ហាញខ្លួននៅក្នុងអង្គជំនុំជម្រះដោយមានការស្នើសុំពីមេធាវីរបស់គេ ចំណែកឯសាក្សីវិញត្រូវបានកោះហៅឲ្យមកបង្ហាញខ្លួនដោយចៅក្រមដើម្បីមកធ្វើសក្ខីកម្មពីហេតុការណ៍មួយចំនួន ។ ដើមបណ្តឹងរដ្ឋប្បវេណីមិនត្រូវបានតម្រូវឲ្យស្បថមុនផ្តល់សក្ខីកម្មទេ ។ លើសពីនេះ ដើមបណ្តឹងរដ្ឋប្បវេណីអាចមានសិទ្ធិទាមទារសំណងបាន ។ ខុសពីដើមបណ្តឹងរដ្ឋប្បវេណី សាក្សីត្រូវតែស្បថមុននឹងចូលមកបង្ហាញខ្លួនក្នុងអង្គជំនុំជម្រះ ។ នៅក្នុងសន្និសីទការសែតកាលពីសប្តាហ៍មុន អ្នកនាំពាក្យរបស់ អ.វ.ត.ក បាននិយាយថា ផលប៉ះពាល់នៃភាពខុសគ្នារវាងដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីគឺថា ចៅក្រមមិនបានផ្តល់ «តម្លៃឲ្យស្មើភាពគ្នា» ដល់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសក្ខីកម្មរបស់សាក្សីឡើយ ។ បើទោះបីជា ម៉ម ណៃ មិនមែនជាដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែគ្រាន់តែជាសាក្សីក៏ដោយ ក៏ ម៉ម ណៃ អាចនឹងប្រឈមមុខនឹងគ្រោះថ្នាក់ជាច្រើននៅក្នុងអង្គជំនុំជម្រះនេះ ហើយអាចនឹងត្រូវលើកទឹកចិត្តឲ្យផ្តល់នូវសក្ខីកម្មមិនពិតក៏ថាបានដែរ ។ ប្រសិនបើវាជាការពិតមែនដែលថាសក្ខីកម្មរបស់សាក្សីទទួលបានតម្លៃជាងដើមបណ្តឹងរដ្ឋប្បវេណីមែននោះ វាទំនងណាស់ដែលថាភាពសមហេតុផលនៃលក្ខណៈខុសប្លែកគ្នានេះត្រូវបានសួរដេញដោលបន្ថែមទៀតដូចជានៅក្នុងករណីអតីតកម្មាភិបាលខ្មែរក្រហមដូច ម៉ម ណៃ ជាដើម ។ នៅក្នុងឱកាសសន្និសីទកាសែតមួយទៀតរបស់ អ.វ.ត.ក វ៉ាន់ឌី ឡូបវើន មកពីអង្គភាពអ្នកគាំទ្រអ្នកជំនាញនិងសាក្សី បានពន្យល់រៀបរាប់ពីសេវាកម្មទាំងអស់ដែលតុលាការផ្តល់ជូនសាក្សីដែលរួមមានការនាំសាក្សីមកកាន់អង្គជំនុំជម្រះ រៀបចំបទពិសោធន៍របស់សាក្សីត្រៀមសម្រាប់ការធ្វើសក្ខីកម្មស្ទាបស្ទង់ពីតម្រូវការផ្នែកការពារសុវត្ថិភាពរបស់សាក្សីនិងការផ្តល់ប្រាក់ឧបត្ថម្ភក្នុងអំឡុងពេលផ្តល់សក្ខីកម្មជាដើម ។ លោកស្រីបានបន្តទៀតថា សាក្សីជាច្រើនមានភាពភ័យខ្លាចនឹងសាក្សីដែលជាជនដៃដល់ ដូច្នេះអង្គភាពរបស់លោកស្រីនឹងធ្វើការយកចិត្តទុកដាក់ពីបញ្ហាសុវត្ថិភាពនិងសុខភាពផ្លូវចិត្តរបស់សាក្សី ។ យ៉ាងណាមិញ ការការពារតាមផ្លូវច្បាប់គឺជាបញ្ហាដាច់ដោយឡែកមួយទៀតដែលទាមទារឲ្យមានការយកចិត្តទុកដាក់ខ្ពស់ ។ យោងតាមវិធាន១១ និង១២ ទាំងអង្គភាពគាំពារដើមបណ្តឹងរដ្ឋប្បវេណីនិងអង្គភាពជនរងគ្រោះបានរក្សាបញ្ជីឈ្មោះមេធាវីដែលប្រកបដោយលក្ខណៈសម្បត្តិនិងឆន្ទៈក្នុងការការពារមនុស្សមានស្មារតីខ្សោយ ។ បើទោះបីជាវាទំនងថា មានការពិចារណាជាច្រើនទៅលើការការពារនិងរៀបចំសាក្សីដែលជាជនរងគ្រោះក៏ដោយ ក៏យើងអាចមានភាពងឿងឆ្ងល់ថាតើសិទ្ធិនិងអត្ថប្រយោជន៍នៃសាក្សីជាជនរងគ្រោះត្រូវទទួលបានការកត់សម្គាល់យកចិត្តទុកដាក់ដែរឬទេ ។ ហ្វ្រង់ស័រ រូហ្ស និងចៅក្រមបានចូលខ្លួនការពារ ម៉ម ណៃ នៅក្នុងដំណើរនីតិវិធីក្នុងថ្ងៃនេះ ប៉ុន្តែតើមាននរណាខ្លះដែលបានគិតពីអារម្មណ៍របស់ ម៉ម ណៃ ។ ប្រសិនបើ អ.វ.ត.ក រកបានមេធាវីម្នាក់ដើម្បីផ្តល់ការណែនាំដល់ ម៉ម ណៃ នាពេលយប់នោះ គាត់នឹងរៀបចំខ្លួនឆ្លើយសំណួរដោយសង្ខេបរួចជាស្រេចមុនពេលឡើងមកធ្វើសក្ខីកម្មនាពេលព្រឹកស្អែក ។

### ហ៊ឹម ហ៊ុយ



ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩ ហ៊ឹម ហ៊ុយ បានឡើងផ្តល់សក្ខីកម្ម ។ ហ៊ឹម ហ៊ុយ អាយុ៥៨ឆ្នាំ សព្វថ្ងៃរស់នៅក្នុងស្រុកកោះធំ ខេត្តកណ្តាល ។ ហ៊ឹម ហ៊ុយ រៀបរាប់ថា ឌុច ជាអ្នកជ្រើស

រើសគាត់ឲ្យចូលមកបម្រើការងារនៅក្នុងមន្ទីរស-២១ ដោយមានតួនាទីជាអ្នកយាមប្រកបចូលនិងទទួលខុសត្រូវពេលអ្នកទោសមកដល់ ។ ក្រោយមក ហ៊ីម ហ៊ុយ ទទួលបញ្ជាពី ឌុច តាមរយៈ ហ៊ី ឲ្យចាប់ខ្លួនមនុស្សនៅក្នុងភ្នំពេញ ដោយក្នុងនោះក៏មានជនបរទេសផងដែរ ។ អ្នកទោសដែលត្រូវបានចាប់ចូលក្នុងមន្ទីរស-២១ ត្រូវបានដាក់ខ្នោះជើងនិងបិទមុខ លើកលែងតែអ្នកទោសស្រី ប៉ុន្តែត្រូវដាក់ឃុំនៅក្នុងបន្ទប់ធំមួយជាមួយកូន រួចចាក់សោបិទជិតនៅក្នុងបន្ទប់ ។ លើសពីនេះទៅទៀត គាត់ថែមទាំងដឹងថា អ្នកទោសជាច្រើននាក់ត្រូវបានសម្លាប់ទម្លាក់នៅក្នុងរណ្តៅ ហើយកប់ភ្លាមៗតែម្តង ។ ចំណែកកូនក្មេងប្រមាណហាសិបទៅហុកសិបនាក់ដែលមានអាយុចាប់ពីមួយឆ្នាំទៅប្រាំបីឆ្នាំ ក៏ត្រូវបានសម្លាប់នៅក្នុងមន្ទីរស-២១ដែរ ។

នៅចុងឆ្នាំ ១៩៧៨ ហ៊ីម ហ៊ុយ ត្រូវបានបញ្ជូនទៅមន្ទីរ-២៤ ជាមួយកងសន្តិសុខដទៃទៀត ក្រោយមកពេលដែលវៀតណាមចូលមករំដោះទីក្រុងភ្នំពេញនៅខែមករា ឆ្នាំ១៩៧៩ ទើបគាត់អាចត្រឡប់មកលំនៅឋានបាន ។

ឌុច ទទួលស្គាល់សក្ខីកម្មរបស់ ហ៊ីម ហ៊ុយ ថាបុគ្គលិកមន្ទីរស-២១មែន ប៉ុន្តែសម្តីរបស់ ហ៊ីម ហ៊ុយ មួយចំនួនគឺមិនពិតទេ ។

**ប្រាក់ ខន**



នៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ ប្រាក់ ខន បានឡើងមកផ្តល់សក្ខីកម្មទាក់ទងទៅនឹងមន្ទីរស-២១ ។ ប្រាក់ ខន បានអះអាងថា គាត់ត្រូវបានចាត់តាំងឲ្យធ្វើការនៅមន្ទីរស-២១ មានតួនាទីជាអ្នកយាមនៅក្រៅបរិវេណមន្ទីរចាប់ពីម៉ោងដប់ពីរថ្ងៃត្រង់រហូតដល់ម៉ោងដប់ពីរយប់ ដោយមានកាន់អាវុធផងដែរ ។ នៅទីនោះ អនុប្រធានមន្ទីរស-២១ ហ៊ី តែងតែប្រាប់គាត់មិនឲ្យលួចដេកទេនៅពេលដែលយាមអ្នកទោស ។ គាត់បន្តថា គាត់បានឃើញក្រុមអ្នកយាមគុកបានចាប់កុមារនៅក្នុងមន្ទីរស-២១ដោយនៅក្នុងនោះមានជនជាតិវៀតណាមពីរនាក់និងកូនអាយុប្រហែលជាប្រាំពីរទៅប្រាំខែដែលក្រោយមកក្មេងនោះត្រូវបានអ្នកយាមទម្លាក់ពីលើអគារចុះមកដី ដោយគាត់ជាអ្នកកប់សាកសពក្មេងនោះតែម្តង ។

នៅចុងឆ្នាំ១៩៧៦ ប្រាក់ ខន ត្រូវបានអង្គការចាត់តាំងឲ្យមានតួនាទីជាអ្នកសួរចម្លើយអ្នកទោសវិញ ។ គាត់អះអាងថា នៅពេលគាត់សួរចម្លើយ គាត់មិនដែលហ៊ានធ្វើទារុណកម្មទៅលើអ្នកទោសទេ ទាល់តែសួរដេញដោលអស់ទើបធ្វើរបាយការណ៍បញ្ជូនទៅ ឌុច ។ នៅទីនោះ គាត់ឃើញពេទ្យ រិន និង ទ្រី បានបូមឈាមអ្នកទោសប្រហែលដប់ទៅម្ភៃនាក់ ។ លើសពីនេះទៅទៀត នៅពេលរៀនសូត្រវគ្គនយោបាយ ឌុច តែងតែនិយាយប្រាប់គាត់អំពីរបៀបធ្វើទារុណកម្មទៅលើអ្នកទោសធ្វើបែបណាកុំឲ្យអ្នកទោសស្លាប់ និងកុំឲ្យអ្នកទោសដើររួច ហើយបន្ទាប់មក និយាយប្រាប់ពីវិធីសាស្ត្រមួយចំនួនដោយត្រូវយកម្ជុលទៅចាក់ក្រចករបស់អ្នកទោសដើម្បីសួរចម្លើយឲ្យកាន់តែច្បាស់ ។ ឌុច ក៏ជាអ្នកបញ្ជាឲ្យបូមឈាមអ្នកទោសផងដែរ ។

ចុងបញ្ចប់ ឌុច ទទួលស្គាល់ថា ប្រាក់ ខន ជាបុគ្គលិកនៅក្នុងមន្ទីរស-២១មែន ក៏ប៉ុន្តែ ឌុច បានបដិសេធការរៀបរាប់របស់ ប្រាក់ ខន មួយចំនួន ។

***សេក ដន***

នៅថ្ងៃទី៣ ខែសីហា ឆ្នាំ២០០៩ សេក ដន បានឡើងផ្តល់សក្ខីកម្មទាក់ទងនឹងមន្ទីរស-២១ ។ សេក ដន មានអាយុ៤៨ ឆ្នាំ មានមុខរបរធ្វើស្រែ ។ សេក ដន បានរៀបរាប់ថា នៅដើមឆ្នាំ ១៩៧៨ គាត់ត្រូវបានបញ្ជូនតាមឡានមកធ្វើការនៅស-២១ ដោយមានតួនាទីចែកថ្នាំឲ្យអ្នកទោសនៅតាមអគារ ដែលមួយអគារមានគ្នាពីរនាក់ ។ នៅពេលនោះ ពេទ្យកុមារដែលមកជាមួយគាត់មានគ្នាបីនាក់ គឺឈ្មោះ ធីម, ម៉ុន និង ហូវ ក្រៅពីនេះមានពេទ្យ ប៉ោ និង យឿន ចំណែកពេទ្យស្រីៗមិនមានទេ ។ ស្ថានភាព

អ្នកទោសនៅពេលនោះគឺមានដំបៅពេញខ្លួន និងស្នាមដាំដងដែរ ដោយសារការធ្វើទារុណកម្ម ។ ថ្នាំសម្រាប់ព្យាបាលអ្នកទោសគឺជាថ្នាំអាចម៍ទន្សាយដែលឲ្យអ្នកទោសលេបនៅពេលមានជំងឺរាកគ្រុន និងឈឺក្បាល ។ សេក ដន បន្តថា គាត់បានឃើញអ្នកទោសចំនួនរាប់រយនាក់ឈឺស្លាប់នៅក្នុងគុកហើយសាកសពទាំងនេះត្រូវបានជញ្ជូនយកទៅកប់នៅខាងក្រៅ ឬជិតមន្ទីរស-២១ ។

ឌុច បានរៀបរាប់ថា នៅក្នុងប្រវត្តិមន្ទីរស-២១ គឺមានការសុំក្មេងជំទង់មកពីកំពង់ឆ្នាំងចំនួនប្រហែលជា៤០នាក់ ហើយបើពិនិត្យលើកម្រិតវប្បធម៌របស់សាក្សីដែលមិនចេះអក្សរ គាត់ពិតជាកុមារមកពីកំពង់ឆ្នាំងមែន ។ ប៉ុន្តែបើនិយាយពីភ័ស្តុតាងដែលធ្វើឲ្យគាត់មិនច្បាស់នោះគឺគាត់និយាយពី មិត្តប៉ោ ជាប្រធានអង្គភាពមន្ទីរពេទ្យរបស់គាត់ ព្រោះ ប៉ោ ត្រូវបានចាប់ខ្លួននៅពាក់កណ្ដាលឆ្នាំ១៩៧៦ ឬដើមឆ្នាំ១៩៧៧ទៅហើយ ហើយគាត់ចូលមកនៅឆ្នាំ៧៨ ។ ឌុច មិនទទួលស្គាល់ថា សេក ដន ជាបុគ្គលិកមន្ទីរស-២១ ទេ ពីព្រោះ សេក ដន មិនទាំងស្គាល់ ម៉ម ណៃ ឬសូម្បីតែ ប៉េង ដែលជាប្រធានកងការពារនៅស-២១ក៏មិនស្គាល់ដែរ ។

## សួស ធី



ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៩ សួស ធី បានឡើងធ្វើសក្ខីកម្ម ។ សព្វថ្ងៃមានអាយុ៥៨ឆ្នាំ សួស ធី បានចូលធ្វើជាកងឈ្លបក្នុងឆ្នាំ១៩៧១ ហើយក្រោយមកគាត់បានចូលបម្រើយោធាខ្មែរក្រហម ។ សួស ធី ត្រូវបានផ្លាស់ទៅធ្វើការនៅមន្ទីរស-២១ ដោយមានតួនាទីជាអ្នករៀបបញ្ជីឈ្មោះអ្នកទោសពេលចូលថ្មីនិងមុនពេលយកទៅសម្លាប់ ។ សួស ធី ក៏មាននាទីកត់ត្រាប្រវត្តិរូបរបស់អ្នកទោសផងដែរ ។

## ឡាច មាន



ថ្ងៃទី៣-៤ ខែសីហា ឆ្នាំ២០០៩ ឡាច មាន បានឡើងផ្ដល់សក្ខីកម្មទាក់ទងនឹងមន្ទីរស-២១ ។ ឡាច មាន អាយុ៥២ឆ្នាំ មានមុខរបរធ្វើស្រែ ។ ឡាច មាន អះអាងថា នៅឆ្នាំ១៩៧៥ គាត់ត្រូវបានបញ្ជូនទៅគុកតាខ្មៅដែលជាអតីតពេទ្យឆ្កួតដោយមានមុខងារជាអ្នកយាមអ្នកទោស ។ បន្ទាប់មក គាត់ត្រូវបានបញ្ជូនទៅគុកប៉េហ្ស៊ីដើម្បីយាមអ្នកទោសនៅតាមផ្ទះនិងតាមបន្ទប់ ។ ក្រោយពីបង្កើតមន្ទីរស-២១រួច ឡាច មាន ក៏ទៅធ្វើការនៅទីនោះ ។ គាត់យាមនៅខាងក្នុង គឺយាមអ្នកទោសនៅតាមបន្ទប់ ហើយពេលខ្លះយាមនៅជាន់ទីមួយ ឬទីពីរនៅអគារកណ្ដាល ឬនៅបន្ទប់ធំអគារខាងជើង ចាប់ពីម៉ោង៦ល្ងាចដល់១២យប់ ។ នៅចុងឆ្នាំ១៩៧៨ ឡាច មាន ត្រូវបានបញ្ជូនទៅរៀនពីវិធីសួរចម្លើយ ។ គាត់ស្គាល់ ឌុច, ហ៊ិ, ដួ និង ប៉ូច ប្រធានកងការពាររបស់គាត់ និង សេង ជាប្រធានក្រុម ។ ឌុច ទទួលស្គាល់ ឡាច មាន ថាពិតជាបុគ្គលិកមន្ទីរស-២១ មែន ពីព្រោះ ឌុច ឃើញមានឈ្មោះ ឡាច មាននៅក្នុងបញ្ជីអ្នកសួរចម្លើយ ។

## ខៀវ ចេស

នៅថ្ងៃទី៤ ខែសីហា ឆ្នាំ២០០៩ ខៀវ ចេស ហៅ ពៅ រៀបរាប់នៅក្នុងសវនាការថា គាត់កើតនៅឆ្នាំ១៩៦៣ ។ ខៀវ ចេស បានរៀបរាប់ថា ប្រហែលជាចុងឆ្នាំ១៩៧៦ តាសម្រែង ហៅ តាចាន់ (ម៉ម ណៃ) បានទៅយកគាត់និងកុមារផ្សេងទៀត

មកភ្នំពេញ ។ ក្រោយមកអង្គការបញ្ជូនគាត់ទៅទួលស្លែង ។ នៅទីនោះ ដំបូង ខៀវ ចេស ត្រូវបានចាត់តាំងឲ្យទៅដាំដំណាំនៅខាងលិចទួលស្លែង ក្រោយមកគាត់ទៅយាមអ្នកទោសមានកំហុសស្រាលនៅអគារខាងជើង និងទទួលបន្ទុកថែអនាម័យរបស់អ្នកទោស ។ ខៀវ ចេស បន្តថា នៅពេលអ្នកទោសចង់បត់ជើង គាត់ត្រូវយកកេសគ្រាប់ឲ្យអ្នកទោស ហើយពេលមានធុំក្លិន គាត់ត្រូវបាញ់ទឹកដើម្បីជម្រះក្លិនមិនល្អចេញ ។ គាត់បានឃើញអ្នកទោសក្រោយពីសួរចម្លើយរួច មានរបួសនិងស្នាមឈាមពេញខ្លួន អ្នកខ្លះទៀតមិនដែលឃើញត្រឡប់មកវិញទេ ។

ឌុច បានទទួលស្គាល់ថា ខៀវ ចេស ពិតជាបុគ្គលិកស-២១ មែន ។

## ប៉ើស ម៉ាត់

នៅថ្ងៃទី៤ ខែសីហា ឆ្នាំ២០០៩ ប៉ើស ម៉ាត់ បានឡើងផ្តល់សក្ខីកម្មទាក់ទងនឹងមន្ទីរស-២១ ។ ប៉ើស ម៉ាត់ ឈ្មោះបដិវត្តន៍ហៅ លី ទ្រី កើតនៅឆ្នាំ១៩៦០ បានរៀបរាប់ថា ដំបូងខ្មែរក្រហមបានឲ្យគាត់ទៅលើកទំនប់នៅកំពង់ឆ្នាំង ក្រោយមកត្រូវមនុស្សម្នាក់ឈ្មោះ ណូ មកហៅគាត់ឲ្យទៅភ្នំពេញ ដើម្បីរៀនដោះមីន និងហាត់យុទ្ធសាស្ត្រកងទ័ពនៅសាលាបច្ចេកទេសយោធា ៧០៣ នៅបឹងទំពុន ។ នៅពាក់កណ្តាលឆ្នាំ១៩៧៦ គាត់ត្រូវបានបញ្ជូនទៅគុកតាខ្មៅ ក្រោយមកទៅទួលស្លែងដោយធ្វើជាអ្នកយាម ។ នៅទីនោះ គាត់បានឃើញអ្នកទោសជាច្រើន រួមទាំងជនជាតិខ្មែរនិងវៀតណាមពីរបីនាក់ផងដែលអ្នកទាំងនោះត្រូវគេវាយធ្វើបាបយ៉ាងខ្លាំង ។

ឌុច ទទួលស្គាល់ ប៉ើស ម៉ាត់ ពីព្រោះ ឌុច ពិតជាបានសុំមនុស្សមកពីខេត្តកំពង់ឆ្នាំងមែន ។

## ញ៉ែម អេន

ញ៉ែម អេន មិនបានឡើងផ្តល់សក្ខីកម្មទេ ។ នៅថ្ងៃទី៤ ខែសីហា ឆ្នាំ២០០៩ ញ៉ែម អេន ត្រូវបានក្រឡាបញ្ជីអានកំណត់ហេតុសាកសួររបស់ការិយាល័យស៊ើបអង្កេតថា ញ៉ែម អេន កើតនៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៩ ។ បន្ទាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ញ៉ែម អេន រស់នៅស្រុកកំពង់លែង តំបន់៣១ ក្រោយមកគាត់ត្រូវបានបញ្ជូនមកធ្វើការនៅភ្នំពេញ ។ ញ៉ែម អេន បន្តថា ក្រោយមកអង្គការបញ្ជូនគាត់មកកាន់ខាងបច្ចេកទេសនៅតាខ្មៅដែលមាន ណាត ជាប្រធាន និង ពីន ហៅ តា ពីន អតីតអ្នកកាន់ខាងបច្ចេកទេសនៅកងពល៧០៣ជាអនុប្រធាន ។ នៅទីនោះ គាត់រៀនពីបច្ចេកទេសកងទ័ពជើងគោក និងកងទ័ពអាកាស ។ បន្ទាប់មក គាត់និងកុមារ៤៥នាក់ទៀតដែលមានប្រវត្តិរូបថាជាកុមារឈានមុខត្រូវអង្គការបញ្ជូនទៅរៀនសូត្រនៅប្រទេសចិន ដោយជិះកាមនាវាពីកំពង់សោមទៅ ។ នៅឆ្នាំ ១៩៧៧ គាត់បានមកដល់ស-២១ ធ្វើជាអ្នកថតរូបដែលមាន ឌុច ជាប្រធាន ។ នៅទីនោះ គាត់មានតួនាទីថតរូបអ្នកទោសដែលបញ្ជូនមកមន្ទីរស-២១ ទាំងអស់ ។ ញ៉ែម អេន អះអាងថា រាល់ការបញ្ជារបស់ ឌុច គឺម៉ឺងម៉ាត់ណាស់ ហើយគាត់មិនដែលធ្វើខុសពីបញ្ជានេះទេ ពីព្រោះវាពាក់ព័ន្ធបញ្ហាអាយុជីវិត ។ ជាក់ស្តែងមានអ្នកយាមនិងអ្នកធ្វើការជាច្រើននាក់បានស្លាប់ដោយសារធ្វេសប្រហែសនឹងការងារ ។ ញ៉ែម អេន បន្តថា រាល់ការងារមួយចំនួន ឌុច ជាអ្នកបញ្ជាផ្ទាល់ ហើយមួយចំនួនទៀត សុន សេន បញ្ជាមក ។ ឌុច ជាអ្នកកំណត់ឈ្មោះអ្នកដែលត្រូវសម្លាប់ ។ ហើយគាត់ក៏ធ្លាប់ថតរូបជនបរទេសដែលមិនមែនជាវៀតណាមពីរនាក់ដែរ ។

ឌុច បាននិយាយថា សក្ខីកម្មរបស់ ញ៉ែម អេន ទាក់ទងនឹងការថតរូបនៅស-២១ គឺត្រឹមត្រូវជាមូលដ្ឋាន ។ ប៉ុន្តែ ឌុច បានបដិសេធថា ចំពោះប្រវត្តិទៅរៀននៅស្រុកចិនដែល ញ៉ែម អេន បាននិយាយគឺជារឿងប្រឌិតពីព្រោះនៅឆ្នាំ១៩៧៦ ប៉ុល ពត បានបញ្ជូនក្មួយគាត់ទៅរៀននៅស្រុកចិន មិនមែន ញ៉ែម អេន ទេ ហើយម្យ៉ាងទៀតការដែល ញ៉ែម អេន ថាធ្លាប់ទៅថតនៅផ្ទះរបស់គាត់គឺមិនពិតទេពីព្រោះគាត់ជាបុគ្គលិកតូចតាចនៅផ្នែកថតរូប មិនមានសិទ្ធិចេញទៅណាទេ ។

## ចៀម សឿ

នៅថ្ងៃទី៥ ខែសីហា ឆ្នាំ២០០៩ ចៀម សឿ ឡើងផ្តល់សក្ខីកម្មទាក់ទងនឹងមន្ទីរស-២១ ។ ចៀម សឿ អាយុ៥២ឆ្នាំ បច្ចុប្បន្នប្រកបមុខរបរធ្វើស្រែនិងឡើងត្នោត ។ ចៀម សឿ រៀបរាប់ថា ពីឆ្នាំ១៩៧០-៧៥ គាត់ចូលធ្វើឈ្លបនៅកំពង់ឆ្នាំង ដើម្បីប្រឆាំងនឹងកងទ័ព លន់ នល់ ។ គាត់ជាអ្នកយាមនៅស-២១

ដោយយាមនៅផ្នែកខាងក្រៅនៅខាងលិចមន្ទីរស-២១ ដើម្បីការពារកុំឲ្យអ្នកទោសលួចរត់ ។ ពេលយាម គាត់បានឃើញកងសន្តិសុខដឹកមនុស្សតាមឡានរបស់ស-២១ និងឃើញគេបណ្តើរអ្នកទោសម្នាក់ ដោយសិកកង់ឡានពីលើអ្នកទោសនោះ រួចឃើញភ្លើងឆេះសន្ធោសន្ធៅប្រហែលនៅម៉ោង៦ល្ងាចក្រោយមកទើបភ្លើងរលត់ទៅវិញ ។ ចៀម សឿ បន្តថាគាត់មិនបានឃើញភ្លើង



ឆេះអស់ទេ ពីព្រោះដល់ម៉ោងត្រូវប្តូរវេនរហូតដល់វេនគាត់យាមម្តងទៀត ក៏ឃើញនៅសល់តែសាកសពដែលឆេះរោលផ្សែងខ្មៅ ។

ឌុច បានធ្វើកំណត់សម្គាល់ថា គាត់ពិតជាបានបញ្ជាឲ្យដុតសាកសពមែន ប៉ុន្តែមិនមែនដុតទាំងរស់ទេ ។ ម្យ៉ាងទៀត បើដុតជនបរទេសគឺពីរនាក់ មិនមែនម្នាក់ទេ ដែលការដុតនោះគឺជាបញ្ជារបស់ នួន ជា ។

**ដេវីដ ឆេនដល័រ**



នៅថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៩ ដេវីដ ឆេនដល័រ បាន ឡើងផ្តល់សក្ខីកម្មអំពីការស្រាវជ្រាវរបស់គាត់ទាក់ទងនឹងរបបកម្ពុជាប្រជាធិបតេយ្យ ជាពិសេសមន្ទីរស-២១ ។ ឆេនដល័រ អាយុ៧៦ឆ្នាំ សព្វថ្ងៃរស់នៅប្រទេសអូស្ត្រាលីជាសាស្ត្រាចារ្យប្រវត្តិសាស្ត្រដែលចូលនិវត្តន៍ ។ គាត់ធ្លាប់បានសិក្សាជាច្រើនអំពីប្រវត្តិសាស្ត្រប្រទេសកម្ពុជា ជាពិសេសប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។ គាត់បានសរសេរសៀវភៅពីរក្បាលទាក់ទងនឹងប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ទីមួយគឺ ប្រវត្តិរបស់ ប៉ុល ពត «បងធំទីមួយ» និងទីពីរ «សំឡេងពីមន្ទីរស-២១» ដែលគាត់បានចំណាយពេលបួនឆ្នាំសរសេរសៀវភៅនេះគឺ ពីឆ្នាំ១៩៩៤ ដល់ឆ្នាំ១៩៩៨ ។ នៅក្នុងការសរសេរសៀវភៅនេះ គាត់ធ្វើការស្រាវជ្រាវនិងវិភាគទៅលើឯកសារទាំងអស់ដែលមាននៅបណ្ណសារដ្ឋានស-២១ ដោយប្រុងប្រយ័ត្ននិងបានធ្វើបទសម្ភាសជាមួយ វ៉ាន់ ណាត, ញ៉ែម អេន អតីតអ្នកយាម គកស្រស់ និង ហ៊ឹម ហ៊ុយ ។

គាត់បានបញ្ជាក់បន្ថែមទៅលើអត្ថន័យនៃសៀវភៅ ដែលគាត់បានសរសេរជាក់ស្តែងដូចជាបានសន្និដ្ឋានថា មានការបោសសម្អាតខ្លាំងពីរដង ទីមួយពីខែកញ្ញាឆ្នាំ១៩៧៥ រហូតដល់ខែកញ្ញា ១៩៧៦ ដោយសង្កត់ធ្ងន់ទៅលើអ្នកដែលពាក់ព័ន្ធនឹងរបបចាស់ និងទីពីរពីខែតុលា ឆ្នាំ១៩៧៧ រហូតដល់ចុងបញ្ចប់នៃរបបខ្មែរក្រហមដែលការបោសសម្អាតនេះសំដៅទៅលើកម្មាភិបាលភូមិភាគផ្សេងៗ ។

ឌុច បានធ្វើការសេចក្តីសន្និដ្ឋានថា ការស្រាវជ្រាវរបស់លោក ដេវីដ ឆេនដល័រ ពិតជាមានលក្ខណៈល្អប្រសើរប្រកបដោយគុណធម៌ ហើយការសន្និដ្ឋានជាច្រើនរបស់លោក ឆេនដល័រ ពិតជាត្រឹមត្រូវ ប៉ុន្តែមានចំណុចខ្លះដូចជាលោកបានសរសេរប្រវត្តិរបស់ ឌុច ដោយផ្អែកលើអ្វីដែលបានរៀបរាប់ដោយមនុស្សម្នាក់ដែលអះអាងថាខ្លួនជាមិត្តភក្តិរបស់ ឌុច ពិតជាមិនត្រឹមត្រូវទេពីព្រោះអ្នកទាំងពីរគ្រាន់តែធ្លាប់ឃើញមនុស្សម្នាក់ពីចម្ងាយតែប៉ុណ្ណោះ ។

**ឈុន ផល**

នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៩ ឈុន ផល ឡើងផ្តល់សក្ខីកម្មទាក់ទងនឹងមន្ទីរស-២១ ។ ឈុន ផល មានអាយុ៤៧

ឆ្នាំប្រកបមុខរបរធ្វើស្រែ ។ ឈុន ផល អះអាងថា គាត់បានចូលបដិវត្តន៍នៅក្រោយថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ តាមរយៈមេភូមិចោងម៉ោង ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ។ ក្រោយមកគាត់ត្រូវបានបញ្ជូនទៅសាលាបច្ចេកទេសយោធានៅតាខ្មៅរៀនពីក្បួនយុទ្ធសាស្ត្រយោធានិងក្បួនចាប់ខ្មាំង ។ បន្ទាប់ពីរៀនចប់ គាត់ត្រូវបញ្ជូនបន្តទៅព្រៃសដើម្បីធ្វើស្រែ និងជីកប្រឡាយទឹក ។ នៅចុងបញ្ចប់ គាត់ត្រូវបានបញ្ជូនទៅទួលស្លែងធ្វើជាអ្នកយាមខាងក្នុងគឺយាមអ្នកទោសនិងមើលការខុសត្រូវការពារកុំឲ្យអ្នកទោសចងកសម្លាប់ខ្លួន និងយកបាយឲ្យអ្នកទោស ។ ឈុន ផល បានបញ្ជាក់ថា គាត់បានឃើញក្នុងគុកមានអ្នកទោសដែលជាឈ្លើយសឹកវៀតណាម និងស្ត្រីផងដែរ ប៉ុន្តែមិនសូវជាមានក្មេងតូចៗច្រើនទេ ។

នៅពេលបញ្ចប់សវនាការ ចុងចោទ ឌុច បានទទួលស្គាល់ថា ផល ជាបុគ្គលិកស-២១ ពីព្រោះគាត់ពិតជាមានស្នើសុំក្មេងជំទង់ពីខេត្តកំពង់ឆ្នាំងមែន ។ ឌុច បានរៀបរាប់ថា គាត់ជ្រើសរើសក្មេងៗនៅកំពង់ឆ្នាំងដោយសារតែអ្នកទាំងនោះភាគច្រើនជាជនក្រីក្រ មិនមានចំណេះដឹង ដូច្នេះគាត់ចង់ធ្វើការអប់រំបំពាក់បំប៉នផ្នែកនយោបាយដល់អ្នកដែលមានលក្ខណៈថ្មីថ្មោង ។

***សោម ម៉េត***



នៅថ្ងៃទី១០-១១ ខែសីហា ឆ្នាំ២០០៩ សោម ម៉េត ឡើងផ្តល់សក្ខីកម្ម ។ សោម ម៉េត អាយុ៥១ឆ្នាំ មានមុខរបរធ្វើស្រែចម្ការ ។ សោម ម៉េត បានរៀបរាប់ថា នៅឆ្នាំ១៩៧៣ អង្គការចាត់តាំងឲ្យគាត់ធ្វើជាយោធាស្រុក១៨ ។ នៅឆ្នាំ១៩៧៦ អង្គការបានចាត់តាំងអង្គភាពនិរសារឲ្យទៅយាមអ្នកទោសនៅកន្លែងអគ្គសេនាធិការកងពល៧០៣ ជិតពេទ្យមុនីវង្ស ហៅថា គុកដាំផេង ដែលមាន ណាត ជាប្រធាន ។ នៅទីនោះ សោម ម៉េត បានឃើញ ឌុច, ចាន់, និង ប៉ុន ។ នៅឆ្នាំ១៩៧៧-៧៨ អង្គការបានចាត់តាំងអង្គភាពនិរសារឲ្យទៅយាម នៅមន្ទីរស-២១ ។ ចំណែកគាត់មានតួនាទីយាមអ្នកទោសខាងក្រៅអគារតាមផ្ទះថ្ម ដោយហៅថាគុកពិសេសរបស់ស-២១ មានប្រធានកងឈ្មោះ ហ៊ុយ និង ស្រ៊ី និងប្រធានក្រុមឈ្មោះ ចំរើន ។ គាត់អះអាងថា គាត់បានឃើញអ្នកទោសត្រូវបានដាក់ខ្នោះជើង ឬខ្នោះដៃនៅតាមបន្ទប់ ប៉ុន្តែមិនមានឧបករណ៍ធ្វើទារុណកម្មទេ ។ គាត់បន្តថា គាត់ធ្លាប់ឃើញអ្នកទោសត្រូវបានធ្វើទារុណកម្មយ៉ាងសាហាវឲ្យឆ្លើយសារភាព ដោយពេលនោះ គាត់ឃើញ ទុយ យករំពាត់ផ្តៅមកវាយ និងឆក់អ្នកទោស ។ លើសពីនេះទៅទៀត គាត់ក៏ឃើញ ឌុច ប្រើរំពាត់ផ្តៅវាយអ្នកទោសផងដែរ ។

ឌុច បានរៀបរាប់ថា សោម ម៉េត ជាបុគ្គលិកមន្ទីរស-២១ មែន ។

***ម៉ក់ ស៊ីធីម***

ម៉ក់ ស៊ីធីម មិនបានមកផ្តល់សក្ខីកម្មទេ ប៉ុន្តែតាមកំណត់ហេតុសាកសួររបស់ការិយាល័យស៊ើបអង្កេតចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៧ ម៉ក់ ស៊ីធីម បានរៀបរាប់ថា ហួរ ជាប្រធានក្រុមពេទ្យជាអ្នកចែកថ្នាំឲ្យគាត់បន្តដែលកន្លែងរបស់គាត់ធ្វើការនៅទល់មន្ទីរស-២១ ។ ម៉ក់ ធីម បានអះអាងថា គាត់បានព្យាបាលអ្នកទោសដែលត្រូវបានធ្វើទារុណកម្មដូចជាដំបៅខ្នង ដកក្រចក និងឆក់ខ្សែភ្លើង ។ លើសពីនេះទៅទៀត គាត់ធ្លាប់ឃើញអ្នកទោសដែលត្រូវបានបូមឈាមមានសភាពស្លេកស្លាំងដែលមានចំនួនប្រមាណពី៣០-៤០នាក់ ។

ឌុច បានរៀបរាប់ថា គាត់មិនទាន់ប្រាកដនៅឡើយទេថា ម៉ក់ ស៊ីធីម ជាបុគ្គលិកមន្ទីរស-២១ ព្រោះសក្ខីកម្មរបស់គាត់មិនមានទម្ងន់អ្វីឲ្យគាត់ជឿបានទេ ។

***គយ គេង***

គយ គេង មិនបានមកផ្តល់សក្ខីកម្មទេ ប៉ុន្តែតាមកំណត់ហេតុសាកសួររបស់ការិយាល័យស៊ើបអង្កេតចុះថ្ងៃទី១៧ ខែ

មករា ឆ្នាំ២០០៨ គយ តេង បានរៀបរាប់ថា នៅដើមឆ្នាំ ១៩៧៨ គាត់ត្រូវបានបញ្ជូនមកធ្វើការនៅស-២១ ដោយនៅទីនោះមាន ណាង ជាប្រធានកងរយ ។

គយ តេង បានដឹងថាមានការដឹកអ្នកទោសចេញចូលនិងមានការធ្វើទារុណកម្មលើអ្នកទោសទៀតផង ។ ក្រោយមកប្រហែលជាឆ្នាំ១៩៧៨ គាត់ត្រូវបានបញ្ជូនទៅធ្វើការនៅព្រៃសដែលមាន ហ៊ុយ ជាប្រធាន ។ នៅទីនោះ គាត់បានដឹងថាមានរណ្តៅសម្រាប់សម្លាប់មនុស្ស និងអ្នកទោសដែលត្រូវបញ្ជូនមកទីនេះដោយមានដាក់ខ្នោះដៃនិងចងមុខពេលដឹកចេញពីមន្ទីរផង ។

ឌុច ទទួលស្គាល់ថា គយ តេង ពិតជាបុគ្គលិកមន្ទីរស-២១ ។

## សោម សំអុល និង ជ័យ សូភាព៉

សោម សំអុល មិនបានមកផ្តល់សក្ខីកម្មទេ ប៉ុន្តែតាមកំណត់ហេតុសាកសួររបស់ការិយាល័យស៊ើបអង្កេតចុះថ្ងៃទី១ ខែមេសា ឆ្នាំ២០០៨ បានរៀបរាប់ថា សោម សំអុល ឈ្មោះបដិវត្តន៍ ឃួន សំ កើតថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៥៧ ។ សោម សំអុល បន្តថា គាត់ស្គាល់មន្ទីរស-២១ ដោយសារ វឿន បានឲ្យគាត់នាំសំបុត្រដែលមានចារលើខ្នងថា «ជូនសម មិត្ត ឌុច ប្រធានមន្ទីរស-២១» ។ ផ្ទះរបស់ ឌុច នៅក្រោយរបងមន្ទីរនៅទល់មុខកន្លែងមួយដែលគេនិយមហៅថាស្រះស្រង់ ។ គាត់បានហុចសំបុត្រទៅឲ្យ ឌុច ហើយមានឈ្មោះ ឆេន និង ថាន់ ជាអ្នកទទួលសំបុត្រដោយមានចុះលេខផង ។ បន្ទាប់មក ឌុច បានកាន់ក្រដាសតូចមួយដែល គាត់សរសេរថាបានទទួលសំបុត្រហើយ ។ សោម សំអុល អះអាងថា នៅឆ្នាំ១៩៧៧ ពេលគាត់ត្រូវបានបញ្ជូនឲ្យទៅធ្វើការនៅព្រំដែនរយៈពេលពីរខែ គាត់ដឹងថាមានឈ្លើយសឹកត្រូវបានបញ្ជូនមកមន្ទីរស-២១ ។ នៅឆ្នាំ១៩៧៧ គាត់ធ្លាប់ឃើញ ឌុច ចូលរួមប្រជុំនៅមន្ទីរប-១ជាមួយ អៀង សារី, សុន សេន, នួន ជា និង តាម៉ុក ។ គាត់អះអាងថា គាត់ក៏បាន ចូលរួមមង្គលការរបស់ ឌុច ទៀតផង ។

ជ័យ សូភាព៉ មិនបានមកផ្តល់សក្ខីកម្មទេ ប៉ុន្តែតាមឯកសារចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០៨ បានរៀបរាប់ថា គាត់គឺជាអនុប្រធាននៃអគ្គនាយកដ្ឋានទទួលបន្ទុកសារមន្ទីរខេត្រដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែងនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈដែលបានប្រមូល រៀបចំ និងតម្កល់ឯកសារជាច្រើន រួមមានចម្លើយសារភាពរបស់អ្នកទោស ហ្វីល រូបថត និងឧបករណ៍ផ្សេងទៀតដែលបានប្រទះឃើញនៅជុំវិញបរិវេណមន្ទីរស-២១ ។

ឌុច មិនមានយោបល់អ្វីទាក់ទងនឹងសក្ខីកម្មរបស់លោក ជ័យ សូភាព៉ ទេ ។ ចំណែក សាក្សី ចេក សំ មានឈ្មោះដើមហៅថា សោម សំអុល ឬ ភួន សំអុល ប្រហែលជាមិនមែនជានិសាររបស់ក្រសួងការបរទេសទេ ប៉ុន្តែប្រហែលជាបុគ្គលិករបស់មន្ទីរស-២១នេះ ។

## មាស ប៉េងគ្រី

មាស ប៉េងគ្រី មិនបានឡើងផ្តល់សក្ខីកម្មទេ ។ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់ មាស ប៉េងគ្រី បានរៀបរាប់អំពីសកម្មភាពដែលគាត់បានធ្វើការកាលពីមុននិងក្រោយមកត្រូវបានដក ទៅធ្វើការនៅព្រៃសវិញ ដោយសារគាត់បើកឡានក្រឡាប់ ។

ឌុច ទទួលស្គាល់ថា មាស ប៉េងគ្រី ជាបុគ្គលិកមន្ទីរស-២១ ។

## អ៊ុក ប៊ុនសេង

អ៊ុក ប៊ុនសេង មិនបានឡើងផ្តល់សក្ខីកម្មទេ ។ ប៉ុន្តែតាមកំណត់ហេតុសាកសួររបស់ការិយាល័យស៊ើបអង្កេតចុះថ្ងៃទី២ ខែមេសា ឆ្នាំ២០០៨ អ៊ុក ប៊ុនសេង បានរៀបរាប់ថា គាត់ធ្វើការនៅបឹងជើងឯករយៈពេលពីរខែ ។ នៅទីនោះ គាត់នៅក្នុងកងវរសេនាតូចដែលមានអ្នកត្រូវលត់ដំសរុបប្រហែល១០០នាក់មកពីកងពលលេខ១១២ ដោយបែងចែកជាបីក្រុមមានគ្នាប្រហែល៣០នាក់ ។ អ៊ុក ប៊ុនសេង បានឃើញគេចាប់មនុស្សជារឿយៗហើយមិនដែលឃើញត្រឡប់មកវិញទេ ចំពោះអ្នកដែលចាប់មកពីមន្ទីរស-២១ ។ នៅទីនោះ អ៊ុក ប៊ុនសេង ធ្វើការចាប់ពីម៉ោងពីររសៀលដល់ម៉ោងប្រាំល្ងាច និងយប់ចាប់ពីម៉ោងប្រាំពីរដល់ម៉ោងដប់ពីរយប់ ។ ប៊ុនសេង បន្តថា គាត់ស្គាល់ ឌុច នៅពេលដែលគាត់ចូលរៀននៅស-២១ ហើយបានស្គាល់គាត់កាន់តែច្បាស់នៅពេលដែលគាត់ស្នាក់នៅលើភ្នំក្រវាញ ខេត្តពោធិ៍សាត់ ក្រោយឆ្នាំ១៩៧៩ ។ នៅលើភ្នំនោះ គាត់បានឃើញអ្នកទោសប្រាំមួយនាក់ ត្រូវបានកូនចៅរបស់ ឌុច ចាប់យកទៅសួរចម្លើយក្រោយពី

អ្នកទោសម្នាក់ធ្វើត្រាប់តាមសត្វយំ ដែលមានសំឡេងស្រដៀង ប៉ុល ពត។ បន្ទាប់មក ឌុច បានបញ្ជាឲ្យចាប់អ្នកនោះទៅសួរចម្លើយ ហើយថា «បើឆ្លើយ ឬមិនឆ្លើយបង្ហើយទៅ»។

ឌុច បានរៀបរាប់ថា គាត់មិនដែលស្គាល់ អ៊ុក ប៊ុនសេង ទេ។

## ហ៊ិន អៀម

ហ៊ិន អៀម មិនបានឡើងផ្តល់សក្ខីកម្មទេ។ នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៩ ហ៊ិន អៀម ត្រូវបានក្រឡាបញ្ជីអានកំណត់ហេតុសាកសួររបស់ការិយាល័យស៊ើបអង្កេតធ្វើនៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៧ ថា រយៈពេលបីខែក្រោយពីត្រូវបានចាត់តាំងឲ្យគាត់យាមនៅសាលាព្រះស៊ីសុវត្ថិ គាត់ត្រូវបានដកទៅយាមនៅគុកងងឹតឈ្មោះ គុកដាំដេង វិញ ដែលស្ថិតនៅជិតផ្សារថ្មីជាប់របងពេទ្យមុនីវង្សដែលមានបន្ទប់តូច បន្ទប់ធំ និងមានចម្រឹងដែកជុំវិញ។ គាត់យាមនៅទីនោះប្រហែលជាបីខែ គាត់ក៏ត្រូវផ្លាស់ទៅកន្លែងថ្មី ដោយពេលនោះគាត់ឃើញអ្នកទោសត្រូវបាននាំចេញដាក់ឡាន ដោយចងមុខ និងដាក់ខ្នោះជង។ ពេលមកដល់ទួលស្លែង គាត់មិនឃើញអ្នកទាំងនោះទេ ប៉ុន្តែគាត់ឃើញអ្នកទោសថ្មីត្រូវបានដឹកចូលមកវិញ ដោយដាក់ខ្នោះដៃ និងចងមុខ។

ហ៊ិន អៀម មានតួនាទីយាមនៅខាងក្នុង ពេលខ្លះខាងក្រៅរបង ដោយមានមេក្រុមឈ្មោះ ចំរើន ដែលក្រោយមកត្រូវបានចាប់ខ្លួនដោយសារតែពេលយាមអ្នកទោស គាត់ងងុយដេក ទើបមួយសប្តាហ៍ក្រោយមកគាត់ត្រូវបានចាប់ដាក់ខ្នោះដៃ ចងមុខ និងដាក់ច្រវាក់ដាក់ឃុំនៅក្នុងបន្ទប់តែឯងនៅអគារកណ្តាល។ ក្រោយពីគាត់ត្រូវបានដោះលែង គាត់ត្រូវបានចាត់តាំងឲ្យយាមរបងវិញ។ ពេលយាម គាត់បានឃើញកងសន្តិសុខបណ្តើរអ្នកទោសនៅពេលយប់ ដោយមានដាក់ខ្នោះដៃ និងចងមុខជារៀងរាល់ខែ និងនៅទីនោះឃើញមាន ហ៊ី, ហ៊ុយ និង ឌុច។

ឌុច រៀបរាប់ថា បុគ្គលរូបនេះមិនមែនជាបុគ្គលិកមន្ទីរ ស-២១ទេ។

## ប៊ូ ថុន

នៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ប៊ូ ថុន បានឡើងផ្តល់សក្ខីកម្មទាក់ទងនឹងមន្ទីរស-២១។ ប៊ូ ថុន បានរៀបរាប់ថា មុនឆ្នាំ១៩៧៥ គាត់និងប្តីបានធ្វើដំណើរតាមរថយន្តមួយគ្រឿងត្រឡប់ទៅស្រុកកំណើតនៅស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ដោយមានមិត្តភក្តិរបស់ប្តីគាត់ម្នាក់ជាអ្នកបើកបរ។ នៅពេលមកដល់ពេទ្យលោកសង្ឃ កងទ័ពខ្មែរក្រហមបួននាក់បានឡើងជិះឡានរបស់គាត់ រួចបញ្ជាឲ្យបើកសំដៅទៅឃ្លាំងសាំងពពេលនៅព្រែកព្នៅវិញ។ នៅទីនោះ ក្រោយពី កុយ ធួន នាំប្តីរបស់គាត់ចូលបដិវត្តន៍ ប្តីរបស់គាត់ត្រូវបានចាត់តាំងឲ្យដឹកជយភណ្ឌជាមួយសមាជិកផ្សេងទៀត។ មួយខែក្រោយមក ប្តីរបស់គាត់ត្រូវបានចាត់តាំងឲ្យធ្វើការងារនៅក្រសួងថាមពលមានភារកិច្ចបើករថយន្តដឹកប្រេងសាំងពីកំពង់សោមមកបុស្សីកែវ ភ្នំពេញ ពេលខ្លះដឹកពីភ្នំពេញទៅបាត់ដំបង កំពត និងកំពង់ចាម។ ចំណែកគាត់ត្រូវចាត់តាំងឲ្យធ្វើជាអ្នកដាំបាយឲ្យកម្មាភិបាលក្រសួងថាមពល។



ក្រោយពី កុយ ធួន ត្រូវបានចាប់ខ្លួន មានកម្មាភិបាលម្នាក់មកប្រាប់ ប៊ូ ថុន ថា ប្តីរបស់គាត់ត្រូវអង្គការចាត់តាំងឲ្យទៅដឹកប្រេង។ នៅពេលនោះ ប៊ូ ថុន ដែលទើបសម្រាលបានកូនប្រុសទី៤នៅមន្ទីរពេទ្យព-១ ក៏ត្រូវអង្គការប្រាប់ឲ្យគាត់រៀបចំអីវ៉ាន់ទៅរស់នៅអន្លង់គងដែលមានចម្ងាយប្រាំពីរគីឡូម៉ែត្រពីមន្ទីរ ស-២៤ (គុកព្រៃស)។ ពេលទៅដល់ ប៊ូ ថុន ត្រូវបានថតរូបដើម្បីធ្វើប្រវត្តិរូប រួចបញ្ចូលក្នុងកង១៤។ គាត់បន្តថា អ្នកដែលបញ្ជូនមកទីនេះគឺត្រូវបានចាត់ទុកជាខ្មាំង មិនមានសិទ្ធិសេរីភាពក្នុងការនិយាយស្តីឬដើរទៅក្រៅបរិវេណនេះបានឡើយ គឺរង់ចាំតែថ្ងៃស្លាប់ប៉ុណ្ណោះ។ ចំណែកស្ថានភាពសុខភាពរបស់អ្នកទោសវិញគឺសុទ្ធតែស្គម។ លើសពីនេះទៅទៀត នៅពេលយប់កងការពារតែងតែ

យកពិលមកបញ្ចាំងមើលមុខ រួចយកអ្នកទោសម្នាក់ ឬពីរនាក់ចេញទៅនិងឃើញ ហ៊ុយ មកដឹកមនុស្សមកប្រហែល២០នាក់ចេញទៅបាត់ ប៉ុន្តែមិនដឹងថាអ្នកទាំងនោះត្រូវបញ្ជូនទៅទីណាទេ ។

គាត់បន្តថា គាត់មានកូនបួននាក់ (ប្រុសមួយ និងស្រីបី) ដោយកូនស្រីបងអាយុប្រាំបួនឆ្នាំ កូនស្រីទីពីរអាយុប្រាំមួយឆ្នាំ កូនស្រីទីបី អាយុជិតបួនឆ្នាំ និងកូនប្រុសទីបួនអាយុប្រហែលពីរខែ ។ កូនបីនាក់របស់គាត់ត្រូវបានបញ្ជូនឲ្យទៅរស់នៅក្នុងមណ្ឌលកុមាររបស់អង្គការ ចំណែកកូនអាយុពីរខែអាចអនុញ្ញាតឲ្យរស់នៅជាមួយគាត់បាន ព្រោះកូននៅបៅដោះនៅឡើយ ។ ប៊ូ ថុន ត្រូវបានអនុញ្ញាតឲ្យជួបជាមួយកូនទាំងបីតែក្នុងថ្ងៃទី១០ ឬពេលចូលឆ្នាំប៉ុណ្ណោះ ។ ប៉ុន្តែចាប់តាំងពីគាត់ត្រូវបានបញ្ជូនឲ្យទៅរស់នៅកន្លែងថ្មីមួយទៀត គាត់ក៏បាត់ដំណឹងកូនរបស់គាត់រហូតមកដល់សព្វថ្ងៃនេះ ។

នៅចុងបញ្ចប់នៃសក្ខីកម្មរបស់ ប៊ូ ថុន ឌុច បាននិយាយថា គាត់ព្រមទទួលរាល់ការវិនិច្ឆ័យអំពីឧក្រិដ្ឋកម្មតាមផ្លូវច្បាប់ និងផ្លូវចិត្តនិងសូមឲ្យប្រជាជនកម្ពុជា ក្លាហានចោទគាត់ចុះគាត់អត់ប្រកែកទេ ។ ឌុច បានអះអាងអំពីការស្លាប់របស់ប្តីគាត់ ភោគ ហ៊ិន គឺចេញមកពីគណៈអចិន្ត្រៃយ៍បក្ស ។ ឌុច ជឿថា កូននិងប្តីរបស់ ប៊ូ ថុន ស្លាប់នៅជើងឯកមិនខុសនោះទេ ។

**ម៉ាទីន លើហ៊ឺវ**



នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៩ ម៉ាទីន លើហ៊ឺវ បានមកផ្តល់សក្ខីកម្មព្រោះប្តីរបស់គាត់ឈ្មោះ អ៊ុក កេត ដែលបានស្លាប់នៅមន្ទីរស-២១ ។ ម៉ាទីន លើហ៊ឺវ មានអាយុ៥៧ឆ្នាំ រស់នៅប្រទេសបារាំង មានតួនាទីជាគិលានុបដ្ឋាយិការបស់រដ្ឋ ។ លោកស្រីបានដឹងថា ប្តីរបស់គាត់ត្រូវបានសម្លាប់នៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៧៧ នៅក្នុងមន្ទីរស-២១ ។ អ្នកស្រីបានរៀបការជាមួយ អ៊ុក កេត និងមានកូនពីរនាក់ ដោយពេលនោះ អ៊ុក កេត បានទទួលសញ្ញាបត្រវិស្វករនៅប្រទេសបារាំង ។

គាត់បានបន្តថា គាត់បានជួបលោក អ៊ុក កេត នៅទីក្រុងប៉ារីស ។ នៅឆ្នាំ១៩៧១ ប្តីរបស់គាត់ត្រូវបានផ្តល់តួនាទីជាលេខាទីបីនៃស្ថានទូតកម្ពុជានៅប្រទេសសេណេហ្កាល់ ដោយទទួលការតែងតាំងពីរដ្ឋាភិបាលកម្ពុជា ។ គាត់បានរស់នៅទីនោះក្នុងខែធ្នូ ឆ្នាំ១៩៧១ ។ នៅឆ្នាំ១៩៧៣ និង១៩៧៥ គាត់បានផ្តល់កំណើតឲ្យកូនពីរនាក់ គឺកូនប្រុសឈ្មោះ មករា និងកូនស្រីឈ្មោះ នារី ។ នៅខែមេសា ឆ្នាំ១៩៧៧ ប្តីរបស់គាត់បានទទួលលិខិតឆ្លើយតបពីក្រសួងការបរទេសកម្ពុជាដោយស្នើឲ្យគាត់ត្រឡប់មកកម្ពុជាវិញ ។ គាត់ទាំងបួននាក់បានចាកចេញពីប្រទេសសេណេហ្កាល់តាមយន្តហោះ ហើយមករស់ទីក្រុងប៉ារីស ដោយគាត់បានមករស់នៅជាមួយគ្រួសារឪពុករបស់គាត់ ។ នៅទីក្រុងប៉ារីសបីសប្តាហ៍ ប្តីរបស់គាត់បានមកកាន់ប្រទេសកម្ពុជានៅថ្ងៃទី៧ ខែមិថុនា ឆ្នាំ១៩៧៧ តាមជើងហោះហើរទៅប៉េកាំង ។ ចាប់តាំងពីពេលនោះមក គាត់មិនដែលបានទទួលដំណឹងពីប្តីរបស់គាត់ទេ ។ ដូច្នេះហើយ គាត់បន្តស្វែងរកដំណឹងប្តីរបស់គាត់រហូត ហើយនៅឆ្នាំ១៩៧៩ គាត់បានធ្វើដំណើរមកដល់ជំរំជនភៀសខ្លួនខ្មែរនៅតាមព្រំដែនថៃ ដែលពេលនោះហើយគាត់បានជួប ហ៊ូ តុងហឿន ហើយបានប្រាប់គាត់ថាបានឃើញឈ្មោះរបស់ប្តីគាត់នៅក្នុងឯកសារទួលស្លែង ។

នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ១៩៩១ គាត់បានធ្វើដំណើរទៅមន្ទីរស-២១ ។ គាត់បន្តថា គាត់បានឃើញបញ្ជីមួយដែលមានឈ្មោះប្តីរបស់គាត់នៅទីនោះមែនដែលបញ្ជីនោះមានជនរងគ្រោះជាង៣០០នាក់ ត្រូវបានសម្លាប់ដោយឈ្មោះ អ៊ុក កេត នៅជួរទី៤៣ ។ គាត់បានរៀបរាប់ថា ការអវត្តមានរបស់ អ៊ុក កេត គឺជារឿងដែលមិនអាចទ្រាំបាននោះទេ ។ គាត់បានក្លាយជាស្ត្រីមេម៉ាយត្រូវចិញ្ចឹមកូនតែម្នាក់ឯង ។ កូនៗរបស់គាត់រស់នៅដោយគ្មានឪពុក គ្មានការយកចិត្តទុកដាក់ និងមិនមានការការពារ

និងស្រឡាញ់ថ្នាក់ថ្នម ។

ឌុច បានទទួលស្គាល់ថា ប្រវត្តិរូបរបស់គ្រួសារលោកស្រីវ៉ាជាសច្ចៈធម៌ប្រវត្តិសាស្ត្រ ពីព្រោះវាមានលក្ខណៈអមតៈ ។ សច្ចៈធម៌ពិតប្រាកដមានលក្ខណៈប្លែកពីផ្កាព្រោះផ្កាមានអាយុកាលរបស់វា វាចេះរីក ហើយរោយ ចំណែកសច្ចៈធម៌ប្រវត្តិ-សាស្ត្រអត់ចេះរីករោយទេ វាជាសច្ចៈធម៌ជារៀងរហូត ។

### អ៊ុក នារី



នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៩ អ៊ុក នារី មានអាយុ ៣៧ឆ្នាំបានដាក់ពាក្យជាដើមបណ្តឹងរដ្ឋប្បវេណីដើម្បីប្តឹងទាមទារសំណង និងអំពើព្យសនកម្ម ដែលកើតមានដូចជាខាងសម្ភារៈ ផ្លូវចិត្តនិងផលវិបាកផ្ទាល់អំពីបទល្មើសដែលវាជាព្យសនកម្មកើតឡើងពិតប្រាកដមកដល់សព្វថ្ងៃ ដោយបទឧក្រិដ្ឋដែលចោទប្រកាន់ចំពោះជនជាប់ចោទបានប៉ះពាល់ចំពោះគាត់នៅក្នុងអំឡុងពេលបង្កើតនិងប្រតិបត្តិការរបស់មន្ទីរស-២១ ចាប់ពីថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃ៦ ខែមករា ឆ្នាំ១៩៧៩ ។ អ៊ុក នារី កើតនៅថ្ងៃ១៦ ខែកក្កដា ឆ្នាំ១៩៧៥ នៅប្រទេសសេណេហ្កាល់ នៃទ្វីបអាហ្វ្រិក សព្វថ្ងៃធ្វើការខាងអាកាសចរណ៍បារាំង ។ គាត់បន្តថា ការចងចាំរបស់គាត់ គឺការស្លាប់របស់ឪពុកគាត់ ហើយអ្វីដែលសំខាន់គឺការប្រារព្ធខួបកំណើតផ្សេងៗ ហើយគាត់ប្រាប់ថា កុំឲ្យឡូឡា ហើយកាន់ដៃរបស់គាត់ ។ គាត់បានផ្តល់នូវអារម្មណ៍កក់ក្តៅនិងមានភាពវៃឆ្លាត ។ ការចាប់ដៃរបស់គាត់គឺជាការចាប់ដៃដោយមិនរើសអើងពូជសាសន៍ និងវប្បធម៌ ហើយគាត់ញញឹមនៅលើផ្ទៃមុខគាត់រហូត ។ គាត់រស់នៅជាមួយឪពុករបស់គាត់នៅទីនោះរហូតដល់ថ្ងៃដែលគាត់ទទួលលិខិតឲ្យត្រឡប់មកប្រទេសកម្ពុជាវិញ ។ ការបាត់បង់ឪពុកនេះពិតជាធ្វើឲ្យគាត់មានជំងឺតានតឹងផ្លូវអារម្មណ៍ជាខ្លាំង ជាពិសេសរូបភាពមន្ទីរស-២១ ដែលតម្រូវឲ្យគាត់ត្រូវជួបពេទ្យចិត្តសាស្ត្រដើម្បីព្យាបាល ។

ឌុច បានរៀបរាប់ថា គាត់សូមលំឱនកាយចិត្តទទួលស្គាល់សក្តិកម្មរបស់ អ៊ុក នារី ក្នុងឋានៈជាក្មេងកំព្រាមួយរូបដែលបាត់បង់ឪពុកនៅមន្ទីរស-២១ ។

### ហាមីល រ៉ូបឺត



នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៩ ហាមីល រ៉ូបឺត អាយុ ៤៥ឆ្នាំ កើតនៅកាតានី ប្រទេសញូហ្សេឡែន ។ ហាមីល រ៉ូបឺត បានដាក់ពាក្យបណ្តឹងទាមទារសំណងចំពោះព្យសនកម្មដែលកើតមាននៅក្នុងរបបខ្មែរក្រហម ។ ឪពុករបស់គាត់ឈ្មោះ ម៉ាលអូហិន ហេម៉ូ និងម្តាយ អេស៊្ទ័រ ហេមីល និងមានបងប្អូនបួននាក់ ១) ចន យេរី ២) ចន ហាមីល ៣) រ៉ូបឺត ភីតធឺហាមីល និង៤) ស៊ូមារីហាមីល ។ រ៉ូបឺត គឺជាប្អូនរបស់ យេរី ហាមីល ដែលត្រូវជាប់ឃុំនិងសម្លាប់នៅមន្ទីរស-២១ ។ គាត់បានរៀបរាប់ថា យេរី គឺជាបងប្រុសធំជាងគេបង្អស់នៅក្នុងគ្រួសារ ។ បន្ទាប់ពីរៀននៅមហាវិទ្យាល័យ គាត់បានទៅប្រទេសអូស្ត្រាលី ហើយធ្វើការនៅស៊ីដនីដើម្បីរៀនអំពីជិះទូកក្តោង ។ ក្រោយមក គាត់បានរាប់អានជាមួយជនជាតិកាណាដា ឈ្មោះ ស៊្វីតខ្លាស់ និងរួមគ្នាទិញទូកក្តោងមួយឈ្មោះ ហ៊ុកស៊ីលីឌី ។ នៅពេលនោះ គាត់បានសរសេរសំបុត្រមកផ្ទះផងដែរដើម្បីរៀបរាប់ពីព្រឹត្តិការណ៍ និងរឿងរ៉ាវ

នៃការធ្វើដំណើររបស់គាត់ ។ ក្រោយមកទៀត គាត់ក៏បានរៀបការជាមួយមិត្តនារីរបស់គាត់ឈ្មោះ ហ្គែល ។ លិខិតចុងក្រោយដែលគាត់ទទួលបានពី ឃេរី គឺការធ្វើដំណើរពីប្រទេសសាំងហ្គាពួក្នុងខែកក្កដា ឆ្នាំ១៩៧៨ ។ បន្ទាប់មក គាត់បានអានចម្លើយសារភាពរបស់បងប្រុសគាត់ដោយបញ្ជាក់ថា បងប្រុសរបស់គាត់ត្រូវបង្ខំឲ្យឆ្លើយថាខ្លួនជាភ្នាក់ងារសេ.អ៊ី.អា ។

ហាមីល រ៉ូបឺត អះអាងថា ការបាត់បង់ ឃេរី គឺជារឿងឈឺចាប់ណាស់ ព្រោះធ្វើឲ្យគ្រួសាររបស់គាត់ចាប់ផ្តើមបែកបាក់គ្នា ។ ម្តាយរបស់គាត់តែងតែសម្លឹងមើលទៅសមុទ្រដើម្បីមើលទូកក្តោងរបស់កូនត្រឡប់មកវិញ ។ ក្រោយមក បងទីពីររបស់គាត់ក៏បានសម្លាប់ខ្លួនដោយលោតចុះពីច្រាំងថ្ម ។ ចំណែកឪពុករបស់គាត់វិញបានធ្លាក់ខ្លួនឈឺនិងបានបាត់បង់លទ្ធភាពបំពេញការងារ ហើយម្តាយក៏ធ្លាក់ខ្លួនឈឺដេកលើគ្រែដែរ ដោយសារជំងឺហើមសន្លាក់ដៃសន្លាក់ជើង ថែមទាំងមានអារម្មណ៍ឆេវឆាវទៀតផង ។ ចំណែកប្អូនស្រីរបស់គាត់ឈ្មោះ ស៊ូ ហាមីល ក្រោយពីដឹងដំណឹងអំពីការស្លាប់ ឃេរី នាងមានអារម្មណ៍ភ័យខ្លាច ដែលធ្វើឲ្យមានឥទ្ធិពលទៅលើសេចក្តីសម្រេចចិត្ត និងជម្រើសក្នុងជីវិតរបស់នាង ។ ចំណែកខ្លួនគាត់វិញ ក្នុងរយៈពេល១១ខែដែលបងរបស់គាត់បាត់ខ្លួន គាត់បានប្រើស្រាដើម្បីបំបាត់ទុក្ខ ។

ចុងក្រោយ ឌុច បញ្ជាក់ថា ទទួលស្គាល់អំពីទុក្ខសោករបស់គ្រួសារ ហាមីល ទាំងមូល រួមទាំង គ្រួសារ ដូហ៊ើស ដែលកើតចេញពីមរណភាពរបស់អ្នកទាំងពីរផង ។

## អង់តូញ៉ា ជូឡុង



នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ អង់តូញ៉ា ជូឡុង បានឡើងផ្តល់សក្ខីកម្មទាក់ទងនឹងព្យសនកម្មដែលគាត់បានទទួល ។ អង់តូញ៉ា ជូឡុង អាយុ៥៧ឆ្នាំ សញ្ជាតិបារាំងមានកំណើតនៅប្រទេសបារាំង ធ្វើការនៅកាសែតបារាំង ឡឺចប្រេស ។ ឪពុកគាត់ជាសម្តេចចក្រី ញឹក ជូឡុង ដែលត្រូវបានតែងតាំងដោយសម្តេច សីហនុ នៅឆ្នាំ១៩៤៧ ផ្នែកការពារប្រទេស ។ ម្តាយជាលោក ជំទាវ មាស កេតសមុត្រា ។ អង់តូញ៉ា ជូឡុង មានបងប្អូនស្រីប្រាំពីរនាក់ ។

អង់តូញ៉ា ជូឡុង បានថ្លែងថា បងស្រីរបស់គាត់ឈ្មោះ រង្សុី ជូឡុង និង បងថ្លៃ ឈ្មោះ បុរី ជូឡុង លីសុីម៉ៃ ត្រូវបានសម្លាប់នៅទួលស្លែង ។ គាត់បន្តថា រង្សុី និងប្តីរបស់គាត់មិនចង់ផ្លាស់ប្តូរជីវិតរស់នៅរបស់ខ្លួននៅក្នុងប្រទេសកម្ពុជាទេ ដោយសារតែ រង្សុី បានបម្រើការជាអ្នកអានព័ត៌មានសម្រាប់ស្ថានីយប៉ុស្តិ៍វិទ្យុបារាំង ចំណែកប្តីធ្វើការនៅក្នុងធនាគារមួយ ។ ដោយសារស្ថានភាពនយោបាយធ្ងន់ធ្ងរ រង្សុី ក៏បានបញ្ជូនកូនៗទៅបន្តការសិក្សានៅប្រទេសបារាំង ។ ក្រុមគ្រួសាររបស់ រង្សុី បានទទួលដំណឹងចុងក្រោយបង្អស់នៅខែមីនា ឆ្នាំ១៩៧៥ ។ ក្រុមគ្រួសាររបស់គាត់បានរងទុក្ខដោយសារតែបាត់ដំណឹងរបស់ រង្សុី ។ លើសពីនេះទៅទៀត ដំណឹង អាក្រក់នេះពិតជាបានបំផ្លិចបំផ្លាញ និងបានក្លាយជាភាពតក់ស្លុតមួយប្រចាំគ្រួសាររបស់ត្រកូល ជូឡុង ជាពិសេសកូនៗរបស់ រង្សុី បានកើតរោគតានតឹងផ្លូវចិត្ត ដោយអ្នកចិត្តសាស្ត្របានអះអាងថា អាការៈនេះទាក់ទងនឹងរោគផ្លូវចិត្តដែលកើតឡើងដោយសារការស្លាប់ឪពុកម្តាយ ។

ចុងក្រោយ អង់តូនីញ៉ា ជូឡុង សុំឲ្យអង្គជំនុំជម្រះដាក់ទោស ឌុច ឲ្យសមនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត ។

## ហាវ សុភា

ហាវ សុភា ឡើងផ្តល់សក្ខីកម្មពីការបាត់បង់ឪពុកឈ្មោះ ចាន់ សៀ ដែលត្រូវបានសម្លាប់នៅមន្ទីរស-២១ ។ ហាវ សុភា បន្តថា ការបាត់បង់ឪពុកនេះបានបង្កជាផលលំបាកផ្នែកហិរញ្ញវត្ថុ រូបរាងកាយ និងអារម្មណ៍ផ្លូវចិត្តរបស់គាត់យ៉ាងខ្លាំង ។ ក្តីស្រមៃរបស់ សុភា ជាគ្រូបង្រៀន ត្រូវបានឈប់រៀននៅថ្នាក់ទី៧ ព្រោះម្តាយរបស់គាត់មិនមានប្រាក់ឧបត្ថម្ភដើម្បីឲ្យរៀនបន្ត ។

ម្តាយរបស់គាត់បានទ្រហោយំយ៉ាងខ្លាំងពេលដឹងដំណឹងពីប្តី ។

### សូ សុង



សូ សុង បានដាក់ពាក្យជាដើមបណ្តឹងរដ្ឋប្បវេណីតំណាងឲ្យបងស្រីរបស់គាត់ដែលមានជំងឺ ។ សូ សុង និយាយថា គាត់បានរស់នៅជាមួយបងស្រី និងបងថ្លៃចាប់តាំងពីអាយុប្រាំពីរឆ្នាំ ។ ក្រោយពេលដឹងថា បងស្រីគាត់ដឹងពីការស្លាប់ប្តីរបស់គាត់មក ជីវិតគាត់ចាប់ផ្តើមមានលក្ខណៈទ្រុឌទ្រោម ។ ចុងក្រោយ គាត់បន្តថា បងថ្លៃប្រុសរបស់គាត់គឺជាប្តីដ៏ល្អ ឪពុកដ៏ល្អ និងជាបងប្រុសដ៏ល្អ ។ គាត់ទាំងអស់គ្នានាំគ្នាទ្រហោយំសោកស្តាយដោយសារការបាត់បង់រូបគាត់នេះ ។

### នេត ផល្លី

នេត ផល្លី ឡើងមកផ្តល់សក្ខីកម្មទាក់ទងនឹងបងប្រុសរបស់គាត់ដែលបានស្លាប់នៅមន្ទីរស-២១ ។ នេត ផល្លី បន្តថា បងប្រុសរបស់គាត់បានរងរបួសធ្ងន់នៅក្នុងសមរភូមិកាលពីឆ្នាំ១៩៧៨ ហើយត្រូវបញ្ជូនទៅកាន់មន្ទីរពេទ្យនៅភ្នំពេញ ។ នេត ផល្លី បានទៅសួរសុខទុក្ខបងប្រុសរបស់គាត់ចំនួនពីរលើក ។ គាត់បានតាមស្វែងរកដំណឹងបងប្រុសរបស់គាត់អស់ជាច្រើនខែនៅតែគ្មានដំណឹងអ្វីទាល់តែសោះ ។ ក្រោយពីដឹងថា គាត់ស្លាប់នៅទួលស្លែង ក្រុមគ្រួសាររបស់គាត់សោកសៅចិត្តយ៉ាងខ្លាំង ។ ផល្លី រស់នៅទាំងទុក្ខសោកដោយដឹងថា បងប្រុសស្លាប់នៅមន្ទីរស-២១ ។

### អ៊ឹម ស៊ុន្ទី

នៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៩ អ៊ឹម ស៊ុន្ទី ឡើងផ្តល់សក្ខីកម្មទាក់ទងព្យសនកម្មដែលគាត់បានទទួលរង ។ អ៊ឹម ស៊ុន្ទី អាយុ៧០ឆ្នាំ រស់នៅទីក្រុងភ្នំពេញ១ ។ ប្តីរបស់លោកស្រីឈ្មោះ ភីង គុន បានរៀបការនៅថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ១៩៥៥ ។ ភីង គុន គឺជាសាស្ត្រាចារ្យ ។ លោកស្រី ស៊ីលយី ស្ទូតហ្វីនស៊ី បានឡើងអានប្រវត្តិរឿងរ៉ាវរបស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ឹម ស៊ុន្ទី ដូចតទៅៈ លោកស្រី អ៊ឹម ស៊ុន្ទី បានបាត់បង់ប្តីរបស់គាត់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ហើយក្រោយមក ប្តីរបស់គាត់ត្រូវបានសម្លាប់នៅមន្ទីរស-២១ ។ នៅក្នុងរបបកម្ពុជាប្រជាធិប-តេយ្យ គាត់មិនបានដឹងដំណឹងពីប្តីរបស់គាត់ទេ គ្រាន់តែដឹងថាត្រូវបំបែកក្រុមគ្រួសារប្តីពីប្រពន្ធប៉ុណ្ណោះ ។ ចំពោះកូនស្រីរបស់គាត់ដែលតំណាងឲ្យក្រុមគ្រួសារទាំងមូលផងដែរ រួមទាំងអ្នកស្រី អ៊ឹម ស៊ុន្ទី គាត់បានបាត់បង់ឪពុករបស់គាត់ឈ្មោះ ភីង គុន ដែលជានាយកសាកលវិទ្យាល័យភ្នំពេញ និងមហាវិទ្យាល័យច្បាប់ផង ។ ភីង ហ្គុតស៊ុនថាវី ក៏មិនបានដឹងដែរថា មានរឿងអ្វីកើតឡើងចំពោះឪពុករបស់ខ្លួនដែរ ។ ផលប្រយោជន៍ដែលដើមបណ្តឹងរដ្ឋប្បវេណីមកបង្ហាញខ្លួន និងផ្តល់សេចក្តីថ្លែងការណ៍ពេលនេះគឺដើម្បីរំឭកឡើងវិញអំពីរឿងរ៉ាវប្តីរបស់គាត់ ហើយនិងជាឪពុករបស់គាត់ ដើម្បីស្វែងរកការពិតពាក់ព័ន្ធទៅនឹងជោគវាសនារបស់លោក ភីង គុន ដែលថារហូតដល់ពេលនេះនៅតែមានលក្ខណៈអាថ៌កំបាំង



ទោះបីជាសាក្សីមួយចំនួនបានបំភ្លឺតាមការសួរសំណួរ ដោយរាប់ទាំងការបំភ្លឺរបស់ជនជាប់ចោទផងដែរ ។ ព័ត៌មាននោះនៅតែមិនទាន់បានបង្ហាញឲ្យច្បាស់ដល់ដើមបណ្តឹងរដ្ឋប្បវេណី ហើយនិងក្រុមគ្រួសាររបស់គាត់ ថាតើអ្វីកើតឡើងពិតប្រាកដទៅលើរូបប្តីរបស់គាត់និងជាឪពុករបស់ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ទៀតនោះ ។

### ភីង ហ្គុតស៊ុនថារី

ភីង ហ្គុតស៊ុនថារី អាយុ៥៣ឆ្នាំ មានសញ្ជាតិបារាំង។ ស៊ុនថារី មានឪពុកឈ្មោះ ភីង គុន និងម្តាយឈ្មោះ អ៊ឹម ស៊ុន្នី។ ស៊ុនថារី បានទទួលវិញ្ញាណក្ខន្ធឪពុករបស់គាត់ដែលស្លាប់នៅមន្ទីរ ស-២១។ គាត់និយាយថា ឪពុករបស់គាត់ពាក់ស្លាកលេខ១៧ នៅមន្ទីរស-២១។ ភីង គុន បាន ត្រឡប់មកប្រទេសកម្ពុជាវិញ នៅខែធ្នូ ឆ្នាំ១៩៧៥ មិនមែនស្រឡាញ់ខ្មែរក្រហមទេ តែដើម្បី ជួបជុំគ្រួសារឡើងវិញ។ ក្រោយពេលមកដល់កម្ពុជា ភីង គុន ត្រូវបានចាប់ខ្លួនភ្លាមៗ ហើយត្រូវបានឃុំឃាំងជាច្រើនកន្លែងមុន និងបញ្ជូនមកដល់មន្ទីរស-២១ នៅខែធ្នូ ឆ្នាំ១៩៧៦។ ស៊ុនថារី បាននិយាយថា ការបាត់បង់ឪពុកបានប៉ះពាល់ដល់អារម្មណ៍ផ្លូវ ចិត្តជាខ្លាំង។ គាត់បានបន្ថែម ថាការបាត់បង់ឪពុកនេះគឺជារបួស ដែលមិនអាចព្យាបាលបាន។

### សៀង វ៉ាន់ឌី

សៀង វ៉ាន់ឌី អាយុ៦៣ឆ្នាំ មានស្រុកកំណើតនៅភូមិ ខ្សាច់ទប់ ឃុំជ្រោយបន្ទាយ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ ហើយសព្វថ្ងៃ វ៉ាន់ឌី ជាគ្រូបង្រៀនចូលនិវត្តន៍។ វ៉ាន់ឌី បាត់បង់ ប្អូនប្រុសឈ្មោះ ស៊ាង ដុន ដែលត្រូវបានស្លាប់នៅមន្ទីរស-២១។ វ៉ាន់ឌី បានរៀបរាប់ថា គាត់បានចូលចលនាខ្មែរក្រហមក្នុងឆ្នាំ ១៩៧២ ហើយក្រោយមកឪពុក និងបងប្អូនប្រុសរបស់គាត់ ត្រូវបានបង្ខំឲ្យចូលធ្វើបដិវត្តន៍ដែរ។ ក្រោយឆ្នាំ១៩៧៥ វ៉ាន់ឌី បានត្រឡប់ទៅផ្ទះវិញ ហើយរំពឹងថានឹងជួបជាមួយបងប្អូនប្រុស របស់គាត់ ប៉ុន្តែគាត់មិនបានជួបទេ។ ទើបតែក្រោយពេលរបប ខ្មែរក្រហមដួលរលំ ទើបគាត់ដឹងថា បងប្អូនប្រុសរបស់គាត់ស្លាប់ នៅមន្ទីរស-២១។ វ៉ាន់ឌី មានទុក្ខសោកយ៉ាងខ្លាំង ពេលដែល អានចម្លើយសារភាពរបស់បងប្អូនប្រុសរបស់គាត់។

### ជុំ ស៊ីរ៉ាត់

នៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៩ ជុំ ស៊ីរ៉ាត់ បានឡើងធ្វើ សក្ខីកម្មនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ ស៊ីរ៉ាត់ បាត់បងប្អូនប្រុសពីរនាក់ និងបងថ្លៃស្រីម្នាក់ព្រមទាំងកូនក្នុងផ្ទៃ។ ពីឆ្នាំ១៩៦០ ដល់ឆ្នាំ១៩៦៨ ស៊ីរ៉ាត់ បានទទួលអាហារូបករណ៍ ទៅសិក្សានៅប្រទេសបារាំង។ កាលនោះប្អូនប្រុសរបស់គាត់ក៏ ជាប់អាហារូបករណ៍ទៅសិក្សានៅប្រទេសបារាំងដែរ ប៉ុន្តែគាត់មិន ព្រមទៅទេព្រោះតែគាត់ចង់នៅមើលថែទាំគ្រួសារនៅក្នុងប្រទេស កម្ពុជា។ នៅពេលដែលខ្មែរក្រហមទទួលជ័យជម្នះនៅថ្ងៃ ១៧ មេសា ឆ្នាំ១៩៧៥ ជុំ ស៊ីរ៉ាត់ រស់នៅក្នុងទ្វីបអឺរ៉ុប ដែលក្រោយមក បានទៅនៅប្រទេសបារាំង និងទទួលបានសញ្ជាតិបារាំង។



នៅថ្ងៃទី២៩ ខែតុលា ឆ្នាំ ១៩៧៦ បងប្អូនប្រុសពីរនាក់ ដែលមានអាយុ២៨ និង៣៣ឆ្នាំ និងបងថ្លៃស្រីម្នាក់ត្រូវបាន បញ្ជូនទៅមន្ទីរស-២១។ ក្នុងខែតុលា ឆ្នាំ១៩៩៣ ស៊ីរ៉ាត់ បាន មកដល់ប្រទេសកម្ពុជាជាលើកដំបូង។ ពេលនោះ គាត់បានទៅ ទស្សនាគុកទួលស្លែង ហើយបានឃើញឯកសារមួយបញ្ជាក់ថា បងប្រុសរបស់គាត់ម្នាក់ត្រូវបានយកទៅសម្លាប់នៅក្នុងខែមករា ឆ្នាំ១៩៧៧។ បងប្អូនប្រុសម្នាក់ទៀតរបស់ ស៊ីរ៉ាត់ ក៏បានឃើញ ឈ្មោះនៅក្នុងបញ្ជីចាប់ខ្លួនដែរ។ ជុំ ស៊ីរ៉ាត់ បានរស់នៅក្នុងភាព ឈឺចាប់អស់រយៈពេលជាយូរមកហើយ។ គាត់មានកំហឹងចំពោះ ឌុច យ៉ាងខ្លាំង ហើយគាត់មិនជឿថា ឌុច មានវិប្បដិសារីពិត ប្រាកដទេ។ គាត់ក៏បានរិះគន់ ឌុច ផងដែរ ទាក់ទងទៅនឹងការផ្លាស់ ប្តូរជំនឿពីពុទ្ធសាសនាមកសាសនាគ្រិស្តវិញ ដោយនិយាយថា ឌុច គ្មានបំណងអ្វីក្រៅតែពីចង់លាងបាបប៉ុណ្ណោះ ព្រោះក្នុងពុទ្ធ សាសនា អ្នកសាងអំពើបាបមិនអាចជម្រះកម្មរបស់ខ្លួនបានទេ។ ស៊ីរ៉ាត់ បាននិយាយទៀតថា គាត់មិនអាចលើកលែងឲ្យ ឌុច បាន ទេ។ ឌុច បានសម្តែងនូវការសោកស្តាយចំពោះការបាត់បង់ មនុស្សជាទីស្រឡាញ់របស់ ស៊ីរ៉ាត់។

ឌុច និយាយថា គាត់បានស្គាល់បងប្អូនប្រុសរបស់ ស៊ីរ៉ាត់

ហើយ ឌុច បានចាត់ទុកជាមិត្តភក្តិទៀតផង ។

## អ៊ូ សាវរិត

អ៊ូ សាវរិត បាននិយាយផ្ទាល់តាមរយៈប្រព័ន្ធវីដេអូខុនហ្វឺរ៉ែនពីប្រទេសបារាំង ។ សាវរិត បានបាត់បងប្អូនប្រុសម្នាក់ឈ្មោះ អ៊ូ វិនឌី ស្លាប់នៅចន្លោះឆ្នាំ១៩៧៥-១៩៧៩ នៅមន្ទីរស-២១ ។ សាវរិត តែងតែនឹកបងប្រុស ព្រោះបងប្រុសរបស់គាត់ជាមនុស្សល្អ មនុស្សគំរូសម្រាប់គាត់ ។ សាវរិត បានសញ្ជឹងគិតអស់រយៈពេល៣០ឆ្នាំថា តើបងប្រុសរបស់គាត់រស់នៅបែបណានៅមន្ទីរស-២១ ។ ពេលខ្លះ គាត់ភ្ញាក់នៅពេលយប់ហើយស្រក់ទឹកភ្នែកដោយមិនដឹងខ្លួន ។ សមាជិកគ្រួសារឯទៀតក៏មានអារម្មណ៍ដូចជា សាវរិត ដែរ ។ សាវរិត បានអានសំបុត្ររបស់ក្មួយស្រីរបស់គាត់ដែលរៀបរាប់ពីភាពខ្វះភាពកក់ក្តៅ ។ សាវរិត មិនអាចអភ័យទោសឲ្យ ឌុច បានជាដាច់ខាត ។

## ជុំ នៅ



នៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៩ ជុំ នៅ ជាដើមបណ្តឹងរដ្ឋប្បវេណីបានឡើងធ្វើសក្ខីកម្មអំពីជីវិតរបស់គាត់នៅក្នុងមន្ទីរឃុំឃាំងព្រៃស ឬស-២៤ ។ ជុំ នៅ បានរៀបរាប់ពីការបង្ខំឲ្យធ្វើការជាទម្ងន់ ក្រោយពេលដែលកូនរបស់គាត់បានស្លាប់ទៅ ។ ជុំ នៅ បានបន្តថា ឌុច ធ្លាប់យកកាំភ្លើងខ្លីភ្ជង់ក្បាលគាត់ ពេលគាត់ជួប ឌុច នៅក្នុងព្រៃក្រោយពីរត់គេចចេញពីការវាយលុករបស់កងទ័ពវៀតណាម ។ ទោះបីជាមានការរៀបរាប់ដូច្នេះក្តី ឌុច បានបដិសេធចំពោះការអះអាងរបស់ ជុំ នៅ នេះ ។ ជុំ នៅ បាននិយាយថា គាត់បានរៀបការក្នុងឆ្នាំ១៩៧៦ ដោយមានការព្រមព្រៀងទាំងសងខាង ។ ជុំ នៅ បានស្នើប្រធានរបស់គាត់ដើម្បីអញ្ជើញឪពុកម្តាយមកចូលរួម ប៉ុន្តែត្រូវបានបដិសេធដោយប្រធានគាត់និយាយថា គាត់ជាកូនរបស់អង្គការ ។ នៅក្នុងអង្គសវនាការ ជុំ នៅ បានបន្ទោសខ្មែរក្រហមដែលបណ្តាលឲ្យកូនគាត់ដែលទើបតែសម្រាលស្លាប់ដោយសារតែមិនបានថែទាំត្រឹមត្រូវ ។

## ឈិន ណារី

ឈិន ណារី មានអាយុ៧០ឆ្នាំ រស់នៅទីក្រុងភ្នំពេញ ។ ណារី បានបាត់បង់ប្តីរបស់គាត់ដោយមិនដឹងទៅទីណា ។ មកដល់ឆ្នាំ១៩៨០ ទើបគាត់ដឹងថាប្តីរបស់គាត់ត្រូវបានបញ្ជូនមកមន្ទីរស-២១ ។ ឈិន ណារី បានបែកពីប្តីចាប់តាំងពីក្រោយថ្ងៃជម្លៀស១៧ មេសា ។ ណារី បានរៀបរាប់ថា មុនប្តីរបស់ខ្លួនចេញទៅប្តីគាត់បានប្រាប់គាត់ឲ្យថែខ្លួននិងកូន ។ ណារី គិតថាប្តីរបស់គាត់ពិតជាមិនអាចត្រឡប់មកវិញទេ ។ ក្រោយមក ណារី និងកូនរបស់គាត់ត្រូវបានបញ្ជូនទៅកាន់កន្លែងលត់ដំ ដែលគាត់ត្រូវធ្វើការងារធ្ងន់ធ្ងរ ។ នៅឆ្នាំ១៩៨០ ណារី បានតាមរកប្តីរបស់គាត់ ហើយបានសម្រេចចិត្តចូលទៅមើលគុកទួលស្លែង ។ ណារី បានសន្លប់ពេលដែលគាត់ឃើញរូបថតប្តីរបស់គាត់តាំងនៅទីនោះ ។ តាមឯកសាររបស់មន្ទីរស-២១ បានបញ្ជាក់ថាប្តីរបស់គាត់ត្រូវបាន «កម្ទេច» ។

## តួច មុន្និន

តួច មុន្និន អាយុ៥៨ឆ្នាំ រស់នៅស្រុកចម្ការលើ ខេត្តកំពង់ចាម ។ តួច មុន្និន ជាគ្រូបង្រៀននៅវិទ្យាល័យ ហ៊ុន សែន ចម្ការលើ ។ បងប្អូនជីដូនមួយរបស់ មុន្និន ឈ្មោះ ជា ខន ទទួលសញ្ញាបត្រផ្នែកវិស្វករពីសហភាពសូវៀតបានត្រឡប់មកប្រទេសកម្ពុជាវិញក្រោយពីប្រទេសធ្លាក់ក្នុងកណ្តាប់ដៃខ្មែរក្រហម ហើយត្រូវបានចាប់បញ្ជូនទៅមន្ទីរស-២១ ។ មុន្និន បាននិយាយថា បងប្អូនជីដូនមួយរបស់គាត់ឈ្មោះ ជា ខន ជាកូនទីប្រាំរបស់ម្តាយមីងរបស់គាត់ឈ្មោះ ម៉ៅ ។

## ឈឹម សុធារ៉ា

នៅថ្ងៃទី២៥ ខែសីហា លោក ឈឹម សុធារ៉ា ឡើងផ្តល់សក្ខីកម្មទាក់ទងនឹងអត្តចរិតរបស់ ឌុច ។ ឈឹម សុធារ៉ា មានអាយុ៤៨ឆ្នាំ រស់នៅខណ្ឌ៧មករា ក្រុងភ្នំពេញ ។ លោកបាន

ទទួលសញ្ញាបត្រវេជ្ជបណ្ឌិតនៅឆ្នាំ១៩៩២ ក្រោយមកបានបន្តអនុបណ្ឌិតផ្នែកចិត្តសាស្ត្រនៅសាកលវិទ្យាល័យញូវសៅវែល ប្រទេសអូស្ត្រាលី ។ សព្វថ្ងៃនេះ លោកមានមុខរបរជាវេជ្ជបណ្ឌិតឯកទេសជំងឺផ្លូវចិត្ត និងជានាយកប្រតិបត្តិនៃអង្គការចិត្តសង្គមអន្តរវប្បធម៌កម្ពុជា ហៅកាត់ថា អង្គការធីភីអូ កម្ពុជា និងបង្រៀនផ្នែកចិត្តសាស្ត្រនៅមហាវិទ្យាល័យវេជ្ជសាស្ត្រសុខាភិបាលនៃក្រុងភ្នំពេញ ។ លោកបានប្រកបមុខរបរនេះអស់រយៈពេល ១០ឆ្នាំហើយ ។ គោលបំណងរបស់អង្គការនេះ គឺដើម្បីជួយផ្តល់ការព្យាបាល និងអន្តរាគមន៍ខាងផ្នែកបញ្ហាផ្លូវចិត្តដល់ជនរងគ្រោះក្រោយរបបខ្មែរក្រហម ដូចជាជំងឺធ្លាក់ទឹកចិត្ត វិកលចរិតបាក់ស្បាត និងបញ្ហាផ្សេងៗ ដើម្បីឲ្យពួកគេដោះស្រាយបញ្ហាផ្លូវចិត្ត និងឲ្យពួកគេប្រកបមុខរបរបាន ។ នៅអំឡុងពេលដែលគាត់ធ្វើការស្រាវជ្រាវអំពីជំនាញនេះ គាត់ធ្លាប់ជួបសម្ភាសន៍ជាមួយជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យដែរ ជាពិសេសជនរងគ្រោះនៃមន្ទីរស-២១ ។ បន្ទាប់មក លោកបានរៀបរាប់ពីស្ថានភាពនិងមូលហេតុនៃជំងឺផ្លូវចិត្ត ការភ័យខ្លាច ឬការបាក់ស្បាតរបស់ជនរងគ្រោះតាំងពីមុនរហូតដល់ពេលបច្ចុប្បន្ន ព្រមទាំងឆ្លើយសំណួរជាច្រើនទាក់ទងនឹងផលប៉ះពាល់លើមនុស្សជំនាន់ក្រោយនៃជនទាំងនោះ និងមូលហេតុមួយចំនួនដែលជនរងគ្រោះនៅតែមិនទាន់បានជាសះស្បើយពីជំងឺផ្លូវចិត្ត និងហេតុអ្វីបានជាជនរងគ្រោះមិនព្រមផ្តល់ការអត់ឱនឲ្យជនដៃដល់ ។



ចុងក្រោយ ឌុច បានរៀបរាប់ថា គាត់ទទួលស្គាល់ថា ការស្រាវជ្រាវរបស់លោកវេជ្ជបណ្ឌិត ជាការស្រាវជ្រាវមួយប្រកបដោយលក្ខណៈវិទ្យាសាស្ត្រ ។ គាត់ទទួលខុសត្រូវនៅមន្ទីរស-២១ ក្នុងឋានៈជាប្រធាននៃយន្តការឧក្រិដ្ឋកម្មនេះ និងនៅតែតាំងចិត្តដាច់ខាតថាទទួលខុសត្រូវគ្រប់ឧក្រិដ្ឋកម្មទាំងអស់ដែលកើតមាននៅមន្ទីរស-២១ ទាំងផ្លូវច្បាប់ និងផ្លូវចិត្ត ។ គាត់បានរៀបរាប់ថាគាត់មិនមែនជាអ្នកទទួលខុសត្រូវលើមន្ទីរសន្តិបាលទូទាំងប្រទេសទេ ក៏ប៉ុន្តែជាបេក្ខជនម្នាក់របស់របបកម្ពុជាប្រជាធិបតេយ្យ ។ គាត់បានបន្តថា នៅពេលដែលប្រឈមមុខនឹងជនរងគ្រោះ ស្ត្រីមេម៉ាយ កុមារកំព្រា ហើយពួកគេអញ្ជើញមកទីនេះថ្កោលទោសគាត់ ចង្អុលគាត់ គាត់ពិតជាបានធូរចិត្តណាស់ ។

## សាក្សីជនជាប់ចោទ ឌុច

ឌុច បានអះអាងប្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាថា គាត់បានលះបង់អាយុជីវិតរបស់គាត់ដើម្បីប្រទេសជាតិនិងប្រជាជន «ការចូលរួមរបស់ខ្ញុំនៅក្នុងមនោគមន៍វិជ្ជារបស់បក្សកុម្មុយនីស្តកម្ពុជា បូជាជីវិតដើម្បីប្រជាជនរបស់ខ្ញុំ មិនមែនដើម្បីប្រព្រឹត្តបទឧក្រិដ្ឋនោះទេ...» ។ ដូចគ្នាទៅនឹងកម្មាភិបាលថ្នាក់ក្រោម ឬប្រហែលជាថ្នាក់លើរបស់ខ្មែរក្រហមដទៃទៀតដែរ ឌុច បានចូលរួមបដិវត្តន៍កុម្មុយនីស្តខ្មែរក្រហម ដើម្បីរំដោះប្រទេសពីការត្រួតត្រារបស់បរទេសឈ្លានពាន ស្របពេលដែលលទ្ធិកុម្មុយនីស្តកំពុងរីករាលដាលទូទាំងពិភពលោក ។ ឌុច បានរៀបរាប់ថា «សូម្បីតែបណ្តាប្រទេសអ៊ីស្លាម និង អឺរ៉ុបខាងកើតក៏ទប់នឹងកុម្មុយនីស្តមិនបានដែរ ។ ដូច្នេះ ថ្ងៃក្រោយ កុម្មុយនីស្តនឹងឈ្នះ» ។ គំនិតនិងស្ថានភាពនៅពេលនោះជំរុញទឹកចិត្ត ឌុច ឲ្យស្រឡាញ់លទ្ធិកុម្មុយនីស្ត ។ ការគិតទុករបស់ ឌុច មិនជាខុសឆ្គងទេសម្រាប់ស្ថានការណ៍ពិភពលោកនាចុងទសវត្សរ៍៦០ ។ ឌុច រៀបរាប់ថាគាត់ស្រឡាញ់លទ្ធិកុម្មុយនីស្តដោយសារឥទ្ធិពលពីរយ៉ាង ។ ទីមួយដោយសារឥទ្ធិពលចិននៅកម្ពុជាកាន់តែខ្លាំងឡើងៗ និងទីពីរដោយសារស្ថានភាពនៅក្នុងប្រទេស ។ ស្ថានភាពចិននៅស្រុកស្ទោង ជាស្រុកកំណើតរបស់ ឌុច ដែលបានប្រែក្លាយពីភាពក្រីក្រមកជាអ្នកមានទ្រព្យសម្បត្តិគ្រប់គ្រាន់បានជំរុញទឹកចិត្ត ឌុច ឲ្យស្រឡាញ់លទ្ធិចិន ។ ឌុច និយាយថា «នេះដោយសារគុណរបស់ម៉ៅ សេទុង» ។ ការមកធ្វើទស្សនកិច្ចរបស់នាយករដ្ឋមន្ត្រីចិន ជូអេនឡាយ នៅកម្ពុជាក្នុងឆ្នាំ១៩៥៦ បានធ្វើឲ្យ ឌុច ងប់ងល់នឹង

ចិនកាន់តែខ្លាំងឡើងៗ ។ ស្ថានភាពក្រីក្រគោកយ៉ាករបស់ជីតាគាត់បានធ្វើឲ្យ ឌុច តាំងចិត្តថាគាត់នឹងពុះពារនិងជួយប្រជាជននៅថ្ងៃអនាគត ។ ឌុច ចាំសម្តីរបស់ជីតាគាត់ដែលនិយាយថា «អ្ហែង រៀនពូកែ ដល់ធំឡើងច្បាស់ជាជិះជាន់អញហើយ» ។ ឌុច មានការរំជួលចិត្តនឹងភាពជិះជាន់របស់វណ្ណៈសង្កមតាមរយៈពាក្យពេចន៍របស់ជីតាគាត់ណាស់ ។

នាទសវត្សរ៍៦០ មានការតាមចាប់ខ្លួនអ្នកចូលរួមក្នុងការបាចគ្រាក់ដោយចោទប្រកាន់ លន់ នល់ ថាជាជនក្បត់ជាតិចង់ធ្វើរដ្ឋប្រហារទម្លាក់សម្តេចសីហនុ ។ ឆាយ គឹមហ៊ំ ដែលជាអ្នកអប់រំ ឌុច ឲ្យចូលបដិវត្តន៍កុម្មុយនីស្តត្រូវបានចាប់ខ្លួន ។ បន្ទាប់ក្រោយមកក៏មានការចាប់ខ្លួនជនល្បីៗជាច្រើនទៀតដែលបានចូលរួមក្នុងការបាចគ្រាក់ដូចជា យឹង ជួន ជាដើម ។ ឃើញសភាពបែបនេះ ឌុច ក៏ចូលបដិវត្តន៍ដែរ ។ ឌុច បានរៀបរាប់ថា គាត់ដឹងខ្លួនថាមិនអាចដកខ្លួនរួចពីបដិវត្តន៍បានទេ ប្រសិនជាចូលក្នុងបដិវត្តន៍ហើយ «ខ្ញុំដឹងថា ប្រសិនបើខ្ញុំចូលក្នុងចលនាបដិវត្តន៍របស់បក្សកុម្មុយនីស្ត ខ្ញុំដកខ្លួនមិនរួចទេ ក៏ប៉ុន្តែខ្ញុំជឿស៊ប់ណាស់ថា បដិវត្តន៍សង្គ្រោះប្រជាជន» ។

ក្រោយពេលដែលគាត់ចូលធ្វើជាគ្រូបង្រៀន ឌុច បានចំណាយស្ទើរតែទាំងអស់នៃប្រាក់ខែរបស់គាត់សម្រាប់អង្គការបដិវត្តន៍ ។ ប៉ុន្តែ ឌុច មានមោទនភាពខ្លួនឯងដែលបានធ្វើបែបនេះដោយគិតថាខ្លួនបានប្រគល់អ្វីៗទាំងអស់ជូនបដិវត្តន៍ ។ រដ្ឋាភិបាលមិនបានដឹងពីការលាក់ការណ៍សម្ងាត់របស់ ឌុច និងបក្សពួករបស់គាត់ទេមុននឹងគាត់សម្រេចចិត្តរត់ចូលព្រៃដើម្បីធ្វើបដិវត្តន៍ដោយពេញលេញ ។

នៅក្នុងអង្គសវនាការ ឌុច បានរៀបរាប់ថា គាត់គឺជាអ្នកទទួលខុសត្រូវក្នុងជួរបដិវត្តន៍នៅស្គន់ កំពង់ចាម ចំណែកនៅអង្គតាសោមមាន ហ៊ូ ណារ នៅកំពង់ធំ មាន អ៊ិន លន ហៅ ណាត និង សូ គឹមអាន ។ ឌុច បានរៀបរាប់ថា កាលនោះគាត់គឺជាប្រធានរបស់អ្នកទាំងបួននេះដោយសារគាត់ជាមនុស្សដែលចេះទ្រឹស្តីច្រើនជាងគេ ។ ឌុច បានបន្តថា គាត់ពេញចិត្តជាខ្លាំងពេលដែលគាត់អានសៀវភៅមួយរបស់ ម៉ៅ សេទុង ដែលអះអាងថា «សេចក្តីស្នេហាប្រជាជនពិតប្រាកដ គឺត្រូវប្រគល់លទ្ធភាពអនុវត្តផ្តាច់ការទៅឲ្យវណ្ណៈអធន» ។ ឌុច បានរៀបរាប់ថា «យើងអនុវត្តផ្តាច់ការទៅលើពួកចោរលួច ចោរប្លន់ និងអ្នកដុតបំផ្លាញបង្កើតអគ្គិភ័យ ហើយនិងទៅលើពួកចងការទុច្ចរិត» ។ ដោយសារឃើញមានការជិះជាន់ពីសំណាក់អ្នកមានអំណាចខ្លះ ឌុច បានចូលរួមធ្វើបដិវត្តន៍ក្នុងគោលបំណងបំបាត់វណ្ណៈជិះជាន់ទាំងនោះ ។ ឌុច បានចូលបដិវត្តន៍ក្នុងឆ្នាំ១៩៦៤ ។ មកដល់ឆ្នាំ១៩៦៧ នៅក្នុងកិច្ចប្រជុំសម្ងាត់មួយនៅម្តុំផ្សារទួលទំពូង កាំង ហ្គេកអ៊ាវ ត្រូវបានដូរទៅជា ឌុច វិញដើម្បីលាក់ការណ៍សម្ងាត់ ។ ឌុច បានរៀបរាប់ថាគាត់សម្រេចយកឈ្មោះនេះដោយសារតែឈ្មោះនេះមានលក្ខណៈជាខ្មែរ ហើយឈ្មោះ ឌុច នេះគឺជាឈ្មោះរបស់ជាងបដិមាម្នាក់ដែលបានធ្វើព្រះពុទ្ធរូបនៅវត្តពោវើយ ។ ម្យ៉ាងទៀត ឈ្មោះ កាំង ហ្គេកអ៊ាវ គឺ ជាឈ្មោះចិន ។

មកត្រឹមដើមឆ្នាំ១៩៧៣ ទំនាក់ទំនងរវាងខ្មែរក្រហម និងវៀតណាមមានលក្ខណៈរង្គោះរង្គើណាស់ទៅហើយដោយសារតែវៀតណាមខាងជើងព្រមធ្វើការចរចាជាមួយអាមេរិកដែលខ្មែរក្រហមគិតថាអាមេរិកគឺជាសត្រូវខាងក្រៅធំជាងគេ ។ ខ្មែរក្រហមបានបន្ថយឥទ្ធិពលពីវៀតណាមជាបណ្តើរៗ តែទំនាក់ទំនងមិនបានផ្តាច់ទាំងស្រុងទេ ។ ឌុច បានរៀបរាប់ប្រាប់អង្គជំនុំជម្រះថា ខ្មែរក្រហមមានគោលការណ៍ប្រមូលផ្តុំប្រជាជននៅក្នុងតំបន់រំដោះដើម្បីក្តាប់សភាពការណ៍ប្រជាជន និងដើម្បីគ្រប់គ្រងទិន្នផលស្រូវដោយការពារមិនឲ្យជនជាតិវៀតណាមមានលទ្ធភាពទិញស្រូវអង្ករពីកសិករខ្មែរដើម្បីទៅចិញ្ចឹមទ័ពរបស់ខ្លួនបានឡើយ ។

**ហ្វ្រង់ស័រស៊ីរ៉ូនី ហ្គៀលបូ និង កា ស៊ុនបូណាត**



នៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៩ ចិត្តវិទូបារាំង ហ្វ្រង់ស័រស៊័រនី ហ្គៀលបូ និងគ្រូពេទ្យចិត្តវិទ្យាជនជាតិខ្មែរលោក កា ស៊ុនបូណាត បានឡើងមកស្បថនៅចំពោះមុខអង្គជំនុំជម្រះ ។ លោកស្រី ហ្គៀលបូ និង លោក កា ស៊ុនបូណាត ឡើងនិយាយពីស្ថានភាពផ្លូវចិត្តរបស់ ឌុច ដោយផ្អែកទៅលើបទសម្ភាសន៍ជាមួយ ឌុច ចំនួនដប់បីលើកដែលមួយលើកៗចំណាយពេលអស់ប្រមាណជាបីម៉ោងក្នុងរវាងខែកុម្ភៈនិងមីនាឆ្នាំ២០០៨ ។ លោកស្រី ហ្គៀលបូ និង លោក ការ ស៊ុនបូណាត បានរៀបរាប់ថា ឌុច មិនមានបញ្ហាផ្លូវចិត្តធ្ងន់ៗទេ ។ គាត់បានធ្វើអ្វីដែលគាត់ធ្លាប់ធ្វើដោយសារតែគ្មានជម្រើស ។ កាលពីពេលដែលគាត់នៅជាប្រធានមន្ទីរស-២១ ឌុច បានផ្តាច់ខ្លួនពីអ្នកឯទៀត ហើយគេចវេះពីស្ថានភាពមួយចំនួនដើម្បីកុំឲ្យឃើញនិងដឹងពីរឿងរ៉ាវនៅក្នុងគុកនោះ ។ លោកស្រី ហ្គៀលបូ និង លោក ការ ស៊ុនបូណាត ក៏បាននិយាយផងដែរអំពីការផ្លាស់ប្តូរសាសនារបស់ ឌុច ទៅកាន់ជំនឿគ្រិស្តសាសនាវិញ ដោយមានមតិខ្វះនិយាយថា ទង្វើរបស់ ឌុច គឺគ្មានអ្វីក្រៅពីចង់រំដោះខ្លួនចេញពីបាបកម្មទេ បន្ទាប់ពីមើលឃើញថា ខ្លួនធ្លាប់សាងអំពើបាបជាមួយអ្នកទោស ។ នៅក្នុងអង្គសវនាការ ឌុច បានធ្វើការសុំទោសជាសាធារណៈដល់ពលរដ្ឋកម្ពុជា ជាទូទៅដែលទង្វើនេះត្រូវបានចោទប្រកាន់ដោយភាគីរដ្ឋប្បវេណី ថាជាការសុំទោសបោកប្រាស ។ ទោះបីជា ឌុច ធ្លាប់ប្រព្រឹត្តអំពើឃោរឃៅនៅមន្ទីរស-២១ក៏ដោយ ក៏មកដល់ពេលនេះ ឌុច នៅតែមានស្ថានភាពផ្លូវចិត្តជាប្រក្រតីដែរ ។ លោកស្រី ហ្គៀលបូ បាននិយាយថា «កំឡុងពេលធ្វើកោសល្យវិច័យចិត្តសាស្ត្រ ឌុច គ្រាន់តែមានបញ្ហាឈឺក្បាល និងអស់កម្លាំងប៉ុណ្ណោះ» ។ ការផ្លាស់ប្តូរឈ្មោះរបស់គាត់ពីឈ្មោះដើមមកឈ្មោះបដិវត្តន៍ក៏អាចទាក់ទងនឹងបញ្ហាចិត្តសាស្ត្រដែរ ។ លោកស្រី ហ្គៀលបូ បាននិយាយថា «ការជ្រើសរើសឈ្មោះ និងអត្ថន័យដើរតួនាទីយ៉ាងសំខាន់នៅក្នុងការបង្កើតអត្តសញ្ញាណនិងកម្លាំងពលំរបស់បុគ្គល ព្រមទាំងជំនឿទុកចិត្តលើខ្លួនឯង» ។ លោកស្រីបានមានប្រសាសន៍ថា ឌុច មិនដែលពេញចិត្តនិងឈ្មោះ «យឹម ដាវ» ទេ ព្រោះឈ្មោះនេះគឺមានន័យថា «សម្លឹក ចាស់គំរីល» ។ ឈ្មោះ «យឹម ដាវ» នេះ គឺជាឈ្មោះ ដែលឪពុករបស់ ឌុច បានដូរពី «កាំង ដាវ» ដែលជាឈ្មោះកំណើតរបស់ ឌុច ។ អ្វីដែល ឌុច បានធ្វើមកលើអ្នកទោសនៅមន្ទីរស-២១គឺអ្វីដែលលោកស្រីហៅថា «ភាពមនោសញ្ចេតនា» ដែលជាការមិនយល់ និងមិនគិតគូរពីបុគ្គលផ្សេងទៀត ។ លោក ការ ស៊ុនបូណាត ក៏បានរៀបរាប់ផងដែរថា ទោះបីជា ឌុច ធ្លាប់ទទួលរងនូវភាពភ័យខ្លាចដែលអាចយាយីដល់ជីវិតរបស់គាត់មុនចូលបដិវត្តន៍ក៏ដោយ ក៏ពេលនេះ ឌុច មិនមានបញ្ហាផ្លូវចិត្តធ្ងន់ធ្ងរដែលអាចប៉ះពាល់ដល់ដំណើរការកាត់ទោសនេះបានទេ ។

## ស៊ូ សាត



នៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០០៩ ស៊ូ សាត បានមកផ្តល់សក្ខីកម្មនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ស៊ូ សាត អាយុ៦៦ឆ្នាំ សព្វថ្ងៃរស់នៅភូមិពោធិ៍ស្វាយ សង្កាត់ស្រយូវ ក្រុងស្ទឹងសែន គឺអតីតមិត្តរួមថ្នាក់របស់ ឌុច ។ សព្វថ្ងៃ សាត ជាគ្រូចូលនិវត្តន៍ ។ សាត អះអាងថា ឌុច គឺជាមនុស្សចិត្តល្អម្នាក់កាលពីគាត់ទាំងពីរជាមិត្តរួមថ្នាក់នឹងគ្នានៅថ្នាក់ទី៤នឹងទី៣ ។ សាត ធ្លាប់បានរៀននៅក្នុងក្លឹបសិក្សារួមគ្នាជាមួយ ឌុច អស់រយៈពេលពីរឆ្នាំក្នុងចន្លោះឆ្នាំសិក្សា ១៩៥៩-១៩៦១ ។ សាត បានអធិប្បាយចរិតរបស់ ឌុច ថា «ស្លូតបូត ស្មោះត្រង់ ចេះយោគយល់គ្នាមានចិត្តទូលាយនិងជាសិស្សពូកែនៅក្នុងថ្នាក់ គាត់មិនដែលលាក់លៀមចំណេះដឹងរបស់គាត់ទេ ពេលដែលរៀននៅក្នុងក្លឹបជាមួយគ្នា» ។ សាត បានបន្ថែមទៀតថា «ប៉ុន្តែ ឌុច មិនសូវមានមិត្តភក្តិច្រើនទេ» ។ សាត បានសរសើរ ឌុច ថា «គាត់ជាមនុស្សមិនដែលខ្វល់ខ្វាយនឹងរឿងស្រីញី» ឡើយ ។ ជាសិស្សដ៏ល្អម្នាក់នៅក្នុងថ្នាក់ ឌុច

តែងតែមករៀនទៀងទាត់ពេលវេលាជានិច្ច ហើយក៏មិនដែលគេចម៉ោងសិក្សាដែរ ។ សាត មិនដែលមានទំនាក់ទំនងជាមួយ ឌុច ទេតាំងពីរៀនចប់ថ្នាក់ទីបី ក្នុងឆ្នាំ១៩៦១មក ។ ពេលសួរថា តើមានស្គាល់ផ្ទះ ឬដែលទៅលេងផ្ទះរបស់ ឌុច ទេកាលជាមិត្តរួមថ្នាក់នឹងគ្នា សាត បានឆ្លើយថា គាត់មិនដែលស្គាល់ផ្ទះរបស់ ឌុច ទេ អ្វីដែលគាត់ស្គាល់គឺថា ឌុច មានឪពុកជាមេការនៅឡូតិ៍នេសាទមួយ ។ សំណួរចំពោះ សាត មួយទៀតគឺចង់ដឹងពីទស្សនៈវិស័យរបស់គាត់កាលពីគាត់នៅក្មេង តែ សាត បានបកស្រាយថា គាត់មិនដឹងពីចិត្តគំនិតរបស់ ឌុច ទេដោយសារកាលនោះគាត់គិតតែពីរៀនសូត្រនៅតាមសាលារៀនប៉ុណ្ណោះ ។ លោក និល ណុន ប្រធានអង្គជំនុំជម្រះបានសួរទៅ សាត ថាតើមានបំណងចង់ឃើញមុខជនជាប់ចោទដែរឬទេ? សាត ឆ្លើយថាគាត់ចង់ជួបតែមិនអាចលើសពីដប់នាទីទេ ។ លោកប្រធានអង្គជំនុំជម្រះបានយកសំណើនេះមកពិចារណា ហើយ សាត ក៏អស់តួនាទីរបស់ខ្លួននៅតុលាការទៅ ។ សាក្សីម្នាក់ទៀតបានចូលមកបំភ្លឺបន្ទាប់ពី ស៊ូ សាត ។

**ទេព សែម**



នៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០០៩ ទេព សែម បានមកផ្តល់សក្ខីកម្មនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ទេព សែម មានអាយុ៦១ឆ្នាំ រស់នៅភូមិតាសែន ឃុំសូទិព ស្រុកជើងព្រៃ ។ ទេព សែម ជាអតីតសិស្សរបស់ ឌុច នៅសាលារៀនស្រុកជើងព្រៃកាលពីឆ្នាំសិក្សា១៩៦៥-១៩៦៦ ។ សែម មានទំនាក់ទំនងជាមួយ ឌុច តាំងពីពេលនោះមករហូតដល់ឆ្នាំ១៩៦៨ ក្រោយពេលដែលអ្នកទាំងពីរបានបែកគ្នា ។ ឌុច ជាអតីតគ្រូគណិតវិទ្យារបស់ សែម នៅឆ្នាំ១៩៦៥-១៩៦៦ ។ តែមួយឆ្នាំក្រោយមក ឌុច បានបង្រៀនមុខវិជ្ជាខ្មែរទៀត ដែលកាលនោះ សែម រៀនថ្នាក់ទីពីរ ។ នៅឆ្នាំ ១៩៦៧-១៩៦៨ ឌុច បានប្តូរមកបង្រៀនគណិតវិទ្យាដល់ថ្នាក់របស់ សែម វិញ ។ សែម បានរៀបរាប់ពីអត្តចរិតរបស់ ឌុច នៅពេលនោះថា «គាត់ជាមនុស្សស្លូតបូត ត្រឹមត្រូវ មិនប្រកាន់វណ្ណៈ ម្យ៉ាងទៀតគាត់មិនប្រើសិទ្ធិរបស់គាត់គាបសង្កត់មកលើសិស្សរបស់គាត់ទេ» ។ សែម បាននិយាយថាកាលពី ឌុច នៅជាគ្រូបង្រៀនរបស់គាត់ គាត់ជាគ្រូម្នាក់ដែលវាងវៃ យកចិត្តទុកដាក់ក្នុងការងារ ហើយសិស្សរបស់គាត់ស្រឡាញ់គាត់ណាស់ ។ ពេលសួរថា តើ ឌុច ចាត់វិធានការបែបណា ពេលដែលមានសិស្សនៅក្នុងថ្នាក់មិនគោរពវិន័យ សែម បានឆ្លើយថា ឌុច មិនដែលធ្វើបាបសិស្សដែលមិនគោរពវិន័យទេ តែគាត់បានប្រៀនប្រដៅសិស្សទាំងនោះវិញដើម្បីឲ្យយកចិត្តទុកដាក់ក្នុងការសិក្សា ។ ចំពោះសិស្សក្រីក្រ ឌុច បានបង្រៀនដោយមិនយកកម្រៃ ។ ឌុច បានជួយសិស្សគ្រប់ៗគ្នា ។ សែម បានបន្តថា ឌុច ក៏មិនដែលមានការឈ្លោះប្រកែកគ្នាជាមួយគ្រូដទៃឡើយ ។

ពេលសួរថា ឌុច មានដែលបង្កាត់បង្រៀនសិស្សពីលិទ្ធិកុម្មុយនីស្តទេកាលពីគាត់នៅជាគ្រូបង្រៀន សែម បាននិយាយថា អ្វីដែល ឌុច និយាយនៅចុងម៉ោងសិក្សាគឺអំពីរឿងកសិករនៅថ្នាក់កណ្តាល និងថ្នាក់ក្រោមវណ្ណៈអធននាយទុនហើយមិនដែលនិយាយអំពីនយោបាយអ្វីជ្រាលជ្រៅទេ ។ សាក្សី ទេព សុខ បានឡើងបន្ទាប់ពី សែម នៅក្នុងអង្គជំនុំជម្រះ ។

**ទេព សុខ**

នៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០០៩ ទេព សុខ បានមកផ្តល់សក្ខីកម្មនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ទេព សុខ អាយុ៦១ឆ្នាំរស់ នៅភូមិសង្កែពង ឃុំស្រម៉ ស្រុកជើងព្រៃ ។ សុខ បានពណ៌នាពីឌុចថា «គាត់ជាមនុស្សមានអត្តចរិតស្លូតបូត សុភាពរាបសា ហើយជាពិសេសស្រឡាញ់សិស្សដែលរៀនខ្សោយ និងកូនសិស្សក្រីក្រ» ។ សម្រាប់សិស្សក្រីក្រ ឌុច តែងចែកសម្ភារៈសិក្សាឲ្យជានិច្ច ។ ឌុច បានប្រើគោលនយោបាយណែនាំឲ្យសិស្ស

ពូកែបង្រៀនសិស្សខ្សោយ ។ ពេលសួរពីអាកប្បកិរិយារបស់ ឌុច ពេលបម្រើការងារ សុខ បានរៀបរាប់ថា ឌុច ជាមនុស្ស ហ្មត់ចត់ ទាំងការនិយាយស្តី ទាំងការងារ ហើយម៉្យាងទៀត



សិស្សតែងតែធ្វើតាមដំបូន្មានរបស់គាត់ជានិច្ច ។ សុខ បានសង្កេតឃើញអត្តចរិតថា គ្មានសិស្សណាម្នាក់ដែលមិនចូលចិត្តគាត់ទេ ឌុច តែងតែណែនាំសិស្សនោះឲ្យទៅជាសិស្សល្អជានិច្ច ។

**ជូ វិន**



នៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០០៩ ជូ វិន បានមកផ្តល់សក្ខីកម្មនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ជូ វិន មានអាយុ៥០ឆ្នាំ រស់នៅភូមិសូភី សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ។ វិន បានចាប់ផ្តើមស្គាល់ ឌុច លើកដំបូងនៅឆ្នាំ ១៩៩៥ ដែលពេលនោះ ឌុច ដាក់ឈ្មោះថា ហង់ ពិន ដោយអ្នកទាំងពីរធ្វើជាគ្រូបង្រៀននៅភូមិផ្កាំ ក្នុងស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យដូចគ្នា ។ វិន បានមានប្រសាសន៍ប្រាប់តុលាការថា គាត់ទើបតែស្គាល់ឈ្មោះ កាំង ហ្កេកអ៊ាវ នេះក្រោយមកទេ ។ វិន បានបន្ថែមទៀតថា នៅអនុវិទ្យាល័យផ្កាំ ឌុច បង្រៀនមុខវិជ្ជាគីមីវិទ្យា ។ ពេលលោកប្រធានអង្គជំនុំជម្រះបានចោទសួរទៅសាក្សី ជូ វិន ថាតើអនុវិទ្យាល័យផ្កាំនេះក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាល ឬ ខ្មែរក្រហម? វិន បានឆ្លើយថា កាលនោះសាលានោះស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាល ហើយឈ្មោះ ហង់ ពិន នេះក៏មានឈ្មោះនៅក្នុងក្របខណ្ឌក្រសួងអប់រំដែរ ។ លោកប្រធានអង្គសវនាការបានសួរ ជូ វិន បន្តទៅទៀតអំពីអត្តចរិតរបស់ ឌុច ក្នុងរយៈពេលដែលអ្នកទាំងពីរជាសហការីដូចគ្នា ។ ជូ វិន បានប្រាប់អង្គជំនុំជម្រះទាំងមូលថា «ឌុចជាមនុស្សស្លូតបូត សុភាពរាបសា ម៉ឺងម៉ាត់នឹងការងារ ។ គាត់ធ្វើការបានត្រឹមត្រូវតាមការកំណត់» ។ ជូ វិន បានបន្តទៀតថា «ក្នុងអំឡុងពេលដែលគាត់បានរស់នៅកន្លែងនោះ ជាចំណុចពិសេសរបស់ ឌុច គឺមានប្រជាប្រិយខាងការងារអប់រំ ធ្វើការបានហ្មត់ចត់ល្អ ។ ប្រជាជនច្រើនហៅ ឌុច ថា គ្រូតា។» ។ ពេលសួរថា ហេតុអ្វីបានជាមានការសម្រេចចិត្តជ្រើសរើស ឌុច ឲ្យធ្វើជាគ្រូបង្រៀន? ជូ វិន បានរៀបរាប់ថា «អ្នកចេះច្រើនបង្រៀនអ្នកចេះតិច» ។ ក្នុងអំឡុងឆ្នាំ១៩៩៥ ស្រុកស្វាយចេកជាតំបន់ប្រទាញប្រទង់គ្នារវាងទាហានរដ្ឋាភិបាលនិងកងទ័ពខ្មែរក្រហម ។ នៅទីនោះ មានកង្វះខាតច្រើនខាងអ្នកដែលមានសមត្ថភាពជ្រៅជ្រះក្នុងការបង្រៀន ។ ឌុច ក្រោមឈ្មោះ ហង់ ពិន ត្រូវបានជ្រើសរើសឲ្យធ្វើជាគ្រូបង្រៀនដោយសារគាត់ជាអ្នកចេះដឹងម្នាក់ ។ ជូ វិន បាននិយាយថា ឌុច មិនដែលនិយាយរឿងនយោបាយនៅសាលារៀនទេ តែគាត់និយាយតែពីរឿងការងារប៉ុណ្ណោះ ។ ឌុច គឺជាមនុស្សចាស់ទុំម្នាក់នៅសាលា ហើយគាត់ជាមនុស្សដែលគោរពពេលវេលាបំផុតដែរ ។

**ហ៊ុន ស្មៀន និង ប៉េង ពាន់**

នៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០០៩ ហ៊ុន ស្មៀន និង ប៉េង ពាន់ បានមកផ្តល់សក្ខីកម្មនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ហ៊ុនស្មៀន អាយុ៦០ឆ្នាំ រស់នៅខេត្តបន្ទាយមានជ័យ បាននិយាយថា «ដោយសាលាខ្ញុំខ្វះគ្រូ ខ្ញុំក៏សុំការិយាល័យអប់រំស្រុកអញ្ជើញ ឌុច ឲ្យមកបង្រៀននៅសាលាខ្ញុំ» ។ ស្មៀន

បានបន្ថែមទៀតថា «កាលនោះ គាត់ឈ្មោះ ហង់ ពិន» ។ ស្មៀន បានរៀបរាប់ថា ឌុច ចូលបង្រៀននៅអនុវិទ្យាល័យស្វាយចេក នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩៦ ជាគ្រូភាសាបារាំង ហើយ មួយរយៈខ្លីក្រោយមក គាត់ក៏បោះបង់ចោលការងារហើយបាត់ខ្លួនរហូត ។ ដូចគ្នាទៅនឹងសាក្សីមុនៗដែរ ហ៊ុន ស្មៀន បាននិយាយរៀបរាប់អំពី ឌុច ថាជាមនុស្សមានចរិតស្លូតបូត ស្ងៀមស្ងាត់ និងជាមនុស្សចូលចិត្តអានសៀវភៅ ។ ស្មៀន រៀបរាប់ថា «ឌុច មិនសូវជានិយាយលេងសើចជាមួយគ្រូដទៃច្រើនទេ ។ ក្រោយពីចប់ម៉ោងបង្រៀន គាត់ចូលចិត្តអង្គុយអានសៀវភៅតែម្នាក់ៗឯង» ។ នៅប្រមាណម៉ោងដប់និងបួននាទីព្រឹក សាក្សីម្នាក់ទៀតឈ្មោះ ប៉ែង ពាន់ ត្រូវបានអញ្ជើញឲ្យចូលក្នុងបន្ទប់សវនាការ ។

ប៉ែង ពាន់ អាយុ៥៧ឆ្នាំ រស់នៅភូមិផ្កាំ ឃុំផ្កាំ ស្រុកស្វាយចេកជាកន្លែង ដែល ឌុច បង្រៀន ។ ពាន់ ក៏ជាអតីតគ្រូបង្រៀននៅសាលាជាមួយ ឌុច ដែរ ។ ពាន់ បានរៀបរាប់ពី ឌុច ថា គាត់ជាមនុស្សម៉ឺងម៉ាត់នឹងការងារ ។ គាត់បានបន្ថែមទៀតថា ថ្ងៃមួយមានគ្រូម្នាក់ឈ្មោះ ឡុត ង៉ាត បាននាំ ឌុច មកជួបនឹង ពាន់ ដោយប្រាប់ ពាន់ ថា ឌុច គឺជាអតីតគ្រូកាលពីសម័យសង្គមរាស្ត្រនិយម ។ ដោយកាលនោះសាលារបស់គាត់មានការខ្វះគ្រូដងពាន់ក៏បានណែនាំឲ្យ ឌុច ដាក់ពាក្យសុំធ្វើជាគ្រូបង្រៀន ។

## គ្រីស្តូហ្វើ ឡាប៉ែល

គ្រីស្តូហ្វើ ឡាប៉ែល មានអាយុ៥១ឆ្នាំ សញ្ជាតិអាមេរិកាំង បានជួប ឌុច ក្នុងខែធ្នូ ឆ្នាំ១៩៩៥ នៅភូមិចម្ការសំរោង ខេត្តបាត់ដំបង នៅពេលដែល ឌុច បានមកចូលរួមក្នុងកិច្ចប្រជុំគ្រិស្តសាសនា ។ លោក គ្រីស្តូហ្វើ ឡាប៉ែល ជាគ្រូគង្វាលគ្រិស្តសាសនា ។ ឌុច បានចូលកាន់សាសនាគ្រិស្តតាំងពីពេលនោះមក ហើយនៅថ្ងៃទី៦ ខែមករា ឆ្នាំ១៩៩៦ លោក គ្រីស្តូហ្វើ បានមុជទឹកដល់ ឌុច ដើម្បីបញ្ជាក់ថា ឌុច គឺជាគ្រិស្តសាសនិកពេញលេញហើយ ។ លោក គ្រីស្តូហ្វើ និយាយថា ឌុច បានចូលកាន់គ្រិស្តសាសនាយ៉ាងខ្ជាប់ខ្ជួនតាំងពីពេលនោះមក ហើយនៅឆ្នាំ១៩៩៧ ឌុច បានចូលធ្វើការនៅជំរំជនភៀសខ្លួនក្នុងទឹកដីថៃ ឌុច បានចូលទៅថ្វាយបង្គំព្រះរៀងរាល់ថ្ងៃអាទិត្យ ។ ពេលសួរថាតើអត្តចរិតរបស់ ឌុច យ៉ាងម៉េចដែរ នៅពេលនោះ លោក គ្រីស្តូហ្វើ ឡាប៉ែល បាន និយាយថា ឌុច ជាមនុស្សមានទឹកចិត្តល្អ ស្រឡាញ់និងគោរពព្រះ និងចេះចែករំលែកជាមួយអ្នកដទៃ «គាត់ជាបុរសដែលមានភាពជិតស្និទ្ធនិងរួសរាយ ហើយនិងមានភាពស្មោះត្រង់ និងរួសរាយ» ។ ក្រោយមកនៅខែមេសា ឆ្នាំ១៩៩៩ ទើប គ្រីស្តូហ្វើ ឡាប៉ែល ដឹងថា ឌុច មានឈ្មោះដើម កាំង ហ្កេកអ៊ាវ ដែលជាអតីតប្រធានមន្ទីរស-២១ ។

## ស្តេហ្វិន ហេស្សែល

ស្តេហ្វិន ហេស្សែល គឺជាអ្នករួចរស់ជីវិតពីជំរំឃុំខ្លួនរបស់ណាហ្ស៊ី ។ ស្តេហ្វិន ហេស្សែល មានអាយុ៩១ឆ្នាំ និងមានសញ្ជាតិបារាំង ។ លោក ស្តេហ្វិន ក៏ជាសាក្សីមួយរូបដែរនៅក្នុងតុលាការនូរ៉េមប៊ឺក ។ លោកឡើងរៀបរាប់ពីការផ្សះផ្សានៅក្នុងសាកលលោកតាមរយៈតុលាការ ។ លោកមានប្រសាសន៍ថា តុលាការនូរ៉េមប៊ឺក បានផ្សះផ្សាជម្លោះរវាងបារាំងនិងអាល្លឺម៉ង់ ហើយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានេះក៏នឹងជួយផ្សះផ្សានៅក្នុងប្រទេសកម្ពុជាដែរ ។

នៅពេលរសៀល ឌុច បានឡើងបំភ្លឺនៅក្នុងសវនាការ ។ ឌុច បានរៀបរាប់ការចាប់ឃុំខ្លួនប្អូនថ្លៃរបស់គាត់ឈ្មោះ កៅលី ចុងហួត ។ ឌុច បាននិយាយថា គាត់មិនអាចជំទាស់នឹងលេខាភូមិភាគបានទេ នៅពេលដែលលេខាភូមិភាគបញ្ជាឲ្យគាត់ចាប់នរណាម្នាក់ ឬលេខាភូមិភាគឲ្យសម្លាប់នរណាម្នាក់ ។ ហើយម្យ៉ាងទៀត ឌុច ក៏មិនហ៊ានការពារអ្នកដទៃដែរ ក្រៅពីមនុស្សដែលគាត់អប់រំបណ្តុះបណ្តាល ។ ឌុច បញ្ជាក់ថា ប្អូនថ្លៃរបស់គាត់ត្រូវបានអប់រំឲ្យចូលបក្សដោយលេខាស្រុកស្មោងឈ្មោះ ស្រ៊ុន ដែលត្រូវបានបញ្ជូនមកមន្ទីរស-២១ដែរ ។ ប្អូនប្រុសរបស់គាត់ត្រូវបានបញ្ជូនមកស-២១ប្រហែលជាជាប់ពាក់ព័ន្ធជាមួយ ស្រ៊ុន ។

ថ្ងៃទី២៧ វិច្ឆិកា ឆ្នាំ២០០៩ គឺជាថ្ងៃបញ្ចប់ការសួរដេញដោលនៅក្នុងតុលាការកាត់ទោស កាំង ហ្កេកអ៊ាវ ហៅ ឌុច ។ ថ្ងៃនេះ ឌុច បានស្នើសុំឲ្យមានការរួចទោស ។ ឌុច ទាមទារឲ្យមានការដោះលែងទោះបីជាខ្លួនបានប្រព្រឹត្តនៅមន្ទីរស-២១ក៏ដោយ ។ ទោះជាយ៉ាងណាក៏ការទាមទារនេះត្រូវបានបដិសេធទាំងអស់ ។

**ក្រុមទស្សនាវដ្តីស្វែងរកការពិត**

# អតីតអ្នកទោស និង សាច់ញាតិគោរពដល់អ្នកស្លាប់នៅមន្ទីរស-២១

នៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១០ មួយថ្ងៃមុនការប្រកាសជាផ្លូវការនូវសាលក្រម កាំង ហ្គេកអ៊ាវ ហៅ ឌុច ដើមបណ្តឹងរដ្ឋប្បវេណីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលក្នុងនោះក៏មានអតីតអ្នកទោសនៅមន្ទីរ-២១ដែរ នោះបានមកជួបប្រជុំគ្នានៅក្នុងបរិវេណមន្ទីរស-២១ ឬគុកទួលស្លែងដើម្បីប្រារព្ធពិធីតាមបែបពុទ្ធសាសនាមួយដើម្បីឧទ្ទិសដល់សាច់ញាតិដែលបានទទួលរងនូវអំពើទារុណកម្មនិងសម្លាប់នៅរបបពិឃាតដើងឯកក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ។

អ្នកចូលរួមមានអារម្មណ៍រំជួលចិត្តនៅពេលដែលធ្វើពិធីអុជធូបដើម្បីឧទ្ទិសដល់ក្រុមគ្រួសារដែលបានស្លាប់នៅមន្ទីរស-២១ ។ ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ឈ្មោះ ហាវ សុភា មិនអាចទប់ទឹកភ្នែករបស់ខ្លួនបានឡើយ នៅពេលគាត់អុជអូបនៅក្នុងពីធីនេះ ។ ហាវ សុភា បានបាត់បង់ឪពុករបស់គាត់នៅមន្ទីរស-២១ ក្រោមការគ្រប់គ្រងរបស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច ។ នង ចាន់ផល មិនដែលបំភ្លេចរឿងរ៉ាវឈឺចាប់កាលពីជំនាន់ខ្មែរក្រហមទេ តែពេលអុជធូបនៅក្នុងពិធីនេះបានធ្វើឲ្យគាត់រឹតតែនឹកឃើញឡើងវិញដល់ម្តាយរបស់គាត់ដែលបានស្លាប់នៅមន្ទីរនេះ ។

សូមឲ្យវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់នៅមន្ទីរស-២១ បានទៅដល់សុគតិភពនិងសូមឲ្យកូនចៅរបស់ជនរងគ្រោះទាំងនោះធ្វើដំណើរទៅមុខទៀតទៅរកភាពផ្សះផ្សានិងភាពសុខសាន្តទាំងផ្លូវកាយនិងផ្លូវចិត្ត ។

**ញាណ សុជាតិ**



ជនរងគ្រោះបង្សុកូល ឧទ្ទិសកុសលដល់អ្នកទោសដែលបានស្លាប់នៅមន្ទីរស-២១ ឬ គុកទួលស្លែង

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០

# សេចក្តីប្រកាសព័ត៌មាន

## កាំង ហ្គេកអ៊ាវ ត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩

ថ្ងៃនេះ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) សូមប្រកាសថា កាំង ហ្គេកអ៊ាវ ហៅ ឌុច មានពិរុទ្ធភាពពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ និងបានផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល៣៥ឆ្នាំ ។

កាំង ហ្គេកអ៊ាវ គឺជាបុគ្គលទីមួយដែលត្រូវបានយកមកជំនុំជម្រះនៅចំពោះមុខ អ.វ.ត.ក ។ កាំង ហ្គេចអ៊ាវ ធ្លាប់បានបំពេញការងារជាអនុប្រធាន និងក្រោយមកជាប្រធានមន្ទីរស-២១ ដែលជាមន្ទីរសន្តិសុខមានភារកិច្ចក្នុងការសួរចម្លើយ និងសម្លាប់បុគ្គលទាំងឡាយដែលបក្សកុម្មុយនីស្តកម្ពុជាយល់ថាជាខ្មាំងរបស់កម្ពុជាប្រជាធិបតេយ្យ ។ មន្ទីរស-២១ បានដំណើរការពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ។ អង្គជំនុំជម្រះរកឃើញថា ជនគ្រប់រូបដែលត្រូវបានឃុំនៅក្នុងមន្ទីរស-២១ សុទ្ធតែរង់ចាំការសម្លាប់ចោលទាំងអស់ អនុលោមតាមគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងការ «កម្ទេច» ខ្មាំង ។ អ្នកជាប់ឃុំត្រូវបានសម្លាប់ដោយផ្ទាល់ក្នុងទ្រង់ទ្រាយធំ ឬបានស្លាប់ដោយសារតែការធ្វើទារុណកម្មនិងលក្ខខណ្ឌនៃការឃុំខ្លួន ។ ទោះបីជាអង្គជំនុំជម្រះរកឃើញថាមានមនុស្សចំនួនតែ១២,២៧២នាក់ ត្រូវបានឃុំខ្លួននិងសម្លាប់ចោលនៅមន្ទីរស-២១ ដោយផ្អែកតាមបញ្ជីអ្នកទោសក៏ដោយ ក៏អង្គជំនុំជម្រះបានបង្ហាញរួចហើយថា ចំនួនពិតប្រាកដនៃអ្នកជាប់ឃុំទាំងអស់ពិតជាមានចំនួនច្រើនជាងនេះឆ្ងាយណាស់ ។

អង្គជំនុំជម្រះសាលាដំបូងរកឃើញថា កាំង ហ្គេកអ៊ាវ បានធ្វើការជាមួយអ្នកផ្សេងៗរួមទាំងអ្នកនៅក្រោមឱវាទរបស់គាត់ នៅក្នុងកិច្ចប្រតិបត្តិការមន្ទីរស-២១ និង ស-២៤នេះ ។ ស-២៤ គឺជាមន្ទីរចំណុះមួយដែលត្រូវបានប្រើប្រាស់ធ្វើជាមណ្ឌលលត់ដំ ។ យ៉ាងតិចបំផុតក៏មានមនុស្សចំនួន ១៣០០នាក់ ដែលត្រូវបានឃុំខ្លួននៅទីនោះ ។ អង្គជំនុំជម្រះរកឃើញទៀតថា កាំង ហ្គេកអ៊ាវ ពិតជាមានអំណាចពេញលេញ និងបានអនុវត្តអំណាចនេះនៅមន្ទីរស-២១ ហើយអំពើរបសគាត់ក្នុងការអនុវត្តតួនាទីទាំងនេះបានបង្ហាញឲ្យឃើញនូវកម្រិតប្រសិទ្ធភាពខ្ពស់ចំពោះការងារនិងការពេញចិត្តរបស់គាត់ចំពោះភារកិច្ចនេះ ។ គាត់បំពេញការងារដោយមិនខ្លាចនឿយហត់ដើម្បីធានាឲ្យមន្ទីរ-២១ ដំណើរប្រកបដោយប្រសិទ្ធភាពខ្ពស់ ហើយគាត់ធ្វើដូច្នេះដើម្បីបង្ហាញភក្តីភាពដ៏មោះមុតរបស់គាត់ចំពោះថ្នាក់លើ ។ ដូច្នេះ អង្គជំនុំជម្រះរកឃើញថា កាំង ហ្គេកអ៊ាវ ហៅ ឌុច មិនត្រឹមតែបានអនុវត្តគោលនយោបាយប៉ុណ្ណោះទេ ប៉ុន្តែគាត់ថែមទាំងបានចូលរួមយ៉ាងសកម្មក្នុងការបង្កើតគោលនយោបាយទាំងឡាយរបស់បក្សកុម្មុយនីស្តនៅមន្ទីរស-២១ ទៀតផង ។

កាំង ហ្គេកអ៊ាវ ត្រូវបានចោទប្រកាន់បន្ថែមពីបទឧក្រិដ្ឋកម្មក្រោមច្បាប់ជាតិរួមមាន បទមនុស្សឃាតគិតទុកជាមុននិងបទធ្វើទារុណកម្ម ដែលអាចផ្តន្ទាទោសបាននៅចំពោះមុខ អ.វ.ត.ក តាមមាត្រា៣ថ្មីនៃច្បាប់ អ.វ.ត.ក ។ នៅក្នុងសេចក្តីដាច់ដោយឡែកពីគ្នាដែលត្រូវចេញនៅថ្ងៃនេះដែរ ចៅក្រមនៃអង្គជំនុំជម្រះមានការយល់ឃើញផ្ទុយគ្នាអំពីថាការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋទាំងនេះត្រូវបានផុតរលត់ឬមិនទាន់ផុតរលត់នៅមុនការចាប់ផ្តើមការស៊ើបអង្កេតរបស់ អ.វ.ត.ក លើជនជាប់ចោទ ។ ការមិនមានសំឡេង

ភាគច្រើនដាច់ខាតនៃចៅក្រមបួនរូបយ៉ាងតិចគាំទ្រចំពោះបញ្ហានេះបានបង្កើតឧបសគ្គក្នុងការអនុវត្តយុត្តាធិការរបស់អង្គជំនុំជម្រះចំពោះបទឧក្រិដ្ឋជាតិទាំងនេះ ។ ទោះជាយ៉ាងណាក្តី សេចក្តីសម្រេចនេះពុំមានផលប៉ះពាល់ដល់ការកំណត់ទោសទេ ។

កាំង ហ្កេកអ៊ាវ ត្រូវបានជាប់ពិរុទ្ធភាពពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលមានបទល្មើសការធ្វើទុក្ខបុកម្នេញដែលរួមបញ្ចូលនូវបទល្មើសដទៃទៀតនៃបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិមានដូចជា ការសម្លាប់រង្គាល ការដាក់នៅក្នុងមន្ទីរឃុំឃាំង និងការធ្វើទារុណកម្មព្រមទាំងការបំពារបំពានធ្ងន់ធ្ងរចំពោះបទល្មើសជាច្រើននៃអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ ដែលជាមូលដ្ឋានឲ្យអង្គជំនុំជម្រះសម្រេចកំណត់ទោសសរុបដាក់ពន្ធនាគារចំនួន៣៥ឆ្នាំ ។ នៅក្នុងការសម្រេចកំណត់ទោសនេះឲ្យសមស្រប អង្គជំនុំជម្រះបានពិចារណាទៅលើស្ថានទម្ងន់ទោសជាច្រើន ជាពិសេសភាពធ្ងន់ធ្ងរនៃបទល្មើសដែលត្រូវបានប្រព្រឹត្តក្នុងរយៈពេលយ៉ាងយូរមកលើជនរងគ្រោះយ៉ាងតិចបំផុតក៏មានចំនួន១២,២៧២ នាក់ដែរ ។

អង្គជំនុំជម្រះក៏បានសម្រេចដែរថា មានកត្តាសម្រាលទោសមួយចំនួនដែលតម្រូវឲ្យមានការផ្តន្ទាទោសដាក់ពន្ធនាគារជនជាប់ចោទមានកំណត់ឆ្នាំជាជាងដាក់ពន្ធនាគារអស់មួយជីវិត ។ ស្ថានសម្រាលទោសទាំងនេះរួមមាន កិច្ចសហការរបស់ជនជាប់ចោទជាមួយអង្គជំនុំជម្រះ ការទទួលសារភាពអំពីការទទួលខុសត្រូវរបស់ខ្លួន ការសម្តែងវិប្បដិសារី ទោះបីជាមិនបានទូលំទូលាយក៏ដោយ ស្ថានភាពបង្ខិតបង្ខំក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ និងលទ្ធភាពដែលថាជនជាប់ចោទអាចនឹងស្តារនីតិសម្បទាបានឡើងវិញ ។

ផ្អែកតាមសេចក្តីសម្រេចកាលពីលើកមុនចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ អង្គជំនុំជម្រះបានសម្រេចថា ការកាត់បន្ថយទោសពីរយៈពេលផ្តន្ទាទោសខាងលើចំនួន០៥ឆ្នាំ គឺជាការបន្ថយសមស្រប ដោយសារតែការរំលោភសិទ្ធិរបស់ជនជាប់ចោទក្នុងអំឡុងពេលឃុំខ្លួនគាត់ខុសនីតិវិធីច្បាប់ដោយតុលាការយោធាកម្ពុជាចាប់ពីថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ រហូតដល់ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧ ។ កាំង ហ្កេកអ៊ាវ ត្រូវបានទទួលការទូទាត់រយៈពេលឃុំខ្លួននៅក្រោមសមត្ថកិច្ចរបស់តុលាការយោធាកម្ពុជា និងក្រោមសមត្ថកិច្ចរបស់ អ.វ.ត.ក ។

នៅក្នុងសាលក្រមរបស់ខ្លួន អង្គជំនុំជម្រះបានប្រកាសថា ដើមបណ្តឹងរដ្ឋប្បវេណីទាំង៦៦នាក់ ពិតជាមានភស្តុតាងបញ្ជាក់លើការអះអាងរបស់ពួកគេថាជាជនរងគ្រោះផ្ទាល់នៃមន្ទីរស-២១ ឬស-២៤ ឬមានភស្តុតាងបញ្ជាក់អំពីអត្ថិភាពជាជនរងគ្រោះផ្ទាល់នៃមន្ទីរស-២១ឬស-២៤ និងសាច់ញាតិជិតស្និទ្ធឬចំណងនៃសេចក្តីស្រឡាញ់ពិសេសជាមួយនឹងជនរងគ្រោះទាំងនោះ ឬភាពស្ថិតនៅក្នុងបន្ទុករបស់ជនរងគ្រោះទាំងនោះ ។ ដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះក៏មានបង្ហាញបន្ថែមថា មរណភាពជនរងគ្រោះទាំងនោះធ្វើឲ្យពួកនេះទទួលរងព្យសនកម្មជាច្រើន ហើយព្យសនកម្មទាំងនេះគឺផលវិបាកផ្ទាល់នៃអំពើឧក្រិដ្ឋរបស់ កាំង ហ្កេកអ៊ាវ ។ អង្គជំនុំជម្រះយល់ព្រមតាមសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលបានស្នើសុំឲ្យបញ្ចូលឈ្មោះរបស់ពួកគាត់ក្នុងសាលក្រម ។ អង្គជំនុំជម្រះក៏បានបង្គាប់ផងដែរឲ្យមានការចងក្រងនិងបោះពុម្ពពាក្យសម្តីសុំអភ័យទោសដែលជនជាប់ចោទបាននិយាយក្នុងអំឡុងពេលសវនាការ ។ អង្គជំនុំជម្រះបានបដិសេធសំណើសំផ្សេងៗទៀតទាំងអស់របស់ដើមបណ្តឹងរដ្ឋវប្បវេណី ដោយហេតុថា សំណើសុំទាំងនេះមិនមានភាពជាក់លាក់ ឬហួសវិសាលភាពដែល អ.វ.ត.ក អាចសម្រេចបាន ។

ការជំនុំជម្រះលើអង្គសេចក្តីចំពោះ កាំង ហ្កេកអ៊ាវ បានចាប់ផ្តើមនៅក្នុងថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៩ ។ សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលត្រូវបានបញ្ចប់នៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៩ បន្ទាប់ពីមានការបើកសវនាការជំនុំជម្រះក្តីអស់រយៈពេល៧៧ថ្ងៃរួចមក ។ ក្នុងអំឡុងពេលធ្វើសវនាការទាំងនេះ មានសាក្សីចំនួន២៤នាក់ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន២២នាក់ និងសាក្សីជំនាញចំនួន៩នាក់ បានចូលរួមផ្តល់សក្ខីកម្ម ។ មានប្រជាពលរដ្ឋជាង ២៨០០០០នាក់ បានមកចូលរួមតាមដានកិច្ចដំណើរការនីតិវិធីនេះនៅក្នុងសវនាការសាធារណៈដោយផ្ទាល់ ។

***(ឯកសាររបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា)***

# សាលក្រម ឌុច

នៅថ្ងៃទី២៦ ខែកក្កដា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.) បានចេញសាលក្រមជាលើកដំបូងរបស់ខ្លួន នៅក្នុងករណីប្រឆាំងនឹងជនជាប់ចោទ ឌុច ។ តុលាការនេះបានរកឃើញថា ឌុច មានពិរុទ្ធភាពលើបទឧក្រិដ្ឋកម្មសង្គ្រាមនិងបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិចំពោះអំពើទាំងឡាយណាដែលបានប្រព្រឹត្តឡើងនៅ «មន្ទីរស-២១» គុកខ្មែរក្រហមដែលត្រូវបានគេស្គាល់ថាជាគុកទួលស្លែង ។ ការប្រកាសសាលក្រមនេះគឺជាចំណុចរបត់មួយដ៏សំខាន់សម្រាប់ប្រទេសកម្ពុជា ។ នេះជាលើកដំបូងនៅក្នុងប្រវត្តិសាស្ត្រប្រទេសកម្ពុជាដែលកម្មាភិបាលខ្មែរក្រហមដ៏សំខាន់ម្នាក់ត្រូវបានដាក់ឲ្យទទួលខុសត្រូវនៅក្នុងតុលាការដ៏គួរឲ្យជឿជាក់ចំពោះបទឧក្រិដ្ឋនានានៅក្នុងសម័យប៉ុលពត ។

បើទោះជាយ៉ាងនេះក៏ដោយ សាលក្រមនេះបានទាក់ទាញមតិរិះគន់ដ៏គួរឲ្យកត់សម្គាល់មួយចំនួនពីសំណាក់ជនរងគ្រោះ រួមទាំងរដ្ឋមន្ត្រីក្រសួងការបរទេស ហោ ណាំហុង ផង ។ អត្ថបទនេះនឹងធ្វើការពិភាក្សាដោយសង្ខេបពីមូលហេតុពីរយ៉ាងដែលបណ្តាលឲ្យមានការព្រួយបារម្ភ ។ ចំណុចទីមួយគឺថា មានជនរងគ្រោះជាច្រើនបានធ្វើការត្អូញត្អែរយ៉ាងឈឺចាប់ថាការដាក់ទណ្ឌកម្មចំពោះ ឌុច គឺមានកម្រិតស្រាលខ្លាំងណាស់ ។ អង្គជំនុំជម្រះសាលាដំបូងបានធ្វើការដាក់ទោស ឌុច រយៈពេល៣៥ឆ្នាំនៅក្នុងគុកដែលទូទាត់ទៅនៅសល់តិចជាង២០ឆ្នាំផង បន្ទាប់ពីបានធ្វើការកាត់បន្ថយរយៈពេលដែល ឌុច បានជាប់នៅក្នុងឃុំរួចទៅហើយ ។ ចំណុចទីពីរ គឺថា ដើមបណ្តឹងរដ្ឋប្បវេណីដែលជាអ្នកបានចូលរួមជាមួយនឹងរឿងក្តីហើយបានធ្វើការស្នើសុំទៅតុលាការឲ្យផ្តល់សំណងចំពោះការខូចខាតនិងរបួសស្នាមផ្សេងៗដែលបង្កឡើងក្រោមការដឹកនាំរបស់ ឌុច មានការខកបំណងជាខ្លាំងចំពោះការសម្រេចរបស់អង្គជំនុំជម្រះទាក់ទងនឹងការទាមទារសំណងនេះ ។ ចៅក្រមបានត្រឹមតែសន្យាថានឹងធ្វើការបញ្ចូលឈ្មោះរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសាលក្រម ព្រមទាំងធ្វើការចងក្រងនិងបោះពុម្ពផ្សាយពាក្យសម្តីសុំអភ័យទោសនិងពាក្យស្តាយក្រោយរបស់ ឌុច ប៉ុណ្ណោះ ។

**ការកាត់សេចក្តី**

ការកម្រិតទោសរបស់ ឌុច គឺជាមូលហេតុចម្បងនៃការខកបំណងរបស់ជនរងគ្រោះ ។ បញ្ហានេះមានភាពស្រដៀងគ្នាទៅនឹងការសម្រេចរបស់តុលាការអន្តរជាតិផ្សេងៗដែរ ប៉ុន្តែចំពោះជនរងគ្រោះ រឿងនេះមានភាពលំបាកក្នុងការប្រឈមនឹងការពិតដែលថា ឌុច អាចនឹងរួចខ្លួននៅពេលគាត់មានអាយុ៨៦ឆ្នាំ ។ បើទោះជាទណ្ឌកម្មធំជាងគេបង្អស់នៅតុលាការក៏ដោយ (ការដាក់គុកអស់មួយជីវិត) ក៏មិនអាចយកមកកាត់ថ្លៃបានចំពោះមនុស្សរាប់ពាន់នាក់ដែលបានបាត់បង់ជីវិតនៅក្រោមរបបខ្មែរក្រហមដែរ ។ សហព្រះរាជអាជ្ញានៅក្នុងអ.វ.ត.ក. បានស្នើសុំការដាក់ទោសទៅដល់៤០ឆ្នាំ ប៉ុន្តែអង្គជំនុំជម្រះបានសម្រេចទោសត្រឹមតែ៣៥ឆ្នាំនៅក្នុងគុក ។ អង្គជំនុំជម្រះបានផ្តល់ហេតុផលថា ការសហការនិងការទទួលកំហុសរបស់ ឌុច បានជួយសម្រាលទោសពីការជាប់គុកអស់មួយជីវិតមកជាទោសក្នុងរយៈកាលកំណត់មួយ ។ អង្គជំនុំជម្រះបានលើកហេតុផលបន្ថែមទៀតថា ឌុច ត្រូវបានសម្រេចឲ្យសម្រាលទោសដើម្បីជាថ្នូរទៅនឹងរយៈពេលដែលសិទ្ធិមូលដ្ឋានរបស់គាត់ត្រូវបានរំលោភ ដោយសារតែ ឌុច បានជាប់ឃុំឃាំងដោយខុសច្បាប់មួយរយៈកាល មុនពេលដែល អ.វ.ត.ក. ចាប់ដំណើរការងាររបស់ខ្លួនទៅទៀត ។ អង្គជំនុំជម្រះមានការលំបាកក្នុងការព្យាយាមថ្លឹងថ្លែងពីសារសំខាន់នៃការដាក់ទោសមួយដ៏សមរម្យទល់នឹងការពិចារណាទៅលើភាពយុត្តិធម៌និងដំណើរនីតិវិធីដ៏ត្រឹមត្រូវ ។

ការឃុំខ្លួន ឌុច ដោយខុសច្បាប់ទំនងជាផ្តល់មូលហេតុជាក់លាក់មួយឈានទៅដល់ការសម្រេចរយៈពេលនៃការដាក់ទោសនៅក្នុងគុក ។ បើទោះបីជាមានជនរងគ្រោះមួយភាគតូចនឹងសម្តែងនូវការអាណិតអាសូរចំពោះអតីតប្រធានមន្ទីរស-២១ ជាបុគ្គលដែលត្រូវបានបង្ខំឲ្យចាប់ដាក់ឃុំឃាំងយ៉ាងសាហាវឃោរឃៅចំពោះជនរងគ្រោះយ៉ាងណាក៏ដោយ ក៏អ.វ.ត.ក. អាចលើក

កម្ពស់នូវបទដ្ឋានមិនលម្អៀងនិងយុត្តិធម៌បាន លុះត្រាណាតែតុលាការខ្លួនឯងនេះអាចគោរពច្បាប់បាន ។ ជាការពិត លក្ខណៈពិសេសមួយរបស់សវនាការ ឌុច គឺថា តុលាការនេះមានភាពយុត្តិធម៌ចំពោះជនជាប់ចោទ បើទោះជាមានភស្តុតាងប្រវត្តិសាស្ត្រច្រើនលើសលុបបានបង្ហាញពីកំហុសរបស់ ឌុច ក៏ដោយ ។ តុលាការនេះគួរតែត្រូវបានលើកសរសើរចំពោះការយកចិត្តទុកដាក់ទៅលើបទដ្ឋាននីតិវិធីយ៉ាងត្រឹមត្រូវនិងចំពោះការដើរតួជាគំរូមួយចំពោះប្រព័ន្ធតុលាការនៅកម្ពុជា ។ ការសម្រេចឲ្យមានការកាត់បន្ថយទោសនៅក្នុងគុករបស់ ឌុច មិនមែនជាការសម្រេចដោយគ្មានមូលដ្ឋានច្បាស់លាស់នោះទេ ។

អង្គជំនុំជម្រះបានធ្វើការសម្រេចចិត្តដោយផ្អែកទៅលើសេចក្តីសម្អាងថា ឌុច បានធ្វើការសហការ ព្រមទាំងបង្ហាញពីការសោកស្តាយរបស់ខ្លួន ។ អង្គជំនុំជម្រះមានមូលហេតុគ្រប់គ្រាន់ក្នុងការលើកទឹកចិត្តឲ្យជនជាប់ចោទនិយាយលាតត្រដាងការពិត និងជួយជ្រោមជ្រែងក្នុងការស្វែងរកការទទួលខុសត្រូវ ។ មកទល់នឹងពេលនេះ ឌុច គឺជាកម្មាភិបាលខ្មែរក្រហមតែម្នាក់គត់ដែលបានទទួលស្គាល់អំពើឧក្រិដ្ឋរបស់ខ្លួន ។ នៅក្នុងសវនាការ ឌុច បានបញ្ជាក់នូវអង្គហេតុជាច្រើននិងបានបង្ហាញនូវព័ត៌មានមួយចំនួនអំពីការងារនៅក្នុងមន្ទីរស-២១ ។ ទោះជាយ៉ាងណាក៏ដោយ ការទទួលស្គាល់របស់ ឌុច បានបន្ថែមតែបន្តិចបន្តួចប៉ុណ្ណោះក្នុងការស្វែងរកការពិតផ្នែកប្រវត្តិសាស្ត្រពីអំពើឧក្រិដ្ឋកម្មដែលបានកើតមាននៅទួលស្លែង ហើយការសហការរបស់ ឌុច ក៏មិនមានភាពចាំបាច់ដើម្បីសម្រេចលើទោសគាត់ដែរ ដោយហេតុថា តុលាការមានឯកសារនិងភស្តុតាងដទៃទៀតពាក់ព័ន្ធនឹង ឌុច ច្រើនលើសលប់រួចស្រេចទៅហើយ ។

តុលាការនេះយល់ថា វាមានសារសំខាន់ណាស់ក្នុងការលើកទឹកចិត្តឲ្យ ឌុច ឡើងធ្វើជាសាក្សីប្រឆាំងនឹងមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមបួនរូបទៀតនៅក្នុងករណី០០២ ។ ភស្តុតាងដែលអាចភ្ជាប់បុគ្គលទាំងបួនរូបទៅនឹងអំពើឧក្រិដ្ឋកម្មដោយផ្ទាល់មានចំនួនតិចតួចណាស់បើប្រៀបធៀបទៅនឹងភស្តុតាងដែលរកឃើញចំពោះ ឌុច ។ ហេតុដូច្នេះ ការឡើងធ្វើជាកសិណសាក្សីរបស់ ឌុច មានតម្លៃខ្លាំងណាស់ ។ មកទល់នឹងពេលនេះ យើងនៅមិនទាន់ដឹងថាតើការដាក់ទោស ឌុច បែបនេះពិតជាធ្វើឲ្យ ឌុច ព្រមផ្តល់នូវកសិណសាក្សីចំពោះករណី០០២ ឬយ៉ាងណាទេ ។ ប្រសិនបើ ឌុច ពិតជាមានព័ត៌មានដ៏មានសារប្រយោជន៍មែន គាត់ប្រហែលជាមានទឹកចិត្តគ្រប់គ្រាន់ដើម្បីចែករំលែកព័ត៌មាននេះរួចទៅហើយ ។ ការទម្លាក់ការចោទប្រកាន់ទៅលើអ្នកបង្គាប់ពីខាងលើ ពិតជាអាចបញ្ជាក់ថាការទទួលខុសត្រូវរបស់គាត់មានកំណត់ ព្រមទាំងអាចបញ្ជាក់បានថា អ្នកដែលបញ្ជាគាត់ឲ្យប្រព្រឹត្តអំពើព្រៃផ្សៃ ពិតជាមិនអាចរួចខ្លួនបានឡើយ ។

ក្នុងទ្រឹស្តី ក្តីសង្ឃឹមចេញមកពីការកម្រិតទោសឲ្យនៅស្រាលអាចល្បួងជនជាប់ចោទម្នាក់ឬច្រើនជាងនេះនៅក្នុងករណី០០២ ឲ្យធ្វើការទម្លាយការពិត ទទួលស្គាល់ឧក្រិដ្ឋកម្ម និងទទួលយកការទទួលខុសត្រូវ ។ បើទោះជាយ៉ាងនេះក៏ដោយ ទ្រឹស្តីនេះហាក់ដូចជាមិនអាចយកមកប្រើប្រាស់បានចំពោះករណីនេះទេ ។ ជនជាប់ចោទទាំងបួនរូបមានវ័យចាស់ជាង ឌុច ខ្លាំង ហើយមានសុខភាពទ្រុឌទ្រោម ។ មិនមានហេតុផលណាមួយដែលអ្នកទាំងបួនរូបនេះអាចសង្ឃឹមថាអាចនៅមានជីវិតរស់ដើម្បីទទួលទោសឲ្យដល់រយៈពេលមួយស្មើគ្នានឹង ឌុច នោះទេ ។ គ្រឿងជំរុញទឹកចិត្តជនជាប់ចោទឲ្យនិយាយគឺការចោទប្រកាន់គ្នាទៅវិញទៅមកដើម្បីឲ្យខ្លួនរួចផុតពីការទទួលខុសត្រូវ ។

សេចក្តីសម្រេចចំពោះការបន្ថយទោស ឌុច ដោយផ្អែកទៅលើការសម្តែងចេញនូវការស្តាយក្រោយ នៅមានភាពទន់ខ្សោយនៅឡើយ ។ ពេលដែលតុលាការសម្រេចផ្តល់រង្វាន់ចំពោះការសូមទោស តុលាការត្រូវតែពិនិត្យមើលឲ្យបានល្អិតល្អន់ថាតើការសូមទោសនោះមានភាពស្មោះត្រង់កម្រិតណាដើម្បីចៀសវាងកុំឲ្យមានការបង្ហាញពីការស្តាយក្រោយក្លែងក្លាយឬទទេស្អាតនៅពេលក្រោយទៀត ។ កាយវិការនៃការស្តាយក្រោយគួរតែបង្ហាញឲ្យឃើញច្រើនជាងនេះ ។ ឌុច ពិតជាបានបង្ហាញពីការសោកស្តាយរបស់គាត់នៅក្នុងតុលាការ ប៉ុន្តែគាត់មិនបានឆ្លៀតឱកាសក្នុងការសម្តែងការសុំទោសដោយផ្ទាល់ទៅកាន់ជនរងគ្រោះទេ ។ បន្ទាប់ពីបានសម្តែងនូវការទទួលស្គាល់កំហុសនិងសុំអភ័យទោសរួចមក នៅចុងបញ្ចប់នៃសវនាការ គាត់បែរជាសុំឲ្យមានការដោះលែងនិងសុំមិនទទួលកំហុសតាមរយៈមេធាវីជាតិការពារក្តី

របស់គាត់ទៅវិញ ។ ប្រសិនបើទំហំនៃឧក្រិដ្ឋកម្មនេះមិនមានទំហំធំធេងនោះទេ ការសម្ដែងការសោកស្ដាយរបស់ ឌុច ពិតជាទទួលបាននូវការពិចារណាច្បាស់លាស់ជាងនេះ ។ ដោយផ្អែកទៅលើភាពរន្ធត់និងសាហាវឃោរឃៅនៅមន្ទីរស-២១ ពាក្យសម្ដីសុំអភ័យទោសរបស់គាត់មិនអាចដើរតួតែឯងក្នុងការសម្រេចចិត្តទៅលើការកាត់បន្ថយទោសបានទេ ។

អង្គជំនុំជម្រះបានជ្រើសរើសយកការដាក់ទោសមួយស្ថិតនៅក្នុងកម្រិតទាបតែសមហេតុផល ។ ដើម្បីទទួលបាននូវយុត្តិធម៌តាមរយៈការដាក់ទោស តុលាការនេះត្រូវតែសម្រេចទោសដែលអាចដាក់ ឌុច ឲ្យជាប់គុកស្មើរមួយជីវិត ឬក៏មួយជីវិតតែម្ដង ។ ដើម្បីលើកកម្ពស់បទដ្ឋាននៃដំណើរការនីតិវិធី និងការប្រាប់ការពិតព្រមទាំងការសុំអភ័យទោស តុលាការនេះត្រូវតែចាប់ផ្ដើមចេញពីចំនួនមួយដែលធ្វើឲ្យការបន្ថយទោសនេះយ៉ាងហោចណាស់ក៏មានអត្ថន័យទៅថ្ងៃអនាគតដែរ ។ ឌុច បានប្រកាសថា គាត់គ្រាន់តែជាមនុស្សម្នាក់ ហើយសហព្រះរាជអាជ្ញាកំពុងធ្វើការពិចារណាអំពីលទ្ធភាពបែបនេះដែរ ។

អង្គជំនុំជម្រះសាលាឧទ្ធរណ៍មិនគួរបន្ថយទោសទេ ប៉ុន្តែសាលានេះគួរធ្វើការពិចារណាឲ្យមានការដាក់ទោសក្នុងគុកយូរជាងនេះ ។ មធ្យោបាយដ៏ល្អនោះគឺចាប់ផ្ដើមជាមួយការដាក់ទោស ៤០ឆ្នាំដែលព្រះរាជអាជ្ញាបានស្នើសុំដែលការស្នើសុំនេះបានសម្រាលឧក្រិដ្ឋកម្មរបស់ ឌុច រួចបាត់ទៅហើយ ព្រមទាំងធ្វើការបញ្ចូលនូវការបន្ថយទោសបន្តិចបន្តួចជាថ្នូរនឹងការឃុំឃាំងដោយខុសច្បាប់របស់គាត់ ។ លទ្ធផលចុងក្រោយគួរតែដាក់ទោសក្នុងរយៈពេល៣៥ ទៅដល់ ៣៨ឆ្នាំ ។ ការសម្រេចនេះមិនងាយនឹងធ្វើឲ្យ ឌុច អាចរួចខ្លួនបាន ហើយអាចជួយឲ្យទទួលបាននូវប្រយោជន៍ចំពោះការដាក់ទោសប្រសើរជាងនេះ ដោយមិនចាំបាច់ផ្លាស់ប្ដូរកិច្ចខំប្រឹងប្រែងរបស់តុលាការក្នុងការលើកកម្ពស់ដំណើរការនីតិវិធីនិងការស្វែងរកការពិត ។

## សំណងជំងឺចិត្តជាសមូហភាព និងផ្លូវចិត្ត

ការរិះគន់ចម្បងទីពីរចំពោះសាលក្រម គឺទាក់ទងទៅនឹងសំណងសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណី ។ អ.វ.ត.ក មិនមានខ្ទង់ថវិកាឬសមត្ថកិច្ចផ្ដល់សំណងជាហិរញ្ញវត្ថុដល់ជនរងគ្រោះជា



ឌុច នៅថ្ងៃប្រកាសសាលក្រម

លក្ខណៈបុគ្គលនោះទេ។ ជាងនេះទៅទៀត អ.វ.ត.ក ពុំមានសមត្ថកិច្ចគ្រប់គ្រាន់ក្នុងការបង្ខំឲ្យរដ្ឋាភិបាលកម្ពុជាអនុវត្តសំណងនោះដែរ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏អ.វ.ត.ក ត្រូវតែផ្តល់នូវសំណងជំងឺចិត្តជាសមូហភាពនិងផ្លូវចិត្តទៅដល់ដើមបណ្តឹងរដ្ឋប្បវេណីដែលតុលាការរកឃើញថាបានទទួលរងការឈឺចាប់។ ដើមបណ្តឹងរដ្ឋប្បវេណីមានការខកចិត្ត ដែល អ.វ.ត.ក បានផ្តល់សំណងដែលមិនគ្រប់គ្រាន់តាមការទាមទារ។ អ.វ.ត.ក បានទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណីចំនួន៦៦នាក់ ដែលមានលក្ខណៈគ្រប់គ្រាន់។ ប៉ុន្តែ បែរជាផ្តល់ឲ្យពួកគាត់ត្រឹមតែការទទួលស្គាល់ដោយការបោះពុម្ពឈ្មោះ និងដកស្រង់សេចក្តីថ្លែងការណ៍របស់ឌុច តែប៉ុណ្ណោះ។ ដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនបានធ្វើការរិះគន់ចំពោះ អ.វ.ត.ក ថានេះជាសញ្ញាមួយបង្ហាញពីការបដិសេធចោល និងការមិនគោរព។

អ.វ.ត.ក ត្រូវបានចាត់ទុកថាជាអ្នកចាប់ផ្តើមដំបូងដោយបានបញ្ចូលឲ្យមានការចូលរួមរបស់ជនរងគ្រោះយ៉ាងទូលំទូលាយ ហើយដោយសារតែមូលហេតុនេះ អ.វ.ត.ក បានទទួលជំនួយឧបត្ថម្ភពីម្ចាស់ជំនួយ។ ការចូលរួមរបស់ជនរងគ្រោះនៅក្នុងសវនាការ ឌុច ហាក់ដូចជាមានភាពរកាំរកូស ដោយបានចំណាយពេលវេលាច្រើន ហើយជារឿយៗមានការតវ៉ាតាមផ្លូវច្បាប់ពីសំណាក់ចៅក្រម ក៏ដូចជាសហព្រះរាជអាជ្ញា។ ដូច្នេះហើយតួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០២ ត្រូវបានរឹតបន្តឹងជាងមុន។ ការផ្លាស់ប្តូរគោលនយោបាយនេះអាចបន្ការបាន ប៉ុន្តែវាមិនបានបង្ហាញពីការទទួលខុសត្រូវរបស់ អ.វ.ត.ក ក្នុងការឆ្លើយតបដ៏ត្រឹមត្រូវចំពោះការស្នើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសវនាការ ឌុច នោះទេ។ ដើមបណ្តឹងរដ្ឋប្បវេណីទាំងនោះបានដើរតួនាទីយ៉ាងសកម្មនិងសំខាន់ ប៉ុន្តែ អ.វ.ត.ក បានធ្វើខុសដោយនឹងផ្តល់ឲ្យនូវសំណងជំងឺចិត្តផ្នែកផ្លូវចិត្ត ដោយមិនបានបំពេញនូវការរំពឹងចង់បានរបស់ពួកគាត់ ដោយសមហេតុផលទៅនឹងការប៉ះប៉ូវជារួមនោះទេ។

អ.វ.ត.ក គួរតែមានការច្នៃប្រឌិតច្រើនជាងនេះទាក់ទងទៅនឹងបញ្ហាសំណង។ វាមានលទ្ធភាពជាច្រើនដែលផ្តល់សំណងជាហិរញ្ញវត្ថុ។ អ.វ.ត.ក អាចជួយផ្តល់អនុសាសន៍ដល់ម្ចាស់ជំនួយ ឬសង្គមស៊ីវិល ឬសកម្មភាពណាមួយអនុវត្តដោយអង្គភាពផ្សេង បើទោះបីជាមិនអាចអនុវត្តជាក់ស្តែង ឬក៏ផ្តល់ជាមូលនិធិសម្រាប់សំណងដោយខ្លួនឯងក៏ដោយ។ ទស្សនៈដែលបានលើកឡើងដោយអ្នកដែលនៅរស់រានមានជីវិត និងសង្គមស៊ីវិលមិនមែនដាច់ខាតនោះទេ។ ពួកគាត់បានបញ្ជូនសំណើឲ្យមានការសាងសង់បូជនីយដ្ឋាន បុណ្យរំឭកសម្រាប់អ្នកដែលនៅរស់រានមានជីវិត ឬក៏បង្កើតជាទូសម្រាប់ដាក់វិភាគទានដែលប្រជាពលរដ្ឋទូទៅអាចបរិច្ចាគបានដើម្បីបំពេញតម្រូវការរបស់ជនរងគ្រោះ។ ការគាំទ្ររបស់ អ.វ.ត.ក ចំពោះគំនិតផ្តួចផ្តើមនេះអាចផ្តល់នូវថវិកាតិចតួច និងអាចមានផលប៉ះពាល់មិនល្អ ប៉ុន្តែវាបានផ្តល់នូវផលប៉ះពាល់តាមផ្លូវច្បាប់យ៉ាងខ្លាំងនិងមានន័យសម្រាប់អ្នកដែលនៅរស់រានមានជីវិត។ ជាសំណាងល្អ សាលក្រម ឌុច មិនមែនជាឱកាសចុងក្រោយរបស់អ.វ.ត.ក នោះទេ។ ប្រសិនបើ សហព្រះរាជអាជ្ញាធ្វើការប្តឹងឧទ្ធរណ៍នោះ សាលាឧទ្ធរណ៍របស់ អ.វ.ត.ក អាចធ្វើវិសោធនកម្មបាន។ មិនតែប៉ុណ្ណោះ អ.វ.ត.ក អាចមានឱកាសម្តងទៀតនៅពេលបញ្ចប់សំណុំរឿង ០០២។

អ.វ.ត.ក មិនអាចបំពេញចិត្តអ្នកដែលនៅរស់រានមានជីវិតពីគុកទួលស្លែង និងសមាជិកក្រុមគ្រួសាររបស់ពួកគេទាំងស្រុងបានទេ។ កាតព្វកិច្ចរបស់ អ.វ.ត.ក គឺអនុវត្តនូវការកាត់ទោសដោយមិនលម្អៀង ប្រកាសសាលក្រមដែលគួរឲ្យជឿទុកចិត្តបានពីភាពមានកំហុស ឬគ្មានកំហុស ដាក់ទោសដោយសមស្របនិងផ្តល់នូវសំណងជាសមូហភាពដែលសមរម្យមួយ។ អ.វ.ត.ក បានបំពេញនូវកាតព្វកិច្ចដំបូងពីរក្នុងចំណោមកាតព្វកិច្ចទាំងអស់នោះ ហើយប្រហែលជាកាតព្វកិច្ចចាំបាច់បំផុតសម្រាប់តុលាការព្រហ្មទណ្ឌផ្សេងទៀត។ អ.វ.ត.ក ក៏បានបង្ហាញពីការខិតខំប្រឹងប្រែងក្នុងការដាក់ទណ្ឌកម្ម ឌុច យ៉ាងសមហេតុផល បើទោះបីជាមានបញ្ហារកាំរកូសបន្តិចបន្តួចក៏ដោយ។ អ្វីដែលនឹងត្រូវពង្រឹងបន្ថែមសម្រាប់ដំណើរការនាពេលខាងមុខទៀតនោះ គឺការគ្រប់គ្រងដំណើរការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីឲ្យមានប្រសិទ្ធភាព។ បើមិនដូច្នោះទេ ដំណើរការរបស់ អ.វ.ត.ក នឹងជួបប្រទះនូវបញ្ហាដោយមិនបានបំពេញនូវតម្រូវការដែលអ្នកដែលនៅរស់រានមានជីវិតចង់បាន។ **ចន ឆរធីអារី**

# ឌុច ដែលត្រូវកាត់ទោសឱ្យជាប់ពន្ធនាគាររយៈពេល៣៥ឆ្នាំ នឹងត្រូវឃុំឃាំងតែ១៩ឆ្នាំប៉ុណ្ណោះ

នៅថ្ងៃនេះ ៣៥ឆ្នាំ ៣ខែ និង១០ថ្ងៃ បន្ទាប់ពីខ្មែរក្រហមចូលមកដល់ភ្នំពេញ និង៣១ឆ្នាំ ៦ខែ និង ១៩ថ្ងៃ បន្ទាប់ពីកងទ័ពវៀតណាមបានបណ្តេញខ្មែរក្រហមចេញពីអំណាច កាំង ហ្កេកអ៊ាវ ហៅ ឌុច ប្រធានគុកទួលស្លែង (ស-២១) គឺជាជនដំបូងគេដែលត្រូវដាក់ឲ្យទទួលខុសត្រូវចំពោះតុលាការដែលមានបទដ្ឋានអន្តរជាតិសម្រាប់ការកាត់ទោសដោយយុត្តិធម៌ ។ នៅពេលព្រឹក ប្រជាជនកម្ពុជាគ្រប់វ័យនិងមកពីកន្លែងផ្សេងគ្នាដែលមានចំនួនលើសពីមួយពាន់នាក់បានមកដល់ខ្លោងទ្វារនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីស្តាប់ការប្រកាសសេចក្តីសម្រេចរបស់ចៅក្រម ។ ប្រជាជនខ្លះបានប្រមូលផ្តុំក្នុងទីធ្លានៃអង្គជំនុំជម្រះដើម្បីមើលការចាក់ផ្សាយពីសេចក្តីសម្រេច ខណៈពេលដែលអ្នកផ្សេងទៀតមានឱកាសចូលទៅក្នុងបន្ទប់សវនាការដោយផ្ទាល់ ។ អ្នកចូលទស្សនាដែលមកដល់ទីធ្លាបរិវេណតុលាការបានជួបជាមួយអ្នកសារព័ត៌មានជាតិនិងអន្តរជាតិដែលបង្កើតជាឱកាសដ៏ពិសេសសម្រាប់ព្រឹត្តិហេតុជាតិនិងអន្តរជាតិទាក់ទងនឹងការដាក់ឲ្យមានការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម ។

ទីធ្លាសាធារណៈរបស់តុលាការមានពោរពេញទៅដោយមនុស្សជាច្រើនដូចជា ដើមបណ្តឹងរដ្ឋប្បវេណីដែលជាអ្នកនៅរស់ពីទួលស្លែងនិងសាច់ញាតិរបស់អ្នកដែលទទួលទណ្ឌកម្មនិងសម្លាប់នៅក្នុងគុក ក្រុមគ្រួសាររបស់អ្នកទាំងនោះ អ្នកភូមិមកពីតំបន់នានានៃប្រទេសកម្ពុជា ព្រះសង្ឃដែលមានស្បង់ចីពរពណ៌ទឹកក្រូច ជនបរទេសដែលមានតួនាទីសំខាន់ និងក្រុមអ្នកសារព័ត៌មាន និងសមាជិកអង្គការក្រៅរដ្ឋាភិបាលដែលធ្វើការទាក់ទងនឹងសិទ្ធិមនុស្សជាតិ និងអន្តរជាតិ ។ អ្នកដាក់ពាក្យធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីមួយក្រុមដែលមានចំនួន១៥នាក់ ហើយមួយចំនួននៃអ្នកទាំងនោះធ្លាប់បានចូលរួមស្ទើរតែគ្រប់ដំណើរការនីតិវិធីបានអង្គុយនៅពីក្រោយមេធាវីនៅក្នុងបន្ទប់សវនាការប្រឈមមុខនឹង ឌុច និងមេធាវីរបស់គាត់ ។ គួរឲ្យកត់សម្គាល់ដែរថា អ្នកដែលអវត្តមាននៅតុលាការគឺ ហ្វ្រង់ស័រ រូហ្វ មេធាវីអន្តរជាតិរបស់ ឌុច ដែលត្រូវបានផ្លាស់ប្តូរ និងដកពីតំណែងពីរសប្តាហ៍មុនបន្ទាប់ពី ឌុច បានឲ្យដំណឹងទៅអង្គភាពគាំពារការការពារក្តីថាគាត់បានបាត់បង់ភាពជឿជាក់ទៅលើលទ្ធភាពរបស់លោក រូហ្វ ក្នុងការផ្តល់ការតំណាងឲ្យមានប្រសិទ្ធភាព ។

ក្រុមមនុស្សបានក្រោកឈរឡើងនៅម៉ោង១០គត់នៅពេលដែលចៅក្រមចូលទៅក្នុងបន្ទប់សវនាការដើម្បីអានសេចក្តីសម្រេចដែលត្រូវគេរង់ចាំជាយូរណាស់មកហើយ ។ ប្រធានអង្គជំនុំជម្រះចៅក្រម និល ណុន ដែលកំពុងតែនិយាយនៅក្នុងសវនាការបានហៅ ឌុច ឲ្យក្រោកឈរឡើងដើម្បីស្តាប់សេចក្តីសម្រេចដែលត្រូវបានប្រកាសជាសាធារណៈ ។ ឌុច ដែលពាក់វ៉ែនតា និងអាវពណ៌ខៀវមានឡេវមួយជួរចុះក្រោមបានសម្លឹងមើលទៅសាធារណជនមួយភ្លែតខណៈពេលដែលគាត់ក្រោកឈរឡើង ក្រោយពីនោះគាត់អង្គុយយ៉ាងស្ងៀមស្ងាត់ហាក់ដូចជាចូលរួម


អ្នកភូមិឡើងសួរសំណួរ ក្រោយពីមើលការផ្សាយបន្តផ្ទាល់សាលក្រម ឌុច

នៅក្នុងដំណើរការនីតិវិធដែរ ។

តុលាការបានសង្កត់ធ្ងន់ទៅលើសាលក្រម ដែលជាសេចក្តីសម្រេចប្រឆាំងនឹងកម្មាភិបាលជាន់ខ្ពស់ខ្មែរក្រហម ។ តុលាការបានពន្យល់ថា ឌុច ត្រូវប្រឈមមុខនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាក្រុងហ្សឺណែវ (ជាទូទៅសំដៅលើឧក្រិដ្ឋកម្មសង្គ្រាម) និងការរំលោភបំពានទៅលើក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ។ ប៉ុន្តែ ដោយសារតែមិនមានចៅក្រមបួនរូបយល់ស្របនឹងបញ្ហាអាជ្ញាយុកាលនៃឧក្រិដ្ឋកម្មដែលស្ថិតនៅក្រោមក្រមព្រហ្មទណ្ឌកម្ពុជា ចៅក្រមបានសម្រេចថាចៅក្រមខ្វះខាតយុត្តាធិការដើម្បីពិចារណាទៅលើឧក្រិដ្ឋកម្មទាំងនេះ ។

តុលាការបានរកឃើញចំណុចសំខាន់ដែលអាចបង្ហាញពីបរិបទនយោបាយនិងប្រវត្តិសាស្ត្រនៃរបបកម្ពុជាប្រជាធិបតេយ្យដូចជាស្ថានភាពនៃជម្លោះប្រដាប់អាវុធអន្តរជាតិដែលកើតមានរវាងវៀតណាមនិងកម្ពុជានៅអំឡុងរបបកម្ពុជាប្រជាធិបតេយ្យដែលមានន័យថាចុងចោទអាចត្រូវបានកាត់ទោសពីឧក្រិដ្ឋកម្មសង្គ្រាមនិងគណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជាដែលគ្រប់គ្រងប្រទេសកម្ពុជាប្រជាធិបតេយ្យ ។ តុលាការក៏បានសង្កត់ធ្ងន់ទៅលើអង្គហេតុដែលថា នួន ជា គឺជាអ្នកបញ្ជាលើឌុច ដោយផ្ទាល់បើមើលទៅតាមឋានានុក្រមនៃបក្សកុម្មុយនីស្តកម្ពុជា ។ នេះគឺជាការរកឃើញដែលអាចជួយដល់ករណី០០២ ។

បន្ទាប់មក ចៅក្រមបានអានបទឧក្រិដ្ឋដែល ឌុច ត្រូវបានចោទប្រកាន់ ។ ទោះបីជា ឌុច បានសារភាពពីឧក្រិដ្ឋកម្មជាច្រើនដែលខ្លួនបានប្រព្រឹត្តនៅអំឡុងសវនាការក៏ដោយ ប៉ុន្តែអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនមានបញ្ញត្តិអាចទទួលស្គាល់ការសារភាពទោសរបស់ ឌុច ទាំងអស់នោះទេ ដូច្នេះតុលាការបានពិនិត្យមើលរាល់ភ័ស្តុតាង និងប្រកាសថា ឌុច ត្រូវជាប់ទោសចំពោះរាល់ឧក្រិដ្ឋកម្មលើកលែងតែឧក្រិដ្ឋកម្មជាតិពីព្រោះវាខ្វះយុត្តាធិការដូចដែលបានបញ្ជាក់ខាងលើ ។

ជាសរុបសេចក្តី ឌុច ត្រូវបានជាប់ពិរុទ្ធភាពពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលមានការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយ ការសម្លាប់រង្គាល ការធ្វើឲ្យមានទាសភាព ការដាក់នៅក្នុងមន្ទីរឃុំឃាំង និងការធ្វើទារុណកម្ម ការរំលោភមួយករណីនិងសកម្មភាពអមនុស្សធម៌ផ្សេងទៀត ។ ឌុច ត្រូវបានជាប់ពិរុទ្ធភាពពីឧក្រិដ្ឋកម្មសង្គ្រាមដែលមានការសម្លាប់ដោយចេតនាការធ្វើទារុណកម្ម ចេតនាបង្កឲ្យមានការឈឺចាប់និងរបួសស្នាមបំបិទសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ពីប្រជាជនស៊ីវិលនិងអ្នកទោសសង្គ្រាមនិងឃុំឃាំងប្រជាជនស៊ីវិលដោយខុសច្បាប់ ។

ទោះបីជាតុលាការបានសន្និដ្ឋានថា វាមិនមានភ័ស្តុតាងគ្រប់គ្រាន់សម្រាប់បង្ហាញថា ឌុច បានធ្វើទារុណកម្មជនរងគ្រោះនិងប្រព្រឹត្តអំពើអមនុស្សធម៌ផ្សេងទៀតដោយផ្ទាល់ក៏ដោយ ក៏វាបង្ហាញថា ឌុច បានចូលរួមក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មដែលជាផ្នែកមួយនៃសហកម្មឧក្រិដ្ឋកម្មរួមដែរ ។ ឌុច បានធ្វើការ និងគ្រប់គ្រងលើការធ្វើឧក្រិដ្ឋកម្មដើម្បីពង្រីកនូវគោលបំណងនៃសហកម្មឧក្រិដ្ឋកម្មរួម ។ ចំពោះគោលបំណងនៃការផ្តន្ទាទោស តុលាការក៏បានសង្កត់ធ្ងន់ថា ឌុច បានរៀបចំផែនការបញ្ជា និងញុះញង់និងជំរុញឲ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្មជាច្រើន ដូច្នេះ ឌុច ត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅមន្ទីរស-២១ស្ថិតនៅក្រោមបញ្ជារបស់ថ្នាក់លើ ។

តុលាការបានបដិសេធនឹងការការពារខ្លួនពីព្រោះវាជាបញ្ជាថ្នាក់លើដែលលើកឡើងដោយមេធាវីការពារក្តីរបស់ ឌុច និងវាមិនត្រូវបានគេទទួលស្គាល់ថាជាការការពារមួយសម្រាប់ឧក្រិដ្ឋកម្មអន្តរជាតិរបស់ ឌុច ទេ ។ តុលាការក៏បានបដិសេធនឹងការអះអាងរបស់ ឌុច ដែលថាគាត់ប្រព្រឹត្តឧក្រិដ្ឋកម្មដោយការបង្ខំពីព្រោះមានភ័ស្តុតាងបញ្ជាក់ថាគាត់មិនត្រឹមតែចូលរួមក្នុងសហកម្មឧក្រិដ្ឋកម្មរួមទេ ថែមទាំងរួមចំណែកក្នុងការរៀបចំផែនការទៀតផង ។

មុនពេលប្រកាសការផ្តន្ទាទោស ឌុច តុលាការបានដោះស្រាយនឹងដើមបណ្តឹងរដ្ឋប្បវេណី ។ ដោយសង្កត់ធ្ងន់ទៅលើសារសំខាន់នៃការបង្ករបួសស្នាមដោយផ្ទាល់និងការបង្កើតទំនាក់ទំនងជាធម្មតាជាមួយជនត្រូវចោទ តុលាការបានទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណីចំនួន៧០រូប និងអានឈ្មោះអ្នកទាំងនោះព្រមជាមួយនឹងទំនាក់ទំនងទៅនឹងឧក្រិដ្ឋកម្មនៅស-២១ និងជើងឯក ។ អ្វីដែលគួរឲ្យតក់ស្លុតចំពោះដើមបណ្តឹងរដ្ឋប្បវេណីខ្លះគឺការបដិសេធ

នឹងពាក្យបណ្តឹងមួយចំនួន ។ អ្នកដែលត្រូវបានបដិសេធដឹងពីសេចក្តីសម្រេចរបស់តុលាការនៅពេលដែលតុលាការបានបញ្ចប់ការអានបញ្ជីឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានទទួលស្គាល់ ។ បន្ទាប់មក តុលាការបាននិយាយពីសំណងជំងឺផ្លូវចិត្ត និងជារួមដែលអ្នកទាំងនោះអាចទទួលបានដោយយោងទៅតាមច្បាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ តុលាការបានប្រកាសថាឈ្មោះរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នឹងត្រូវបានសរសេរនៅក្នុងសេចក្តីសម្រេចព្រមជាមួយនឹងសេចក្តីរៀបរាប់ពីការពាក់ព័ន្ធរបស់អ្នកទាំងនោះនៅស-២១ និងសាច់ញាតិដែលបាត់ខ្លួន ។ តុលាការក៏បានសន្យាថានឹងដាក់បង្ហាញពីការសុំអភ័យទោសនិងការសោកស្តាយរបស់ ឌុច ដែលធ្វើឡើងនៅអំឡុងពេលជំនុំជម្រះនៅលើគេហទំព័ររបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ តុលាការមិនបានផ្តល់សំណងផ្សេងទៀតទេពីព្រោះតុលាការមិនមានយុត្តាធិការបង្ខំឲ្យរដ្ឋាភិបាលអនុវត្តនូវការផ្តល់សំណងឡើយ ។ នេះគឺជាសេចក្តីសន្និដ្ឋានបញ្ចប់ដែលធ្វើឲ្យដើមបណ្តឹងរដ្ឋប្បវេណីមិនសប្បាយចិត្តទោះបីជាវាមិនមែនជាការដែលមិនបានរំពឹងទុកក៏ដោយ ។

ជាទីបញ្ចប់ ចៅក្រម និល ណុន បានបញ្ជាឲ្យ ឌុច ក្រោកឈរនៅពេលដែលគាត់ប្រកាសពីការផ្តន្ទាទោស ។ តុលាការបានពន្យល់ថា តុលាការបានពិចារណាទៅលើកត្តាជំរុញមួយចំនួនដូចជាការសហការជាមួយតុលាការ ការបង្ហាញពីពិរុទ្ធភាពរបស់ខ្លួននិងការសោកស្តាយដែលមានកំណត់និងស្ថានភាពបង្ខំនៃរបបកម្ពុជាប្រជាធិបតេយ្យនិងកត្តាអាក្រក់មួយចំនួនដូចជាសារធាតុដ៏អាក្រក់របស់ឧក្រិដ្ឋកម្ម និងរយៈពេលដ៏យូរនៃរបបនោះ ។ សាធារណជនបានបន្ទឺសំឡេងសងទៅវិញ និងបង្ហាញពីអារម្មណ៍ខណៈពេលដែលតុលាការប្រកាសថា ឌុច ត្រូវបានផ្តន្ទាទោសឲ្យជាប់ពន្ធនាគារ៣៥ឆ្នាំចំពោះឧក្រិដ្ឋកម្មដែលគាត់ប្រព្រឹត្តនៅមន្ទីរស-២១ ។

ទោះបីជាយ៉ាងណាក៏ដោយ ក៏ការផ្តន្ទាទោស ឌុច ត្រូវបានកាត់បន្ថយប្រាំឆ្នាំដោយសារតែការឃុំខ្លួនមិនស្របច្បាប់ពីឆ្នាំ១៩៩៩-២០០៧ នៅក្នុងតុលាការយោធា ។ ឌុច ក៏ត្រូវបានកាត់បន្ថយ១១ឆ្នាំទៀត ពីព្រោះគាត់បានជាប់ឃុំឃាំង១១ឆ្នាំមកហើយ ចាប់តាំងពីការចាប់ខ្លួនគាត់ដំបូង ។ ជាសរុបមក ឌុច ត្រូវនៅជាប់ពន្ធនាគារតែ១៩ឆ្នាំទៀតប៉ុណ្ណោះ ។ វាមានន័យថា ឌុច ដែលមានអាយុ៦៧ឆ្នាំ ប្រហែលជាអាចមានសេរីភាពម្តងទៀត ។ តុលាការបានបញ្ជាឲ្យ ឌុច ត្រឡប់ទៅមន្ទីរឃុំឃាំងវិញ ។ ឌុច បានចាកចេញដោយស្ងៀមស្ងាត់ដូចនៅពេលដែលគាត់មកដល់បន្ទប់សវនាការដែរ ហើយជនរងគ្រោះនិងអ្នកតាមដានតុលាការបានចាកចេញនិងបញ្ចេញប្រតិកម្មចំពោះសេចក្តីសម្រេចជាប្រវត្តិសាស្ត្រនេះ ។

ខណៈពេលដែលមានមនុស្សជាច្រើនប្រមូលផ្តុំគ្នានៅក្រៅអគារតុលាការ មានមតិជាច្រើនបានរួមបញ្ចូលគ្នា ។ មានអ្នកខ្លះបានយំ និងអ្នកខ្លះទៀតបង្ហាញពីការពេញចិត្តនឹងសាលក្រម ។ ក្រុមអ្នកឃ្លាំមើលសាលាក្តីខ្មែរក្រហមបានជួបសម្ភាសន៍ជាមួយបុគ្គលមួយចំនួនដែលមានយោបល់ផ្សេងៗគ្នា ។ សេង ធារី ដើមបណ្តឹងរដ្ឋប្បវេណីក្នុងករណី០០២ និងសកម្មជនសង្គមស៊ីវិលបានរិះគន់ថាការផ្តន្ទាទោសមានលក្ខណៈស្រាលពេក ហើយគាត់បានសង្កត់ធ្ងន់ទៀតថា ១៩ឆ្នាំទៀតនៅក្នុងគុកគឺមានន័យថា ឌុច នឹងត្រូវទទួលទោសរយៈតិចជាង១១ម៉ោងសម្រាប់ជីវិតមនុស្សម្នាក់ ។ រ៉ូប៊ឺត ហាមីល ដើមបណ្តឹងរដ្ឋប្បវេណីមកពីប្រទេសញ៉ូវហ្សេឡេន ដែលមានបងប្អូនប្រុសត្រូវបានចាប់ខ្លួនដោយខ្មែរក្រហមបន្ទាប់មកត្រូវបានធ្វើទារុណកម្មនិងសម្លាប់នៅមន្ទីរស-២១ បន្ទាប់ពីចតទូកក្តោង នៅជិតឆ្នេរកម្ពុជាបានបង្ហាញពីការពេញចិត្តនឹងសេចក្តីសម្រេចពីព្រោះវាប្រហាក់ប្រហែលនឹងរយៈពេល៤០ឆ្នាំដែលបានស្នើសុំ ។ ទោះបីជាយ៉ាងណាក៏ដោយគាត់បានសួរថាហេតុអ្វីបានជាព្រះរាជអាជ្ញាស្នើសុំឲ្យមានការឃុំខ្លួនដែលគាត់គិតថាតិចនិងបង្ហាញពីការព្រួយបារម្ភថា ឌុច ប្រហែលជាចេញពីគុកដោយមានសេរីភាពម្តងទៀត ។

ទោះបីជាមានទស្សនៈផ្សេងគ្នាទាក់ទងនឹងសាលក្រមនេះក៏ដោយ ក៏ប្រជាជនទាំងអស់គ្នាសុទ្ធតែទទួលស្គាល់ថា វាគឺជាថ្ងៃសំខាន់នៅក្នុងប្រវត្តិសាស្ត្រកម្ពុជា ហើយវាប្រហែលជាជំហានតូចមួយឆ្ពោះទៅកាន់ការផ្សះផ្សានិងការទទួលខុសត្រូវនៅក្នុងប្រទេសដែលបានរងចាំយុត្តិធម៌អស់រយៈពេលជាយូរមកហើយ ។

**ម៉ៃឃើល សាលីបា និង ថៃលើ នីមស៍**

# ភាពច្របូកច្របល់ និងការមិនពេញចិត្ត បន្ទាប់ពីការប្រកាសសាលក្រម ឌុច

សាលក្រមនៅក្នុងសំណុំរឿង០០១ នៃសាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហមដែលជាប់ពាក់ព័ន្ធនឹងអតីតប្រធានមន្ទីរ ស-២១ កាំង ហ្គេកអ៊ាវ ហៅ ឌុច បានប្រកាសក្នុងទិដ្ឋភាពចង់ដឹងយ៉ាងខ្លាំងអំពីការផ្ទុះបញ្ចាំងដ៏ធ្ងន់ធ្ងរនិងក្នុងភាពច្របូកច្របល់នេះ បានធ្វើឲ្យប្រជាជនជាច្រើនអាក់អន់ចិត្តច្រើនជាងការពេញចិត្ត ។ ឌុច ត្រូវបានសម្រេចឲ្យដាក់ពន្ធនាគាចំនួន១៩ឆ្នាំ ក្រោមការចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការរំលោភបំពានធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ ចំពោះអំពើឃោរឃៅដែលបានប្រព្រឹត្តឡើងនៅមន្ទីរស-២១ ដែលបណ្តាលឲ្យមនុស្សយ៉ាងហោចណាស់១៤,០០០នាក់ ស្លាប់បាត់បង់ជីវិត ។ ចំនួនតួលេខនៃការដាក់ពន្ធនាគានេះត្រូវបានបន្ថយពីចំនួន៣៥ឆ្នាំ បន្ទាប់ពីការពិចារណាទៅលើស្ថានសម្រាលទោស ។ សាលក្រមជាប្រវត្តិសាស្ត្រនេះគឺជាសាលក្រមលើកដំបូងដែលបានបង្ហាញពីភាពឃោរឃៅហួសនឹងពិពណ៌នាបានកើតឡើងនៅក្នុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩) ដែលទទួលខុសត្រូវចំពោះការស្លាប់មនុស្សអស់ជិតពីរលាននាក់ ។ នេះក៏ជាសាលក្រមមួយដែលបង្ហាញពីការមិនពេញចិត្តនិងធ្វើឲ្យមានការភាន់ច្រឡំចំពោះប្រជាពលរដ្ឋកម្ពុជាដែលនៅរស់រានមានជីវិតពីរបបដ៏ឃោរឃៅនេះ ។ ប្រជាពលរដ្ឋជាច្រើនរំពឹងទុកថា តុលាការនឹងប្រកាសពីការដាក់ពន្ធនាគារចំនួន៤០ឆ្នាំ តែផ្ទុយទៅវិញតួលេខពិតប្រាកដតិចជាងពាក់កណ្តាលទៅទៀត គឺត្រឹមតែ១៩ឆ្នាំប៉ុណ្ណោះ ។ ជាមួយនឹងការយល់ច្រឡំកាលពីដំបូងដែលថា ការដាក់ពន្ធនាគារចំនួន៣៥ឆ្នាំ ដែលបានប្រកាសនៅក្នុងសាលក្រមវារឹតតែធ្វើឲ្យការរំពឹងរបស់ប្រជាពលរដ្ឋយល់ថា លែងមានយុត្តិធម៌ដោយសារដាក់ទោសតែ



អ្នកភូមិតម្រង់ជួរចូលស្តាប់ការប្រកាសសាលក្រម ឌុច នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

១៩ឆ្នាំប៉ុណ្ណោះ ។

## ការអានសាលក្រម

ប្រហែលជាប៉ុន្មាននាទីមុនម៉ោង១០ព្រឹក នៅក្នុងសាលសវនាការដែលមានកៅអីអង្គុយចំនួន៥០០ កៅអី វាំងននពណ៌ខៀវចាស់ដែលចងនៅពីក្រោយកញ្ចក់បិទជិតត្រូវបានបើកនៅពីមុខអ្នកចូលរួមដែលរួមមានអ្នកនៅរស់រានមានជីវិតពីរបបខ្មែរក្រហម ព្រះសង្ឃ និស្សិតមហាវិទ្យាល័យ អ្នកស្រាវជ្រាវ អ្នកមុខអ្នកការ ហើយនិងអ្នកសារព័ត៌មាន ។ នៅពេលដែលវាំងននបើក បុគ្គលិកមន្ត្រីតុលាការបានអង្គុយរួចជាស្រេចក្បែរនឹងសាក្សីសំខាន់ៗ ។ ពីរ-បីនាទីក្រោយមក ឌុច បានដើរចូលក្នុងបន្ទប់សវនាការដែលអមដំណើរដោយសន្តិសុខពីរនាក់ ។ ឌុច ស្លៀកសម្លៀកបំពាក់យ៉ាងផ្ចិតផ្ចង់ ពាក់អាវដៃវែងពណ៌ខៀវខ្ចីដោយមានអាវយឺតពណ៌សនៅខាងក្នុង ហើយស្លៀកខោពណ៌ប្រផេះមានពាក់ខ្សែក្រវ៉ាត់ពណ៌ខ្មៅជាមួយក្បាលខ្សែក្រវ៉ាត់ផលិតពីលោហៈធាតុ ។ អ្វីដែលចម្លែក គឺឯកសណ្ឋានរបស់ ឌុច ហាក់ដូចជាស៊ីគ្នាជាមួយពណ៌របស់វាំងននិងជញ្ជាំងកញ្ចក់ភ្ជាប់ជាមួយនឹងបន្ទះដែកយ៉ាងក្រាស់ដែលសម្លៀកបំពាក់នោះដុយគ្នានឹងព្រះសង្ឃដែលស្ថិតក្នុងស្បង់ចីវរពណ៌ទឹកក្រូចអង្គុយនៅជួរកណ្តាលខាងមុខ ។

មុនពេលប្រកាសសាលក្រមបានចាប់ផ្តើម ឌុច អង្គុយផ្អែកកៅអីរបស់គាត់ ដោយសម្លែងនូវទឹកមុខមាំ ។ ពេលនោះដែរភ្នែកពណ៌ខ្មៅរបស់គាត់បានងាកចុះឡើងនៅពេលដែលខ្លួនរបស់គាត់ស្ថិតក្នុងសភាពស្ងប់ស្ងាត់ ។ នៅពេលដែលអានសាលក្រមបានប្រហែលជាពាក់កណ្តាល ឌុច បានងើបទៅមុខ រួចយកដៃរបស់គាត់ដាក់នៅលើតុជិតនឹងដបទឹករបស់គាត់ ។ នៅពេលដែលការសង្ខេបសាលក្រមជិតបញ្ចប់ ឌុច បានបង្ហាញកែវភ្នែកដែលពោរពេញទៅដោយភាពមាំទាំរបស់ខ្លួន ។ នៅពេលដែលចៅក្រមប្រកាសការដាក់ពន្ធនាគារចំនួន៣៥ឆ្នាំ សំឡេងខ្សឹបខ្សៀវគ្នានៅក្នុងចំណោមអ្នកចូលរួមស្តាប់បានចាប់ផ្តើមជាមួយនឹងការមិនពេញចិត្ត និងការខកចិត្ត ។ រីឯ ឌុច វិញកំពុងតែឈរយ៉ាងត្រង់ខ្លួន ប៉ុន្តែភ្នែករបស់គាត់ចាប់ផ្តើមក្រហម ។ ការប្រកាសសាលក្រម


សាធារណជនអង្គុយស្តាប់ការប្រកាសសាលក្រម ឌុច នៅក្រៅបន្ទប់សវនាការ

បានបញ្ចប់នៅម៉ោង១១ព្រឹក ហើយ ឌុច ត្រូវបានបណ្តើរចេញពីបន្ទប់សវនាការ ។

## ការឆ្លើយតបពីសាលសវនាការ

ទស្សនីយភាពដែលបានកើតកាលពីព្រឹកនៅថ្ងៃប្រកាសសាលក្រមដែលចាប់ផ្តើមដំបូង គឺការផែកឆេរដើម្បីសុវត្ថិភាព ហើយនិងការអង្គុយគ្មានសណ្តាប់ធ្នាប់របស់អ្នកអង្កេតការណ៍ជាតិ និងអន្តរជាតិ ហើយស្ថានភាពចាប់ផ្តើមរៀបរយនៅពេលដែលសាលក្រមត្រូវបានប្រកាស ។ ក្រៅពីអ្នកចូលរួមតាមដាន នៅខាងក្នុងបន្ទប់សវនាការមានមនុស្សជាច្រើនទៀតអង្គុយនៅលើកៅអីជ័រដែលដាក់នៅលើទីធ្លាខាងក្រៅបន្ទប់សវនាការ ជាងនេះទៅទៀត មានប្រជាពលរដ្ឋរាប់លាននាក់ផ្សេងទៀតកំពុងតាមដានសវនាការ ឌុច នៅទូទាំងប្រទេស រួមជាមួយនឹងប្រតិកម្មយ៉ាងខ្លាំង ។

អ្នកដែលចូលរួមស្តាប់នាំគ្នាដើរចេញពីបន្ទប់សវនាការ បន្ទាប់ពីសាលក្រមបានបញ្ចប់ ហើយការខ្សឹបខ្សៀវក៏ចាប់ផ្តើមមាន ។ មតិជាច្រើនបានលើកឡើងថា «ការដាក់ទោសមានភាពមិនច្បាស់លាស់ថាតើ ឌុច ត្រូវជាប់គុកប៉ុន្មានឆ្នាំ?» អ្នកភូមិដែលមានចំណេះដឹងតិចតួច អ្នករាយការណ៍ដែលស៊ាំនឹងដំណើរការច្បាប់ ហើយនិងអ្នកស្រាវជ្រាវដែលបង្រៀនជាច្រើនឆ្នាំចាប់ផ្តើមពិចារណាអំពីតួលេខពិតប្រាកដ ។ «ចៅក្រមប្រកាសថា ៣៥ឆ្នាំនៅក្នុងពន្ធនាគារ ប៉ុន្តែត្រូវដកចេញប្រាំឆ្នាំសម្រាប់ការឃុំខ្លួនខុសច្បាប់នៅតុលាការយោធា ហើយនិងប្រាំបីឆ្នាំទៀតដែល ឌុច ត្រូវបានឃុំនៅក្នុងតុលាការយោធា ព្រមទាំងបីឆ្នាំទៀតសម្រាប់ការឃុំខ្លួនបណ្តោះអាសន្ននៅក្នុងតុលាការ... ដូច្នេះ... ឈប់សិន តើ ៥ឆ្នាំបន្ថែមនោះផ្តល់ឲ្យសម្រាប់ការឃុំខ្លួននៅតុលាការយោធាអស់រយៈពេល៩ឆ្នាំឬ?» មនុស្សមួយចំនួនបានបញ្ចូលស្ថានសម្រាលទោសដែល ឌុច បានសហការជាមួយតុលាការនៅក្នុងការសន្និដ្ឋានរបស់ពួកគេ «ទេ គឺ ៣៥ឆ្នាំដក៩ឆ្នាំ ហើយដក៥ឆ្នាំសម្រាប់ការសហការជាមួយតុលាការ» ។ មនុស្សមួយចំនួនផ្សេងទៀតចាប់ផ្តើមមានភាពមិនប្រាកដប្រជាជាមួយតួលេខចាប់ផ្តើម «តើ៣៥ឆ្នាំហ្នឹងគិតបញ្ចូល៥ឆ្នាំដែលផ្តល់ឲ្យដោយការឃុំខ្លួនខុសច្បាប់ឬ? អ៊ីចឹងមានន័យថា ចំនួនដំបូងគឺ៤០ឆ្នាំដូចទៅនឹងអ្វីដែលសហព្រះរាជអាជ្ញាចង់បានឬ?» ក៏មានអ្នកចូលរួមជាច្រើនដែលមិនបានខ្វល់ខ្វាយពីការគិតតួលេខនេះទេ ហើយសន្មតថា ឌុច ជាប់ពន្ធនាគារចំនួន៣៥ឆ្នាំ ។ តួលេខ ៣៥ឆ្នាំ ជាតួលេខដែលអ្នកសារព័ត៌មានមួយចំនួនបានប្រើសម្រាប់ការរាយការណ៍លើកដំបូងរបស់ពួកគេចំពោះសាលក្រម ។

ខណៈពេលដែលអ្នកអង្កេតការណ៍មានការភាន់ច្រឡំ និងអស់សង្ឃឹមចំពោះសាលក្រមចុះពីលើកាំជណ្តើរមកដល់ទីធ្លាខាងមុខ អ្នកកាសែតនាំគ្នាប្រញាប់ប្រញាល់ដើម្បីថតរូបភាព ។ អ្នកសារព័ត៌មានផ្សេងទៀតកំពុងសម្ភាសន៍អ្នកចូលរួមដែលបានមើលការប្រកាសសាលក្រមនេះ នៅលើស្មៅខាងមុខបន្ទប់សវនាការ ។ ប៊ូ ម៉េង អ្នកដែលនៅរស់រានមានជីវិតពីមន្ទីរស-២១ ដ៏ល្បីល្បាញមួយរូប ហើយនិង ហ៊ឹម ហ៊ុយ ដែលជាអតីតប្រធានសន្តិសុខនៃមន្ទីរស-២១ ដែលប្រហែលជាល្បីល្បាញដែរនោះ ត្រូវបានឡោមព័ទ្ធដោយអ្នកសារព័ត៌មាន ។ អ្នកស្រាវជ្រាវ មន្ត្រីតុលាការ ប្រធានអង្គការសង្គមស៊ីវិល មន្ត្រីរដ្ឋាភិបាល និងអ្នកដែលនៅរស់រានមានជីវិតផ្សេងទៀតដែលកំពុងតែស្រែកយំគឺជាមុខសញ្ញា



ឌុច ស្តាប់ចៅក្រមអានសាលក្រម

លេចធ្លោសម្រាប់បទសម្ភាសន៍។

ហេតុការណ៍មួយដែលក្នុងនោះមានជនរងគ្រោះនៃរបបខ្មែរក្រហមបីនាក់នៅលើវាលស្មៅក្នុងទីធ្លាសវនាការមានភាពស្រងេះស្រងោច។ នង ចាន់ផល គឺជាអតីតកុមារមួយរូបដែលជាប់នៅមន្ទីរស-២១ និងទើបតែលេចមុខជាថ្មីប៉ុន្មានឆ្នាំចុងក្រោយនេះបន្ទាប់ពីការរស់នៅយ៉ាងស្ងប់ស្ងាត់អស់រយៈពេលជិតពីរទសវត្សរ៍។ នៅក្បែរនោះដែរ គឺស្ត្រីម្នាក់ដែលជានាយិកានៃអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកមួយត្រូវបានកាមេរ៉ារបស់អ្នកកាសែតប្រញាប់ប្រញាល់ចាប់យករូបភាពពីប្រតិកម្មរបស់អ្នកដែលនៅរស់រានមានជីវិត។ មុនពេលចូលក្នុងបន្ទប់សវនាការ នង ចាន់ផល ដែលមនុស្សភាគច្រើនមិនសូវស្គាល់ត្រូវបានអ្នកកាសែតម្នាក់ស្នើសុំធ្វើការថតនិងសម្ភាសន៍បន្ទាប់ពីការប្រកាសសាលក្រម។ នង ចាន់ផល ដែលហាក់ដូចជាភិតភ័យ ប៉ុន្តែពោរពេញទៅដោយបទពិសោធន៍បន្ទាប់ពីផ្តល់បទសម្ភាសន៍ជាច្រើននៅប៉ុន្មានឆ្នាំថ្មីៗនេះ បានយល់ព្រមតាមការស្នើសុំនេះ។ គាត់ត្រូវបានរៀបចំថតភ្លាមៗបន្ទាប់ពីបញ្ចប់ការប្រកាសសាលក្រម។ ជាងនេះទៅទៀត ស្ត្រីម្នាក់ដែលនៅរស់រានមានជីវិតផ្សេងទៀតដែលស្ថិតក្នុងស្ថានភាពខកចិត្ត និងឈឺចិត្តកំពុងស្រែកយំនៅពេលដែលគាត់ដើរចេញមកខាងក្រៅ។ ជាមួយនឹងសម្រែកយំរបស់គាត់ អ្នកសារព័ត៌មានជាច្រើនបានបញ្ច្រៀតគ្នាផ្តិតចាប់រូបភាពដ៏សោកសៅនេះ សូម្បីតែអ្នកកាសែតដែលបានសន្យាថានឹងធ្វើការថត នង ចាន់ផល ក៏ដោយ។ អតីតនាយិការូបនោះបានឆ្លៀតឱកាសចូលទៅឈរបាំង លោក នង ចាន់ផល ពីកញ្ចក់កាមេរ៉ា ហើយបានជួយបកប្រែស្ត្រីដែលកំពុងមានការតានតឹងក្នុងអារម្មណ៍នោះ។ ឃើញទិដ្ឋភាពបែបនេះ នង ចាន់ផល ដែលកំពុងតែវង្វេងវង្វាន់នឹងសោកសៅបន្ទាប់ពីបានឮការប្រកាសសាលក្រមបានធ្វើដំណើរចាកចេញតែម្នាក់ឯងទៅកាន់កន្លែងចតរថយន្ត ហើយដើរឡើងរថយន្តក្រុងដែលគាត់បានធ្វើដំណើរមកដើម្បីសម្រួលអារម្មណ៍ ក្រោយពីការប្រកាសសាលក្រម។ នង ចាន់ផល បានដើរចូលរថយន្តរហូតដល់រថយន្តចេញដំណើរ គួរឲ្យស្តាយ នង ចាន់ផល ដែលជាជនរងគ្រោះដ៏កម្រមួយរូបនៃមន្ទីរស-២១ មិនត្រូវបានផ្តល់បទសម្ភាសន៍បន្ទាប់ពីការប្រកាសសាលក្រមដែលជាប្រវត្តិសាស្ត្រនៃឧក្រិដ្ឋកម្មដែលបានកើតឡើងនៅគុកដ៏សាហាវឃោរឃៅនេះ។

ត្រឡប់ទៅក្នុងសាលសវនាការវិញ សន្និសីទកាសែតកំពុងតែដំណើរការ។ មនុស្សបួនក្រុមកំពុងតែអង្គុយជាជួរនៅពីមុខអ្នកសារព័ត៌មានដូចជា បុគ្គលិកផ្នែកកិច្ចការសាធារណៈនៃអ.វ.ត.ក សហព្រះរាជអាជ្ញា ដើមបណ្តឹងរដ្ឋប្បវេណីបីក្រុម ហើយនិងមេធាវីខាងការពារជនជាប់ចោទ (ដែលក្រោយមកបានលុបចោលវិញ)។ សំណួរដែលបានចោទសួរនៅក្នុងសន្និសីទកាសែតគឺទាក់ទងទៅនឹងរយៈពេលពិតប្រាកដដែល ឌុច ត្រូវឃុំឃាំង។ បន្ទាប់ពីទទួលបានចម្លើយមិនជាក់លាក់ពីសំណាក់ក្រុមទីមួយ អ្នកសារព័ត៌មានបានសាកសួរទៅកាន់លោកស្រី ជា លាង ដែលជាសហព្រះរាជអាជ្ញាជាតិនៅក្នុងក្រុមទីពីរ។ សហព្រះរាជអាជ្ញាបានចាប់ផ្តើមគិតពីស្ថានសម្រាលទោសពីមួយទៅមួយ ហើយជាលទ្ធផលគឺ១៨ឆ្នាំ ដែលវាហាក់ដូចជាខុសគ្នាបន្តិចពីចំនួន១៩ឆ្នាំដែលក្រុមមុនបានប្រាប់ ហើយវាកាន់តែខុសគ្នាថែមទៀតពីចំនួន៣៥ឆ្នាំដែលបានផ្សព្វផ្សាយមុននេះនៅក្នុងសារព័ត៌មាន។

## ប្រតិកម្មនៅទីក្រុងភ្នំពេញ

អស់រយៈពេលពេញមួយថ្ងៃ និងមួយល្ងាច លោក រាជ សម្បត្តិ ដែលជាប្រធានផ្នែកកិច្ចការសាធារណៈបានខិតខំពន្យល់អំពីសាលក្រមនិងស្ថានទម្ងន់ទោស ដោយបានបង្ហាញនូវសាលក្រមទាំងមូលដែលជាភាសាខ្មែរហើយមានកម្រាស់ជាង៤០០ទំព័រ។ ពេញមួយរាត្រី ប៉ុស្តិ៍វិទ្យុបានធ្វើការផ្សព្វផ្សាយពាសពេញផ្ទៃប្រទេសអំពីការពន្យល់របស់គាត់ ក៏ដូចជាការអត្ថាធិប្បាយរបស់អ្នកជំនាញ ហើយនិងបទសម្ភាសន៍ជាមួយអ្នកដែលនៅរស់រានមានជីវិត។ ប្រតិកម្មចំពោះសាលក្រមនេះមានភាពខុសប្លែកគ្នារហូតដល់ការសម្តែងនូវកំហឹងបើទោះបីជាមានមនុស្សភាគច្រើនមានការអាក់អន់ចិត្តក៏ដោយ។

មនុស្សមួយចំនួនដែលបានសម្ភាសន៍នៅតាមផ្លូវបាននិយាយថា គាត់មិនបានដឹងអំពីការប្រកាសសាលក្រមរបស់ ឌុច ទាល់តែសោះ ដោយសារតែគាត់មមាញឹកនឹងជីវភាពប្រចាំថ្ងៃ។ មនុស្សមួយចំនួនផ្សេងទៀតបានដឹងពីការប្រកាសសាលក្រមនៅថ្ងៃច័ន្ទ ប៉ុន្តែគាត់ហាក់ដូចជាបារម្ភអំពីការប្រឡងរបស់កូនគាត់នៅឯសាលាច្រើនជាង ដែលការប្រឡងនេះចាប់ផ្តើមដូនពេលជាមួយ

គ្នានៅថ្ងៃទី២៦ ខែកក្កដា ។ ការប្រឡងដែលមានរយៈពេលពីរថ្ងៃកន្លះ សិស្សអាចកំណត់បានថា គាត់អាចបញ្ចប់ការសិក្សានៅថ្នាក់វិទ្យាល័យ ហើយនិងលទ្ធភាពបន្តការសិក្សានៅមហាវិទ្យាល័យ ។

អ្នកដែលតាមដានសាលក្រមមួយចំនួនបានស្តាប់ការផ្សាយតាមរយៈវិទ្យុជាច្រើនម៉ោង ដោយក្នុងនោះ មាន រស់ សុខាល ដែលគាត់បានបាត់បង់ប្តីហើយនិងកូនដែលទើបតែកើតបាន១០ថ្ងៃមុនពេលដែលខ្មែរក្រហមកាន់កាប់អំណាច ព្រមទាំងសាច់ញាតិដទៃទៀតនៅក្នុងរបបខ្មែរក្រហម ។ លោកស្រី រស់ សុខាល ដែលរស់នៅទីក្រុងភ្នំពេញតែងតែតាមដានពីការវិវឌ្ឍរបស់តុលាការ ហើយបានស្តាប់ការប្រកាសសាលក្រមផងដែរនោះ ហាក់ដូចជាមិនទាន់បានយល់ច្បាស់ពីចំនួនឆ្នាំពិតប្រាកដដែលអំពី ឌុច ត្រូវឃុំខ្លួន ។ នៅក្នុងការិយាល័យហិរញ្ញវត្ថុនៃទីស្តីការគណៈរដ្ឋមន្ត្រី ដែលជាកន្លែងដែល សុខាល ធ្វើការ ទូរទស្សន៍បានបើក ហើយជូនមើលជូនអត់ ។ មនុស្សជាច្រើននៅក្នុងការិយាល័យរបស់គាត់ដូចគ្នាទៅនឹងប្រជាជនខ្មែរដទៃទៀតដែរសុទ្ធតែចាប់អារម្មណ៍ចង់ដឹងថា តើ ឌុច ត្រូវជាប់គុកប៉ុន្មានឆ្នាំ ។ ក្រោយពេលចៅក្រមអានសាលក្រមចប់ សុខាល និងសហការីរបស់គាត់មានក្តីអស់សង្ឃឹម និងច្របូលច្របល់ក្នុងចិត្ត លោកស្រី រស់ សុខាល បាននិយាយថា គាត់អាចទទួលយកបានប្រសិនបើ ឌុច ត្រូវដាក់គុកចំនួន៣៥ឆ្នាំ នេះមានន័យថាគាត់អាចនឹងស្លាប់នៅក្នុងគុក ។ ផ្ទុយទៅវិញ គាត់មិនអាចទទួលយកសាលក្រមនោះបានទេ ប្រសិនបើជា១៩ឆ្នាំវិញ ព្រោះ ឌុច អាចមានលទ្ធភាពនៅរស់បន្ទាប់ពីការជាប់ពន្ធនាគារ ។ លោកស្រី រស់ សុខាន់ និងសហការីរបស់គាត់បាន និយាយថាៈ «ឌុច ជាមនុស្សកំសាក ។ ភាពមាំ ស្ងប់ស្ងាត់ និងភាពអង់អាចរបស់គាត់ក្នុងការសម្លាប់មនុស្ស គឺផ្ទុយពីភាពកំសាករបស់គាត់» ។ បើយោងតាមលោកស្រី មនុស្សដូចជា ឌុច ដែលហ៊ានសម្លាប់អ្នកដទៃ ក៏គួរតែក្លាហានហ៊ានទទួលយកការដាក់ទោសឲ្យជាប់គុកមួយជីវិតដែរ ។ ការដាក់ទោសឲ្យជាប់គុកមួយជីវិត គឺជាហេតុផលមួយដែលលោកស្រីបានលើកឡើងថា វាមានភាពងាយស្រួលក្នុងការប្រៀបធៀបទៅនឹងការធ្វើទារុណកម្ម និងការសម្លាប់ដែល ឌុច


អ្នកយកព័ត៌មាននៅក្រៅបន្ទប់សវនាការ

បានប្រព្រឹត្តទៅលើមនុស្សជាងមួយម៉ឺននាក់ ។ នេះបានបញ្ជាក់យ៉ាងច្បាស់ថា លោកស្រី រស់ សុខាន់ មានការខូចចិត្ត និងសោកស្តាយចំពោះសាលក្រមនេះ ។

## ការស្ទាបស្ទង់មតិនៅទូទាំងប្រទេស

ប្រតិកម្មរបស់អ្នករស់រានមានជីវិតទូទាំងប្រទេសកម្ពុជាមានលក្ខណៈផ្សេងៗគ្នា ក៏ប៉ុន្តែប្រតិកម្មជាទូទៅគឺការខកចិត្ត និងការមិនពេញចិត្ត ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំការបញ្ចាំងសាលក្រម ឌុច ចំនួនប្រាំពីរខេត្ត រួមមាន កណ្តាល កំពង់ធំ បន្ទាយមានជ័យ កំពង់ចាម តាកែវ ស្វាយរៀង និងពោធិ៍សាត់ ។ ប្រជាពលរដ្ឋជាង២០០នាក់ បានចូលរួមទស្សនាការបញ្ចាំងសាលក្រមនេះតាមកន្លែងនីមួយៗ បើទោះបីជាខេត្តមួយចំនួនមានអ្នកចូលរួមតិចជាងនេះ ដោយសារគាត់ជាប់រវល់ស្ទូងស្រូវក៏ដោយ ។ ការស្ទូងស្រូវអាស្រ័យទៅតាមទំហំដីស្រែ ជួនកាលគេត្រូវចំណាយពេលពីរបីថ្ងៃ ឬរហូតដល់ទៅមួយសប្តាហ៍ដងក៏មានដើម្បីស្ទូងស្រូវនៅក្នុងអំឡុងរដូវវស្សាដែលចាប់ផ្តើមពីខែមិថុនាដល់ខែកញ្ញា ។ ប្រតិកម្មពីសំណាក់ខេត្តទាំងអស់នេះអាចបែងចែកទៅជាបួនក្រុម ៖ ទីមួយ) ក្រុមដែលគិតថា សាលក្រមមានរយៈពេល៣៥ឆ្នាំ ហើយមិនពេញចិត្តនឹងសាលក្រមនេះ ទីពីរ) ក្រុមដែលគិតថា រយៈពេល៣៥ឆ្នាំ ហើយអាចទទួលយកបាន ទី៣) ក្រុមដែលគិតថាសាលក្រមនេះមានរយៈពេល១៩ឆ្នាំ ហើយគាត់មានការខកចិត្តចំពោះសាលក្រមនេះ និងទីបួន) ក្រុមដែលគិតថាសាលក្រមមានរយៈពេល១៩ឆ្នាំ ហើយពេញចិត្ត ។ ប្រតិកម្មដែលគួរឲ្យចាប់អារម្មណ៍ទាំងនេះបានលេចឡើងនៅក្នុងចំណោមក្រុមផ្សេងៗតាមរយៈបទសម្ភាសន៍ដែលធ្វើឡើងភ្លាមៗក្រោយពីការប្រកាសសាលក្រមនេះ ។ ក្រុមដែលបដិសេធចំពោះសាលក្រម៣៥ឆ្នាំគិតថា អំពើសាហាវព្រៃផ្សៃរបស់ ឌុច គួរតែទទួលទោសធ្ងន់ជាងនេះ ឧទាហរណ៍ដូចជាជាប់គុកមួយជីវិតជាដើម ។ ទីពីរ អ្នកដែលទទួលយកបានចំពោះសាលក្រម៣៥ឆ្នាំនេះគិតថា ឌុច នឹងស្លាប់នៅក្នុងគុកជាមិនខាន ។ នៅក្នុងចំណោមអ្នកដែលបដិសេធចំពោះសាលក្រម១៩ឆ្នាំនេះ ភាគច្រើនគិតថា ១៩ឆ្នាំតិចពេកបើប្រៀបធៀបនឹងបទឧក្រិដ្ឋដែលគាត់បានប្រព្រឹត្ត ហើយគាត់ក៏ប្រហែលជានៅរស់ទៀតក្រោយពីគាត់ចេញពីគុក ។ ចំណែកមនុស្សមួយចំនួនដែលទទួលយកសាលក្រមរយៈពេល ១៩ឆ្នាំ ក៏ដោយសារតែគាត់យល់ថា បើតាមអាយុរបស់ ឌុច គាត់នឹងស្លាប់នៅក្នុងគុកជាក់ជាប្រាកដ ហើយម្យ៉ាងទៀតដោយសារតែការកាន់សាសនាព្រះពុទ្ធផង ។ ក្នុងខណៈពេលដែលព័ត៌មានទាក់ទងនឹងការកាត់បន្ថយទោសពី៣៥ឆ្នាំមកនៅត្រឹម១៩ឆ្នាំត្រូវបានដឹងជាសាធារណៈ ប្រជាជនភាគច្រើនមកពីក្រុមទីពីរដែលជឿថា ទោសរបស់ ឌុច មានរយៈពេល៣៥ឆ្នាំ (ហើយអាចទទួលយកបាន) គឺមិនពេញចិត្តចំពោះសាលក្រម១៩ឆ្នាំនេះទេ ។ ជាទូទៅ មានការមិនពេញចិត្ត និងខឹងសម្បាក្នុងចំណោមអ្នកដែលរស់រានមានជីវិតពីរបប ប៉ុល ពត ។

## ក្រុមទីមួយ ៖ មិនពេញចិត្តនឹងរយៈពេល ៣៥ឆ្នាំ

ភ្លាមៗបន្ទាប់ពីការប្រកាសសាលក្រម ប្រជាជនភាគច្រើនយល់ថា ឌុច ត្រូវជាប់គុករយៈពេល ៣៥ឆ្នាំ ។ មនុស្សភាគច្រើនគឺទទួលយកសាលក្រម៣៥ឆ្នាំនេះ ពីព្រោះពួកគេជឿថា ឌុច នឹងស្លាប់ក្នុងគុក ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ មនុស្សទូទាំងប្រទេសកម្ពុជាមិនពេញចិត្តចំពោះរយៈពេល៣៥ឆ្នាំនេះទេ ។ នៅក្នុងឃុំចារ ខេត្តតាកែវ ប្រជាជនជាច្រើនដែលត្រូវបានសម្ភាសន៍ក្រោយពីការបញ្ចាំងសាលក្រម ឌុច គឺចង់ឲ្យ ឌុច ជាប់គុកមួយជីវិត ។ បន្ទាប់ពីការបញ្ចាំងសាលក្រមនៅក្នុងឃុំស្វាយចេក ខេត្តស្វាយរៀង មជ្ឈមណ្ឌលឯកសារកម្ពុជាបានសម្ភាសប្រជាជនដែលមិនពេញចិត្តជាមួយនឹងសាលក្រមនេះ ។ អ៊ឹ សុខុម ដែលជាប់គុកនៅក្នុងរបបខ្មែរក្រហម គិតថា ឌុច គួរតែជាប់គុកមួយជីវិតពីព្រោះថាគាត់ជាអ្នកទទួលខុសត្រូវចំពោះអាយុជីវិតមនុស្សរាប់ពាន់នាក់ដែលបានស្លាប់ ។ ដូចគ្នាដែរ វ៉ា សាមុត មិនពេញចិត្តជាមួយនឹងរយៈពេល៣៥ឆ្នាំនេះឡើយ ហើយបាននិយាយថាគាត់នៅតែខឹង ឌុច និងជនដៃដល់ដទៃទៀត ។ យឹម មីន និង កុងរ៉ុង ក៏គិតថា ៣៥ឆ្នាំនេះគឺតិចណាស់ ពីព្រោះថា ក្នុងពេលគាត់គ្រប់គ្រងនៅស-២១ ឌុច បានសម្លាប់មនុស្សអស់ជាច្រើន បើ មីន និង រ៉ុង គិតថាតុលាការខ្មែរក្រហមមានសារប្រយោជន៍ចំពោះប្រទេសកម្ពុជា ហើយអាចបង្រៀនក្មេងជំនាន់ក្រោយឲ្យយល់ថាឧក្រិដ្ឋជននឹងត្រូវផ្តន្ទាទោសមិនខាន ។

អ្នករស់រានមានជីវិតមួយចំនួននៅក្នុងឃុំស្វាយឃ្លាំង

ខេត្តកំពង់ចាមចង់ឲ្យ ឌុច ទទួលរងការឈឺចាប់ដូចអ្វីដែលគាត់បានធ្វើមកលើប្រជាពលរដ្ឋផ្សេងទៀតនៅក្នុងរបបនោះដែរ ។ ដោយមិនបានដឹងថា នៅក្នុងច្បាប់រដ្ឋធម្មនុញ្ញកម្ពុជាមិនមានទោសប្រហារជីវិត ស្រៀង ស្រេង ចង់ឲ្យ ឌុច ត្រូវគេសម្លាប់ដោយព្យួរក ។ សាហាប់ សាស់ ចង់ឲ្យ ឌុច ជាប់គុកមួយជីវិត ហើយបន្ថែមថា «បើសិនខ្ញុំជាចៅក្រមវិញ ខ្ញុំនឹងធ្វើទារុណកម្ម ឌុច ឲ្យដូចនឹងគាត់ធ្វើទារុណកម្មទៅលើអ្នកដទៃដែរ» ។ ស្ត្រីម្នាក់ឈ្មោះ សាគិតថា តុលាការលម្អៀងទៅខាងក្រុមការពារក្តី ។ នូ សជាស ដែលបាត់បង់សមាជិកគ្រួសារទាំងអស់ចំនួនប្រាំបីនាក់នៅក្នុងរបបខ្មែរក្រហមចង់ឲ្យ ឌុច រងគ្រោះ ដូចដែលគាត់ធ្វើទៅលើមនុស្សផ្សេងនៅទួលស្លែងដែរ ដូចជា ដាក់ខ្នោះ ហើយនិងបង្អត់អាហារជាដើម» ។ ប្រាក់ វ៉ែម នៅខេត្តបន្ទាយមានជ័យ បានបាត់បង់សាច់ញាតិប្រាំនាក់ ហើយនៅតែមានកំហឹងចំពោះ ឌុច រហូត ។ គាត់ចង់ឲ្យ ឌុច ទទួលទោសប្រហារជីវិត ។

## ក្រុមទីពីរៈ ទទួលយកសាលក្រម ៣៥ឆ្នាំ

ប្រតិកម្មជាទូទៅរបស់អ្នកនៅរស់រានមានជីវិតពីរបបខ្មែរក្រហមតាមរយៈការបញ្ចាំងសាលក្រមរបស់ ឌុច នៅក្នុងខេត្តកំពង់ធំ និងខេត្តបន្ទាយមានជ័យ គឺអាចថាទទួលយកបានទាក់ទងទៅនឹងអ្វីដែលគាត់ពុំពីដំបូងថា សាលក្រមរបស់ ឌុច គឺ ៣៥ឆ្នាំ ។ បន្ទាប់ពីដឹងថាសាលក្រម គឺ១៩ឆ្នាំវិញ មនុស្សភាគច្រើននៅក្នុងក្រុមនេះបង្ហាញពីការខកចិត្តយ៉ាងខ្លាំង ។ នួន ចៀន រស់នៅក្នុងឃុំអូរគន្ធរ ខេត្តកំពង់ធំ និយាយថា ៣៥ឆ្នាំគឺគ្រប់គ្រាន់ហើយពីព្រោះថា ឌុច នឹងស្លាប់នៅក្នុងគុក ។ គាត់បន្ថែមថា តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមមានសារសំខាន់ ពីព្រោះថាតុលាការនេះអាចបង្ហាញឲ្យពិភពលោកដឹងពីអ្វីដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជាក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ។ ហ៊ុយ ហ៊ើក ប្រជាពលរដ្ឋរស់នៅក្នុងឃុំព្រះនេតព្រះ ខេត្តបន្ទាយមានជ័យគិតថា ៣៥ឆ្នាំ គឺមិនគ្រប់គ្រាន់ទេបើប្រៀបធៀបទៅនឹងបទឧក្រិដ្ឋដែល ឌុច បានប្រព្រឹត្ត ។ តែទោះជាយ៉ាងណាក៏ដោយ ក៏គាត់គិតថារយៈពេល៣៥ឆ្នាំវាសមរម្យដែរហើយសម្រាប់ ឌុច បើគិតពីអាយុរបស់គាត់គឺ៦៨ឆ្នាំទៅហើយ ។ ផាន សៀ និង បួយ ផាន ប្រជាពលរដ្ឋរស់នៅក្នុងឃុំរំលេច ខេត្តពោធិ៍សាត់ក៏ទទួលយករយៈពេល៣៥ឆ្នាំនេះដែរ បើគិតពីអាយុរបស់ ឌុច និង ផ្អែកលើការជឿជាក់ថា គាត់នឹងស្លាប់នៅក្នុងគុកក្រោយរយៈពេល៣៥ឆ្នាំនេះ ។

នៅក្នុងឃុំរំលេច ខេត្តពោធិ៍សាត់ដដែល គីម ហួយ អាចទទួលយកសាលក្រម៣៥ឆ្នាំបានដោយមូលហេតុផ្សេងៗ ។ គីម ហួយ បាត់បង់សមាជិកគ្រួសាររបស់ខ្លួនចំនួន២២នាក់ នៅក្នុងរបបខ្មែរក្រហម ដោយរាប់បញ្ចូលទាំងឪពុកម្តាយ បងប្អូន ហើយនិងប្តីរបស់គាត់ផង ។ អស់ពេលជាយូរមកហើយ គាត់ជឿជាក់ថាមេដឹកនាំខ្មែរក្រហមនឹងមិនត្រូវបានគេនាំមកកាត់ទោសឡើយ ។ គីម និយាយថា «ខ្ញុំមិនដែលគិតថានឹងមានតុលាការទេ» ។ សម្រាប់រូបគាត់ផ្ទាល់ ការទទួលយក៣៥ឆ្នាំនេះ មិនមែនព្រោះតែគាត់ចង់ឲ្យ ឌុច ស្លាក់នៅក្នុងគុកទេ គាត់បានបកស្រាយនៅក្នុងបទសម្ភាសន៍ថា «ខ្ញុំទទួលយកសាលក្រមនេះ ពីព្រោះខ្ញុំចង់បានការផ្សះផ្សាជាតិ ។ បើទោះបីជាសម្លាប់ ឌុច ក៏មិនអាចនាំយកឪពុកម្តាយរបស់ខ្ញុំដែលស្លាប់ត្រឡប់មកវិញបានដែរ» ។

កែ តុង មកពីឃុំព្រះនេតព្រះ បានទទួលយកសាលក្រម ៣៥ឆ្នាំទាំងមិនពេញចិត្ត ដោយគិតថា ឌុច នឹងស្លាប់នៅក្នុងគុក បើទោះជាគាត់ផ្ទាល់ចង់ឃើញ ឌុច ទទួលទោសធ្ងន់ជាងនេះក៏ដោយ ។ បន្ទាប់ពីបានដឹងសាលក្រមពិតប្រាកដសម្រាប់ ឌុច គឺ ១៩ឆ្នាំនោះ លោក កែ មានការខកចិត្តយ៉ាងខ្លាំង ហើយគិតថា «តិចតួច និងគ្មានប្រយោជន៍» ។

## ក្រុមទីបីៈ មិនពេញចិត្តនឹងសាលក្រម ១៩ឆ្នាំ

ទោះបីជាពេញចិត្តឬមិនពេញចិត្តក៏ដោយ ក៏ការពន្យល់ដែលមិនមានលក្ខណៈច្បាស់លាស់របស់ចៅក្រមអំពីសាលក្រម ឌុច បានធ្វើឲ្យមនុស្សជាច្រើនធ្វើការប្រៀបធៀបពីភាពសមស្របរវាងសាលក្រម៣៥ឆ្នាំ ហើយនិងសាលក្រម១៩ឆ្នាំ ។ បន្ទាប់ពីចម្ងល់ទាក់ទងទៅនឹងសាលក្រមត្រូវបានបកស្រាយបំភ្លឺ អ្នករស់រានមានជីវិតពីរបស់ខ្មែរក្រហមចាប់ផ្តើមមានអារម្មណ៍ខកចិត្តយ៉ាងខ្លាំង ជាពិសេសអ្នកដែលជឿជាក់ពីដំបូងថាសាលក្រមគឺ ៣៥ឆ្នាំ ។

ប្រាក់ វុទ្ធី និង ទេព ចាន់ថុន មកពីឃុំកន្ទោក ខេត្តកណ្តាល មិនពេញចិត្តជាមួយនឹងសាលក្រម១៩ឆ្នាំនេះទេ ពីព្រោះថា

សាលក្រមនេះមិនស្មើទៅនឹងជីវិតមនុស្សរាប់ម៉ឺននាក់ដែលស្លាប់ក្រោមបញ្ជារបស់គាត់នៅស-២១ឡើយ ។ ពួកគាត់ទាំងពីរគិតថាតុលាការធ្វើការសម្រេចចិត្តខុស ។

អោក ទូច និង វ៉ាត ញិត មកពីឃុំអូរគន្ធរ ខេត្តកំពង់ធំ ពីដំបូងមិនពេញចិត្តនឹងសាលក្រម៣៥ឆ្នាំទេ ហើយកាន់តែមិនពេញចិត្តថែមទៀត នៅពេលដែលពួកគេដឹងថាសាលក្រមរបស់ ឌុច ត្រឹមតែ១៩ឆ្នាំប៉ុណ្ណោះ ។ គាត់ទាំងពីរបានបាត់បង់សាច់ញាតិនៅស-២១ ។ គាត់ទាំងពីរមិនអាចអត់ទោសឲ្យ ឌុច បានទេ ។ គាត់គិតថា ឌុច មិនស្មោះត្រង់ ហើយ ឌុច ព្រមទទួលស្គាល់ឧក្រិដ្ឋកម្មនៅស-២១គឺគ្រាន់តែដើម្បីឲ្យតុលាការសម្រាលទោសរបស់គាត់តែប៉ុណ្ណោះ ។ ស្ត្រីម្នាក់ឈ្មោះ ស្រី គិតថា ឌុច គួរតែត្រូវជាប់នៅក្នុងបន្ទប់ឃុំឃាំងដែលគ្មានម៉ាស៊ីនត្រជាក់និងអាហារគ្រប់គ្រាន់ ។ គាត់ក៏គិតថា នៅពេលដែល ឌុច នៅក្នុងគុក គាត់គួរតែអានចម្លើយសារភាពដែលគាត់និងបុគ្គលិកសួរចម្លើយរបស់គាត់ដែលបង្ខំឲ្យអ្នកទោស ស-២១ សរសេរ ។

## ក្រុមទីបួនៈ ទទួលយកសាលក្រម ១៩ឆ្នាំ

នៅក្នុងចំណោមប្រជាជនដែលត្រូវបានសម្ភាសន៍នៅកន្លែងបញ្ចាំងសាលក្រមហើយពេញចិត្តទៅនឹងសាលក្រម១៩ឆ្នាំ មួយចំនួនមានជំនឿថា ឌុច នឹងស្លាប់នៅក្នុងគុក ។ អឿន វ៉េត និង សួន អោក មកពីឃុំកន្ទោក ខេត្តកណ្តាល គិតថា ១៩ឆ្នាំ សមរម្យ ហើយបើគិតពីអាយុរបស់ ឌុច ហើយ ឌុច ប្រហែលជាអាចនឹងស្លាប់នៅមុនពេលដែលគាត់ត្រូវបានដោះលែង ។ គីមឡាង មកពីឃុំស្វាយឃ្លាំង ខេត្តកំពង់ចាម ទទួលយកសាលក្រមនេះ បើទោះបីជាមានមូលហេតុខុសគ្នាតិចតួចក្តី ។ គាត់ពឹងផ្អែកទៅលើព្រះពុទ្ធសាសនានៅក្នុងការប្រកាសសាលក្រម របស់ ឌុច នេះ ។ គាត់មិនមែនជាដូនជីទេ ប៉ុន្តែជាអ្នកជឿព្រះពុទ្ធសាសនាសីបម្នាក់ ។ គាត់បានពន្យល់ថា «យើងដើរតាមព្រះពុទ្ធ ហើយព្រះអង្គឲ្យយើងលើកលែងទោស ។ ហេតុដូច្នេះហើយ បើសិនជាមានជម្រើសបីៈ ការដោះលែង ការសម្លាប់ និងការការដាក់ទោស ខ្ញុំនឹងជ្រើសរើសយកជម្រើសទីពីរដើម្បីឲ្យ ឌុច មានរយៈពេលបន្តិចបន្តួចសម្រាប់រស់នៅជាមួយនឹងគ្រួសារ និងស្លាប់នៅផ្ទះពីព្រោះថា ឌុច ក៏មានប្រពន្ធនិងកូនដែរ» ។ គាត់បានបន្ថែមទៀតថា ការសម្លាប់មនុស្សម្នាក់ក្នុងទម្រង់ជាការដាក់ទារុណកម្មនឹងនាំទៅរកការសងសឹកមួយដែលគ្មានថ្ងៃបញ្ចប់ ។ គាត់បានផ្តល់មូលហេតុ «បើមនុស្សម្នាក់សម្លាប់មនុស្សម្នាក់ទៀត ជាមនុស្សឆ្កួត ហើយបើយើងនៅតែធ្វើដូចនេះទៀត នោះយើងនឹងទៅជាមនុស្សឆ្កួតដែរ» ។

អ្នកផ្តល់បទសម្ភាសន៍ដែលគួរឲ្យចាប់អារម្មណ៍ម្នាក់ ហើយទទួលយកសាលក្រម១៩ឆ្នាំ គឺជាក្មួយប្រុសរបស់ ប៉ុល ពត ឈ្មោះ ស្រី ហ៊ាន ។ ស្រី ហ៊ាន មកពីឃុំអូរគន្ធរ ខេត្តកំពង់ធំគិតថាសាលក្រម១៩ឆ្នាំនេះគ្រប់គ្រាន់ហើយសម្រាប់ ឌុច ។ គាត់ក៏ក្រើនរំឭកដែរថា ប្រសិនបើ ឌុច នៅរស់បន្ទាប់ពីជាប់គុក១៩ឆ្នាំ ឌុច ប្រហែលជានឹងធ្វើការសងសឹក ឬក៏បង្កើតឲ្យមានជាការព្រួយបារម្ភមួយសម្រាប់សង្គម ។

## ព្រឹកបន្ទាប់ពីថ្ងៃសាលក្រមៈ ខេត្តកណ្តាល

បទសម្ភាសន៍ជាមួយនឹងប្រជាជននៅក្នុងឃុំកន្ទោក ខេត្តកណ្តាល ដែលមានទីតាំងនៅជិតតុលាការខ្មែរក្រហម បង្ហាញឲ្យដឹងពីមនុស្សមួយចំនួនដែលមិនបានដឹងឬក៏មិនចាប់អារម្មណ៍ចំពោះការប្រកាសសាលក្រម ។ បើទោះបីជាមនុស្សជាច្រើនបានដឹងពីថ្ងៃប្រកាសសាលក្រមតាមរយៈទូរទស្សន៍ វិទ្យុ សាច់ញាតិ និងអ្នកជិតខាងក៏ដោយ ក៏មនុស្សមួយចំនួនមិនបានដឹងពីការប្រកាសសាលក្រមនេះឡើយ ហើយមួយចំនួនទៀតមិនបានដឹងពីតុលាការខ្មែរក្រហមទៅទៀត ។ ក្នុងចំណោមប្រជាជន២៧នាក់ដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានសម្ភាសន៍ នៅពេលព្រឹកក្រោយពេលប្រកាសសាលក្រម ឌុច មាន១៣នាក់និយាយថាមិនបានដឹង ហើយក៏មិនចាប់អារម្មណ៍ពីសាលក្រម ឌុច ទេ ។ សោម អ៊ឺ សយ ប៉េន និង ឆាត សំណាង មិនបានដឹងថា គេប្រកាសសាលក្រម ឌុច កាលពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ទេ ។ ដូចគ្នាដែរ ឡាស ម៉ៅ និង សយ សុជាត មិនបានដឹងថា តុលាការខ្មែរក្រហមប្រកាសសាលក្រម ឌុច ទេ ពីព្រោះពួកគាត់រវល់ស្ទូងស្រូវនៅឯស្រែរបស់ខ្លួន ។

បទសម្ភាសន៍មួយថ្ងៃក្រោយការប្រកាសសាលក្រមបានបង្ហាញថាមានមនុស្សមួយចំនួនជឿថា ឌុច ត្រូវបានផ្តន្ទាទោសឲ្យជាប់គុក៣៥ឆ្នាំ បើទោះបីជាមានការផ្សាយបញ្ជាក់បន្ថែមពីសំណាក់មន្ត្រីតុលាការក៏ដោយ ។ ភុន សាវ៉ុន បង្ហាញពីការមិន

ពេញចិត្តរបស់គាត់ចំពោះសាលក្រមដែលកាត់ ឌុច ជាប់គុក៣៥ ឆ្នាំ ។ គាត់ជឿជាក់ថា គាត់មិនទទួលបានយុត្តិធម៌ទេ ។ ស៊ុ ហ៊ាន មួយថ្ងៃបន្ទាប់ក្រោយការប្រកាសសាលក្រម ស៊ុ ហ៊ាន នៅតែជឿ ថា ឌុច ជាប់គុក៣៥ឆ្នាំ ក៏មានការខកចិត្តដែរ ។ គាត់គិតថា បទ ឧក្រិដ្ឋរបស់ ឌុច សាហាវយង់ឃ្នងណាស់ មិនគួរណាជាប់គុកតែ ៣៥ឆ្នាំនោះទេ ។ គាត់ស្នើឲ្យតុលាការពិចារណាការសម្រេចចិត្ត នោះម្តងទៀត ។ ទេព សុមាលី និង ជួប នីម គិតថាសាលក្រម ៣៥ឆ្នាំនេះគឺអាចទទួលយកបាន ។

## ក្រោយពីការប្រកាសសាលក្រមៈ ដើមបណ្តឹងរដ្ឋប្បវេណី និងសំណង

ទោះបីជាមានការផ្តោតអារម្មណ៍ច្រើនទៅលើរយៈពេល ដែល ឌុច ត្រូវជាប់ទោសក្រោយការប្រកាសសាលក្រមក៏ដោយ ក៏បញ្ហាទាក់ទងទៅនឹងដើមបណ្តឹងរដ្ឋប្បវេណីនិងសំណងមានសារ សំខាន់ដែរ ហើយច្បាស់ជានឹងទាក់ទាញការចាប់អារម្មណ៍ច្រើនផង ដែរ ក្រោយពេលដែលមានការខកចិត្តពីរឿងសាលក្រម១៩ឆ្នាំ មានការសាបរលាប ។ នៅសន្និសីទសារព័ត៌មាន ក្រោយពេល ប្រកាសសាលក្រម ឌុច ដើមបណ្តឹងរដ្ឋប្បវេណីទាំងបីក្រុមបាន បង្ហាញការខកចិត្តរបស់ពួកគេចំពោះការកាត់ទោស ឌុច ឲ្យជាប់ គុកត្រឹមតែ១៩ឆ្នាំ តុលាការមិនទទួលយកការចូលរួមរបស់ដើម បណ្តឹងរដ្ឋប្បវេណី ហើយនិងការបដិសេធទាំងស្រុងនូវសំណង គ្រប់បែបយ៉ាង ។

ប្រជាជនកម្ពុជាជាច្រើនចង់ឲ្យ ឌុច ទទួលការផ្តន្ទាទោស ឲ្យជាប់ពន្ធនាគារអស់មួយជីវិត ខណៈពេលដែលប្រទេសកម្ពុជា មិនអនុញ្ញាតឲ្យមានទោសប្រហារជីវិត ។ ប៉ុន្តែ សហព្រះរាជអាជ្ញា បានស្នើសុំឲ្យមានដាក់ពន្ធនាគារត្រឹមតែ៤០ឆ្នាំប៉ុណ្ណោះ ។ ដោយ បច្ចុប្បន្ន ឌុច មានអាយុ៦៧ឆ្នាំ ការផ្តន្ទាទោសនេះអាចធានាថា ឌុច នឹងស្លាប់នៅក្នុងពន្ធនាគារ ហើយវាអាចធ្វើឲ្យអ្នកដែលចង់ឲ្យ ឌុច ជាប់ពន្ធនាគារអស់មួយជីវិតពេញចិត្ត ។ ប៉ុន្តែរយៈពេល ១៩ឆ្នាំមិនអាចធានាបែបនេះបានទេ ហើយវាមានរយៈពេលតិច ជាង៣៥ឆ្នាំដែលជាចំនួនដើមនៃការផ្តន្ទាទោស ។ សេចក្តីសម្រេច របស់ចៅក្រមក្នុងការប្រកាសការផ្តន្ទាទោសចំនួន៣៥ឆ្នាំជាជាង ១៩ឆ្នាំ មិនត្រឹមតែធ្វើឲ្យប្រជាជនជាច្រើនដែលរួមមានប្រជាជន កម្ពុជាធម្មតា អ្នកសារព័ត៌មាន និងបញ្ញវន្តមានការយល់ខុសទេ ថែមទាំងធ្វើឲ្យមានការឆ្ងល់ថាតើវាជាយុត្តិសាស្ត្រមែនដែរឬទេ ។ ទោះបីជាវាជាចេតនាឬក៏អត់ក៏ដោយ ក៏វាបានធ្វើឲ្យដើមបណ្តឹង រដ្ឋប្បវេណីដែលធ្លាប់មានបញ្ហាជាមួយនឹងតុលាកាតាំងពីសំណុំ រឿង០០១ នៅដើមខែមីនា ឆ្នាំ២០០៩ កាន់តែមានកំហឹង ។ អ្វីដែលភាគីដើមបណ្តឹងរដ្ឋប្បវេណីត្រូវទទួលរងមួយទៀត គឺសេចក្តីសម្រេចរបស់តុលាការនៅថ្ងៃប្រកាសសាលក្រមដែល យ៉ាងហោចណាស់ដើមបណ្តឹងរដ្ឋប្បវេណីចំនួន២៤នាក់ មិនបានទទួលស្គាល់ដោយតុលាការទេ ។ ភាគីទាំង២៤នាក់នេះ


ការផ្សាយបន្តផ្ទាល់សាលក្រម ឌុច នៅវត្តពោធិអណ្តែត

បានចូលរួមជាមួយដំណើរតុលាការអស់ រយៈពេលជាច្រើនខែដោយរំពឹងថា មិនទទួល បានអ្វីមួយសមស្របតាមតុលាការទេ ។

បញ្ហាដែលមិនសូវមានគេនិយាយ ប្រហែលជាបញ្ហាសំណង ។ នៅក្នុងចំណោម ប្រជាជនលើសពី៧០នាក់ដែលផ្តល់បទ សម្ភាសន៍ដល់មជ្ឈមណ្ឌលឯកសារកម្ពុជានៅ អំឡុងពេលចាក់ការផ្សាយបន្តផ្ទាល់ មាន ប្រជាជនតិចតួចប៉ុណ្ណោះបាននិយាយអំពី បញ្ហាសំណង ។ នេះបណ្តាលមកពីហេតុផល មួយចំនួន ។ ហេតុផលទីមួយ គឺប្រជាជន កម្ពុជាជាច្រើនមិនដឹងពីលទ្ធភាពនៃការ

ស្នើសុំសំណងពីតុលាការចំពោះអ្វីដែលបានកើតឡើងចំពោះខ្លួននៅក្នុងរបបខ្មែរក្រហម ។ ទីពីរគឺ ប្រជាជនជាច្រើនមិនដឹងពីដំណើរការដែលអាចផ្តល់សំណងដល់ដើមបណ្តឹងរដ្ឋប្បវេណី ។ ទីបី ដែលប្រហែលជាមូលហេតុចម្បងជាងគេគឺអ្នកនៅរស់ជាច្រើនមិនចាប់អារម្មណ៍នឹងការទទួលសំណងជាសម្ភារៈចំពោះអ្វីដែលបាត់បង់ ។ ចំពោះការពិតដែលថា ២០ភាគរយនៃប្រជាជនសរុបបានស្លាប់ មានន័យថានៅក្នុងគ្រួសារមួយយ៉ាងហោចណាស់ក៏មានសមាជិកម្នាក់ស្លាប់ដែរនិងទ្រព្យសម្បត្តិស្ទើរតែទាំងអស់ ។

ប៉ុន្តែការបដិសេធសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី (មានចំនួនពីរដូចជានៅបញ្ចូលឈ្មោះអ្នកទោសនៅមន្ទីរស-២១ នៅក្នុងសាលក្រម និងការចែកចាយការសុំទោសរបស់ ឌុច) គឺជាសារដ៏ឥតខ្លឹមសារមួយដល់ជនរងគ្រោះ ពីព្រោះសំណើនោះតម្រូវឲ្យប្រើប្រាស់ពេលវេលានិងប្រាក់តែបន្តិចបន្តួចដូចជាចំណាយទៅលើការថែរក្សារូបគំនូររបស់អ្នកនៅរស់ពីស-២១ វ៉ាន់ ណាត ដែលត្រូវបានដាក់បង្ហាញនៅសារមន្ទីរអំពើប្រល័យពូជសាសន៍រួចទៅហើយ ការស្ថាបនាផ្លូវដើរនៅខាងក្រោស-២១ ការសរសេរលិខិតទៅរដ្ឋាភិបាលកម្ពុជាដើម្បីស្នើឲ្យមានការសុំទោសដល់ដើមបណ្តឹងរដ្ឋប្បវេណី ។ ការយល់ស្របទៅលើសំណើយ៉ាងហោចណាស់មួយអាចធ្វើឲ្យអ្នកនៅរស់មានទស្សនៈល្អបន្តិចចំពោះតុលាការ ។ លោកបណ្ឌិត ចន ឆរឆីអារី សាស្ត្រាចារ្យផ្នែកនយោបាយសាធារណៈ និងអ្នកជំនាញសិក្សាអំពីកម្ពុជានៅសាកលវិទ្យាល័យ មីឈីហ្គេន បាននិយាយថា «តុលាការមិនមានតួនាទីអ្វីទៅលើសំណងទេ» ។ គាត់បានពន្យល់ទៀតថា តុលាការគួរតែធ្វើការជាមួយសង្គមស៊ីវិលតាំងពីដើមដើម្បីរៀបចំបំពេញសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី ហើយការដែលមិនបានធ្វើដូច្នោះគឺជា «ការបាត់បង់ឱកាសមួយ» ។ ខណៈពេលដែលមានការចាប់អារម្មណ៍ច្រើនទៅលើបញ្ហាសំណងនៅពេលខាងមុខ ប្រហែលជាមានប្រជាជនកម្ពុជាច្រើនជាងមុនចាប់ផ្តើមគិតអំពីតួនាទីរបស់តុលាការក្នុងការនាំយកយុត្តិធម៌តាមផ្លូវច្បាប់និងជួយរំពុកនូវសោកនាដកម្មនៃរបបខ្មែរក្រហមដែលនឹងផ្តល់នូវជំនួយដល់ផ្លូវផ្សះផ្សា និងស្តារឡើងវិញនូវអ្វីដែលបាត់បង់ ។ ជាងនេះទៅទៀត ខណៈពេលដែលប្រជាជនជាច្រើនមិនពេញនឹងការដាក់ទោសឲ្យជាប់ពន្ធនាគារ ពេលបែបនេះសំណងគួរតែផ្តោតទៅលើការជួយដល់សង្គម ដូចជាការអប់រំពីអំពើប្រល័យពូជសាសន៍ ការបង្កើតមន្ទីរពេទ្យព្យាបាលជំងឺផ្លូវចិត្ត ឬការបង្កើតជាស្តូប ឬវត្តដើម្បីជាការរំពុកនិងអាចជួយសម្រាលកំហឹងនិងភាពអស់សង្ឃឹមចំពោះការផ្តន្ទាទោសដ៏ស្រាល ។ ដើម្បីជាការឆ្លើយតបចំពោះការដាក់ឲ្យជាប់ពន្ធនាគារ៣៥ឆ្នាំ ចាប យួង នៅឃុំរំលេច ខេត្តពោធិ៍សាត់បាននិយាយថា «ខ្ញុំគិតថា ការដាក់ពន្ធនាគារ៣៥ឆ្នាំ គឺមិនគ្រប់គ្រាន់ទេ ប៉ុន្តែខ្ញុំមិនអាចធ្វើអ្វីបានឡើយ ។ ខ្ញុំចង់ឃើញសំណងដូចជាការសាងសង់វត្តនៅថ្ងៃអនាគត» ។ **កែវ ដាស៊ីល**

## កម្មវិធីអប់រំអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

វិទ្យុផ្សាយសំឡេងសហរដ្ឋអាមេរិកជាភាសាខ្មែរនឹងធ្វើការចាក់ផ្សាយកម្មវិធីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ» ដែលនិពន្ធដោយលោក ឌី ខាំបូលី ដែលអ្នកទាំងអស់គ្នាអាចស្តាប់ថតចម្លងនិងអានសាច់រឿងដែលមាននៅក្នុងសៀវភៅនេះតាមរយៈគេហទំព័រ *http://www.voanews.com/ khmer/democratic-kampuchea.cfm* របស់វិទ្យុផ្សាយសំឡេងសហរដ្ឋអាមេរិកជាភាសាខ្មែរ ។ **មជ្ឈមណ្ឌលឯកសារកម្ពុជា**

## ឃ្លាំមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាតាមគេហទំព័រ

ដើម្បីឲ្យសាធារណជនទូទៅមានលទ្ធភាពក្នុងការតាមដានមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសមញ្ញក្នុងតុលាការកម្ពុជា គេហទំព័រ *www.cambodiatribunal.org* ត្រូវបានបង្កើតឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា និងសាលាច្បាប់នៃសាកលវិទ្យាល័យណតវ៉េស្ទើន សហរដ្ឋអាមេរិក និងក្រោមសហប្រត្តិបត្តិការជាមួយ *Illinois Holocaust Museum and Educational Center* ។ មុននិងផ្សព្វផ្សាយគេហទំព័រនេះ ត្រូវបានត្រួតពិនិត្យដោយសាស្ត្រាចារ្យច្បាប់ *David Scheffer* អតីតឯកអគ្គរដ្ឋទូតគោចរណ៍របស់សហរដ្ឋអាមេរិកទទួលបន្ទុកកិច្ចការឧក្រិដ្ឋកម្មសង្គ្រាមកាលពីជំនាន់រដ្ឋការប្រធានាធិបតី ប៊ីល គ្លីនតុន និងលោក ឆាំង យុ នាយក មជ្ឈមណ្ឌលឯកសារកម្ពុជា ។

# ប្រតិកម្មចំពោះសាលក្រម ឌុច

«ការកាត់ក្តី ឌុច ជាប់ទោស៣៥ឆ្នាំ បង្ហាញពីភាពយុត្តិធម៌ច្រើនសម្រាប់ ឌុច ពីព្រោះថា គាត់បានធ្វើសហប្រតិបត្តិការជាមួយតុលាការ ហើយតុលាការក៏បានធ្វើការកាត់សងជំងឺចិត្តដល់គាត់ដែលត្រូវបានឃុំខ្លួនគាត់ខុសពីនីតិវិធីច្បាប់មុនពេលដែលសាលាក្តីខ្មែរក្រហមបានបង្កើតឡើង ។ ប៉ុន្តែទម្ងន់នៃសាលក្រមនេះចំពោះឧក្រិដ្ឋដ៏ច្រើនដែល ឌុច បានសារភាពហាក់បីដូចជាស្រាលពេកសម្រាប់ផ្តល់យុត្តិធម៌ជូនជនរងគ្រោះដែលជនរងគ្រោះគួរតែទទួលបានយុត្តិធម៌ច្រើនជាងនេះ ។ និយាយជារួម ខ្ញុំចាប់អារម្មណ៍ថាសាលក្រមនេះជាសំខាន់បានបង្ហាញជូនជនរងគ្រោះដ៏ដូចជាប្រជាជនកម្ពុជាទាំងមូលថា សាលាក្តីបានរកឃើញអ្នកទទួលខុសត្រូវលើឧក្រិដ្ឋកម្មប្រវត្តិសាស្ត្រមួយរូបនៃរបបកម្ពុជាប្រជាធិបតេយ្យ ហើយសំខាន់ជាងនេះទៅទៀត សាលក្រមនេះក៏បានបង្ហាញពីវប្បធម៌នៃការទទួលខុសត្រូវដល់ប្រជាជនកម្ពុជាគ្រប់រូបផងដែរ» ។

**ហួយ វិចិត្រ អនុបណ្ឌិត សហរដ្ឋអាមេរិក**

«សាលក្រមនេះមានលក្ខណៈសមស្របដោយយោងទៅតាមបទដ្ឋាន និងច្បាប់អន្តរជាតិ ប៉ុន្តែវាហាក់ដូចជាតិចជាងអ្វីដែលប្រជាជនកម្ពុជាទាំងអស់បានរំពឹងទុក ។ មិនត្រឹមតែខ្ញុំផ្ទាល់ទេដែលមានការភ្ញាក់ផ្អើលចំពោះការផ្តន្ទាទោស៣៥ឆ្នាំ ប៉ុន្តែប្រជាជនកម្ពុជាទាំងអស់ក៏ដូច្នេះដែរពីព្រោះឧក្រិដ្ឋកម្មដែល ឌុច បានប្រព្រឹត្តធំធេងសម្បើមណាស់ ។ ទោះបីជា ឌុច មិនមែនជាមេដឹកនាំនៃរបបខ្មែរក្រហម ប៉ុន្តែមានប្រជាជនរាប់ម៉ឺននាក់បានស្លាប់នៅក្រោមកណ្តាប់ដៃគាត់ ដូច្នេះការផ្តន្ទាទោសនោះមានយុត្តិធម៌ បើយោងទៅតាមច្បាប់ ប៉ុន្តែវាមិនមានយុត្តិធម៌សម្រាប់អ្នកនៅរស់និងអ្នកស្លាប់ទេ ។ បើប្រៀបធៀបគ្នា ឧក្រិដ្ឋកម្មដែល ឌុច បានប្រព្រឹត្តមានលក្ខណៈធំជាងឧក្រិដ្ឋកម្មរបស់ សាដាម ហ៊ូសេន ដែលត្រូវបានរកឃើញថាជាប់ពិរុទ្ធភាពឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទៅទៀត ។ ចំពោះខ្ញុំផ្ទាល់ ខ្ញុំយល់ឃើញថា វាគឺជាចំណុចចាប់ផ្តើមដ៏ល្អ និងជាចំណុចល្អក្នុងការរង់ចាំមើលករណី០០២ បន្ទាប់ទៀត» ។

**សុខ សេរី និស្សិតថ្នាក់បណ្ឌិតនៅសាកលវិទ្យាល័យហុងកុងបាបធីស**

«ខ្ញុំសប្បាយចិត្តដែល ឌុច ត្រូវបានសម្រេចថាជាប់ទោស ទោះបីជាសាលក្រមហាក់ដូចជាស្រាលបើគិតទៅដល់អំពើសាហាវឃោរឃៅដែលគាត់បានប្រព្រឹត្ត ។ ទោះបីជាយ៉ាងណាក៏ដោយ វានៅតែជាបញ្ហាថាតើវាអាចផ្តល់យុត្តិធម៌ដល់ជនរងគ្រោះនៃរបបខ្មែរក្រហមដ៏ព្រៃផ្សៃនោះដែរឬទេ ។ តុលាការទើបតែកើតឡើងនៅពេលដែល ប៉ុល ពត បានស្លាប់ រីឯមេដឹកនាំរបបខ្មែរក្រហមផ្សេងទៀតមានវ័យចំណាស់ទៅហើយ ។ ចាប់តាំងពីពេលចាប់ផ្តើមខ្ញុំយល់ថាផលប្រយោជន៍របស់សាលាក្តីខ្មែរក្រហម គឺគ្រាន់តែជានិមិត្តសញ្ញាទេ ដែលរំឭកដល់មេដឹកនាំផ្សេងៗនៅលើពិភពលោកថាអ្នកទាំងនោះត្រូវទទួលខុសត្រូវចំពោះសកម្មភាពរបស់ខ្លួន ។ ក្រៅពីនេះ យើងមិនអាចរំពឹងអ្វីផ្សេងទៀតពីតុលាការទេ» ។

**បណ្ឌិត សូ សុខប៊ុនធឿន សហរដ្ឋអាមេរិក**

«សាលក្រមលើករណី ឌុច គឺជាចលនាប្រវត្តិសាស្ត្រមួយនៅក្នុងប្រវត្តិសាស្ត្រកម្ពុជា ។ សាលក្រមនេះបានទាក់ទាញប្រជាជនកម្ពុជាគ្រប់ស្រទាប់ជាន់ថ្នាក់ និងប្រជាជនផ្សេងទៀតនៅលើពិភពលោក ។ សាលក្រមនេះបានធ្វើឲ្យមនុស្សជាច្រើនមានប្រតិកម្មទៅលើថាតើសាលក្រមអាចផ្តល់យុត្តិធម៌ឬទេ ។ ការពិតដែលថា ឌុច ត្រូវបានសម្រេចថាមានពិរុទ្ធភាព បានជួយព្យាបាលដល់របួសផ្លូវចិត្ត ជាពិសេសដល់អ្នកដែលបានរងគ្រោះនៅក្នុងមន្ទីរស-២១ ដោយផ្ទាល់ ។ នេះគឺជាជំហានសំខាន់ ប៉ុន្តែយើងគួរតែចាំថាដើម្បីទទួលបានយុត្តិធម៌នៅកម្រិតថ្នាក់ជាតិ តុលាការគួរតែដាក់ឲ្យមេដឹកនាំខ្មែរក្រហមទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មឲ្យបានលឿន ។

*នៅថ្ងៃអនាគត ពិភពលោកមិនគួរសម្លឹងមើលមកប្រវត្តិសាស្ត្រនិងអស់សង្ឃឹមចំពោះបរាជ័យភាពរបស់តុលាការ ទោះបីជាមានការចំណាយថវិកាអស់រាប់លានក្នុងការផ្តល់យុត្តិធម៌ក៏ដោយ ពីព្រោះតែពាក្យចចាមអារាមទាក់ទិននឹងអំពើពុករលួយ និងការជ្រៀតជ្រែកផ្នែកនយោបាយ » ។*

**ជេត សុខឧត្តម បុគ្គលិកសិក្សានៅសាកលវិទ្យាល័យហ្សាមែន អនុបណ្ឌិត សហរដ្ឋអាមេរិក**

*«ចំពោះខ្ញុំផ្ទាល់ ខ្ញុំគិតថាសាលក្រមមានលក្ខណៈត្រឹមត្រូវបើប្រៀបទៅនឹងសកម្មភាពនិងបទឧក្រិដ្ឋរបស់ ឌុច ។ សាលក្រមត្រូវបានគេរំពឹងទុកថា បន្ទាប់ពី៣០ឆ្នាំនៃអំពើសាហាវព្រៃផ្សៃកើតឡើង វានឹងអាចនាំយកយុត្តិធម៌ពីមេដឹកនាំដែលត្រូវទទួលខុសត្រូវ ។ ឌុច មិនមែនជាមេដឹកនាំជាន់ខ្ពស់ទេ ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគឺជាការរំឭកមួយដល់មេដឹកនាំដែលចង់បានអំណាចថាអ្នកទាំងនោះគួរតែប្រុងប្រយ័ត្ននូវការប្រើប្រាស់អំណាចរបស់ខ្លួនអំឡុងពេលដែលខ្លួនមានអំណាច» ។*

**បណ្ឌិត គឹម សេតារា ប្រទេសស៊ុយអ៊ែត**

*«ខ្ញុំគិតថាសាលក្រមនោះមិនមានភាពយុត្តិធម៌សម្រាប់ ឌុច ទេ ។ ទោះបីជា ឌុច បានសម្លាប់ប្រជាជនរាប់ម៉ឺននាក់ក៏ដោយ ប៉ុន្តែគាត់មិនមែនធ្វើដោយចិត្តឯងទេ ។ មានន័យថា ឌុច ត្រូវបានគេបង្ខំ ។ ជាងនេះទៅទៀត ឌុច បានសារភាពនូវរាល់ឃាតកម្ម និងបានស្នើឲ្យមានការដាក់ទណ្ឌកម្មដែរ ។ ខ្ញុំគិតថា ឌុច ត្រូវបានឃុំឃាំងនៅមន្ទីរឃុំឃាំងនៅតុលាការយោធាយូរគ្រប់គ្រាន់ទៅហើយ ដូច្នេះ ឌុច គួរតែត្រូវបានឃុំឃាំងបន្តតិចជាង១០ឆ្នាំ» ។*

**ហ៊ាង វឌ្ឍនៈ អនុបណ្ឌិត សហរដ្ឋអាមេរិក**

*«ខ្ញុំត្រូវតែចាត់ទុកថា សាលក្រម ឌុច គឺជាជោគជ័យមួយ ព្រោះនៅទីបញ្ចប់តុលាការបានផ្តន្ទាទោសលើបទឧក្រិដ្ឋ (១៩ឆ្នាំនៅក្នុងពន្ធនាគារ) បន្ទាប់ពីចំណាយកម្លាំង និងប្រាក់ទៅលើគាត់ និងអ្នកដទៃ ។ ១៩ឆ្នាំហាក់ដូចជាស្រាល ប៉ុន្តែវាគួរតែគ្រប់គ្រាន់សម្រាប់បង្ហាញថានៅទីបញ្ចប់ពិតជាមានការផ្តល់យុត្តិធម៌ ។ ប៉ុន្តែប្រសិនបើបច្ចុប្បន្ន ឌុច មានអាយុ៣០ឆ្នាំ ការឃុំឃាំងចំនួន១៩ឆ្នាំពិតជាការលេងសើច ។ ឌុច អាចនឹងស្លាប់នៅក្នុងពន្ធនាគារខណៈពេលដែលគាត់មានវ័យចំណាស់រួចទៅហើយ ។ ជាសរុបសេចក្តី ខ្ញុំមានការពេញចិត្តនឹងសាលក្រម ទោះបីជាខ្ញុំមានការព្រួយបារម្ភចំពោះឧក្រិដ្ឋកម្មសំខាន់ផ្សេងទៀតដែលទាក់ទងនឹងអ្នកដឹកនាំជាន់ខ្ពស់ដែលធ្វើឲ្យមានការសម្លាប់ប្រជាជនស្ទើតែពីរលាននាក់ក៏ដោយ» ។*

**បណ្ឌិត អេង សុធី សហរដ្ឋអាមេរិក**

*«ក្នុងនាមជាខ្មែរ និងដើម្បីយុត្តិធម៌សម្រាប់ប្រជាជនកម្ពុជារាប់លាននាក់ដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហម យើងគួរតែធ្វើការថ្កោលទោសមេដឹកនាំនៃរបបនោះ ប៉ុន្តែប្រសិនបើយើងគិតទៅដល់ទ្រឹស្តីព្រះពុទ្ធ យើងគួរតែចាត់ទុកថាវាគឺជាអតីតកាលនៃប្រវត្តិសាស្ត្រនៅក្នុងប្រទេស ។ ខ្ញុំដឹងថា វាប្រហែលជាមិនមានយុត្តិធម៌សម្រាប់មនុស្សជាច្រើននិងសាច់ញាតិរបស់ជនរងគ្រោះទេ ប៉ុន្តែប្រសិនបើយើងគិតទៅដល់សង្គ្រាមលោកលើកទី១ និងទី២ តើអ្នកណាទទួលខុសត្រូវចំពោះអំពើប្រល័យពូជសាសន៍? មិត្តភក្តិ និងសាស្ត្រាចារ្យជាច្រើនធ្លាប់បានសួរខ្ញុំអំពីរឿងនេះនៅពេលដែលខ្ញុំនៅប្រទេសបារាំង ខ្ញុំបាននិយាយថាយើងគួរតែចាត់ទុកថាវាជាប្រវត្តិសាស្ត្រ កុំរំឭកពីវាទៀត ហើយប្រសិនបើយើងរំឭកពីវា មានន័យថាយើងចង់បង្ហាញដល់ក្មេងជំនាន់ក្រោយដែលកំពុងរស់នៅក្នុងសន្តិភាពឲ្យយកចិត្តទុកដាក់ទៅលើអ្វីដែលអ្នកទាំងនោះមិនដែលពុ្វ មិនដែលជួបប្រទះ ។ យើងទាំងអស់គ្នាសុទ្ធតែរស់នៅក្នុងសន្តិភាព ដូច្នេះសូមអ្នកទាំងអស់គ្នាខំព្យាយាមឲ្យអស់ពីសមត្ថភាពដើម្បីអភិវឌ្ឍប្រទេសយើងឲ្យក្លាយទៅជាប្រទេសដ៏អស្ចារ្យមួយនៅតំបន់អាស៊ីអាគ្នេយ៍ និងនៅក្នុងពិភពលោក» ។*

**បណ្ឌិត ចិន្ត ច័ន្ទរតនា ប្រទេសបារាំង**

*«ការផ្តន្ទាទោសឲ្យជាប់ពន្ធនាគារ៣៥ឆ្នាំ ចំពោះការសម្លាប់ប្រជាជន១២០០០នាក់! ចៅក្រមគួរតែយកចិត្តទុកដាក់ទៅលើឥទ្ធិពលនៃសេចក្តីសម្រេចរបស់ខ្លួនដែលអាចប៉ះពាល់ដល់ជនរងគ្រោះ គ្រួសាររបស់ជនរងគ្រោះ និងពិភពលោកទាំងមូល ។ ការ*

សម្លាប់រង្គាលអាចមិនមែនជាបទល្មើសធ្ងន់ធ្ងរ ល្មិកណាជននោះមានសហការជាមួយតុលាការនិងសម្តែងពីការសោកស្តាយខ្លះ ។ ខ្ញុំយល់ថា ឌុច គួរតែមានភាពធូរស្បើយចំពោះការស្លាប់របស់ជនរងគ្រោះចំនួនលើសពី១២០០០នាក់ ប្រសិនបើគាត់ទទួលបានការកាត់ទោស៣៥ឆ្នាំឲ្យនៅក្នុងពន្ធនាគារ» ។

**អ៊ី សំភី អនុបណ្ឌិត ប្រទេសជប៉ុន**

«ខ្ញុំគិតថា ការប្រកាសសាលក្រមរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាលើករណី ឌុច បានបញ្ចប់ជំពូកសំខាន់មួយទៀតនៅក្នុងប្រវត្តិសាស្ត្រកម្ពុជាបច្ចុប្បន្ន ។ វាគឺជាជំពូកដែលកំពុងរង់ចាំការទទួលស្គាល់ និងពន្យល់ពីសេចក្តីសន្និដ្ឋាន ។ ប្រជាជនស្ទើរតែទាំងអស់នៅក្នុងប្រទេសកម្ពុជាសុទ្ធតែទទួលឥទ្ធិពលពីអ្វីដែលបានកើតឡើងនៅក្នុងអំឡុងខ្មែរក្រហមនិងនឹករំឭកដល់អ្នកជាទីស្រឡាញ់របស់ខ្លួនដែលបានស្លាប់ ។ សាលក្រមលើករណី ឌុច បានធ្វើឲ្យអ្នកទាំងនោះអស់ចិត្ត ហើយក៏ជួយដល់ដំណើរការព្យាបាលរបួសអ្នកទាំងនោះដែរ ។ ប៉ុន្តែប្រជាជនជាច្រើនបានបង្ហាញពីការមិនពេញចិត្តនឹងសាលក្រម ដោយសារតែថិរវេលាដែល ឌុច ត្រូវជាប់ពន្ធនាគារ ។ ក្នុងនាមជាអ្នកជំនាន់ក្រោយនៃប្រទេសក្រោយសង្គ្រាម ខ្ញុំយល់ថាវាមិនមានអ្វីខុសគ្នាប្រសិនសាលក្រមកំណត់ឲ្យជាប់ពន្ធនាគារច្រើន ឬតិចជាងនេះ ។ ចំពោះបុរសម្នាក់ដែលមានអាយុ៦៧ឆ្នាំដែលលើសពីអាយុមធ្យមដែលអាចរស់រានមានជីវិតនៅក្នុងប្រទេសកម្ពុជា ហើយរស់នៅក្នុងមន្ទីរឃុំឃាំង ខ្ញុំគិតថាគាត់នឹងមិនមានសំណាងនិងបានរស់ទេ ។ ដោយធំធាត់នៅក្នុងប្រទេសកម្ពុជា យើងទាំងអស់គ្នាសុទ្ធតែទទួលបានការបង្រៀនមួយដែលថា «ពៀររំងាប់ដោយការមិនចងពៀរ» ។ ឌុច បានទទួលស្គាល់នូវអ្វីដែលគាត់បានធ្វើខុសកាលពីជាង៣០ឆ្នាំមុន ហើយបានស្នើសុំការអភ័យទោស ។ ប៉ុន្តែមិនមាននរណាម្នាក់បានអត់ឱនទោសឲ្យគាត់ទេ ។ ឌុច ធ្លាប់ជាប់ពាក់ព័ន្ធនឹងការសម្លាប់ប្រជាជនលើសពី ១២,០០០នាក់ នៅទួលស្លែង ហើយពិភពលោកចង់មើលឃើញគាត់ត្រូវបានដាក់ទោសចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិហើយត្រូវផ្តន្ទាទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិត ។

**អាន សុវត្ថា និស្សិតថ្នាក់បណ្ឌិតនៅសាកលវិទ្យាល័យហាវ៉ៃ**

«តើយើងគួរតែរស់នៅក្នុងភាពបច្ចុប្បន្ននិងអនាគតហើយនាំគ្នាបំភ្លេចអតីតកាលចោល? ខ្ញុំយល់ឃើញថា ចំណុចនេះងាយស្រួលធ្វើជាជាងនិយាយសម្រាប់អ្នកដែលបាត់បង់មនុស្សសំខាន់ក្នុងអំឡុងរបបខ្មែរក្រហមដែលចេះតែបន្ទាបនិងលង់អ្នកទាំងនោះជារៀងរហូត ។ ប៉ុន្តែខ្ញុំគិតថា យើងមិនគួរចាត់ទុកថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ជាទិវាដែលឈឺចាប់និងគ្រាំគ្រាសម្រាប់ប្រជាជនកម្ពុជាទេ ។ យើងគួរតែចាត់ទុកថ្ងៃប្រកាសសាលក្រម ឌុច ជាដំណាក់កាលចាប់ផ្តើមសម្រាប់ការកាត់ទោសនាពេលក្រោយទៀតចំពោះមេដឹកនាំខ្មែរក្រហម ។ តាមការពិត ឌុច ត្រូវបានបង្ខំឲ្យស្តាប់តាមបញ្ជារបស់ខ្លួន ហើយគាត់ផ្ទាល់ត្រូវតែស្មោះត្រង់ចំពោះរបបខ្មែរក្រហមនោះផងដែរ ។ បើសិនជាសាលក្រមស្រដៀងគ្នានេះជារបស់មេដឹកនាំកំពូលរបស់ខ្មែរក្រហមនោះសាធារណជនមិនគួរនឹងមិនខឹង ហើយបញ្ចេញប្រតិកម្មខ្លាំងៗនោះទេ ។ បើមិនកាត់ទោស ឌុច ឲ្យជាប់គុក៣៥ឆ្នាំ តើប៉ុន្មានឆ្នាំទើបគិតថាសមស្របសម្រាប់គាត់? តើយើងមានបំណងកាត់ទោសប្រហារជីវិតគាត់ដែរឬទេ? បើធ្វើដូច្នេះនោះយើងនឹងបាត់បង់សាក្សីម្នាក់សម្រាប់សវនាការលើកក្រោយទៀតហើយ» ។

**ស សម្ផស្ស អនុបណ្ឌិត សហរដ្ឋអាមេរិក**

«ខ្ញុំចង់ឲ្យតុលាការកាត់ទោស ឌុច ឲ្យជាប់គុកមួយម៉ឺនជីវិត ឬប្រហារជីវិតមួយម៉ឺនដង ។ ខ្ញុំដឹងថា តុលាការនឹងមិនអាចកាត់ទោស ឌុច ប្រហារជីវិតទេ ប៉ុន្តែខ្ញុំមិនយល់ត្រង់ថាហេតុអ្វីបានជាមិនអាចកាត់ទោស ឌុច អស់មួយជីវិតបានចំពោះអ្វីដែលគាត់បានធ្វើឲ្យបាត់បង់ជីវិតមនុស្សយ៉ាងហោចណាស់១២,២៧៣នាក់ នៅមន្ទីរស-២១ ។ ការដាក់ទោស៣៥ឆ្នាំ និងចោទជាសំណួរថាតើនឹងមានយុត្តិធម៌ពិតប្រាកដឬទេសម្រាប់ប្រជាជនកម្ពុជា ។ ខ្ញុំក៏យល់ផងដែរថា ការកាត់ទោសនេះគឺជាថ្នាំព្យាបាលរបួសផ្លូវចិត្តជនរងគ្រោះ ហើយជាសារមួយដែលនឹងជូនចំពោះអនាគតឧក្រិដ្ឋជនទាំងឡាយថាអ្នកទាំងនោះត្រូវតែសងវិញចំពោះអ្វីដែលខ្លួនបានយកពីជនរងគ្រោះ» ។

**បណ្ឌិត រស់ សុវាចា សហរដ្ឋអាមេរិក**

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់
# នៅក្នុងរបបខ្មែរក្រហម

មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាងមួយលាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ អេង កុកថាយ ទូរស័ព្ទលេខ ០១២ ៩៥៥ ៨៥៨ ឬ អ៊ីម៉ែល ៖ truthkokthay@dccam.org ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។

***សូមផ្តល់ព័ត៌មានដូចខាងក្រោម៖***

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍៖ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍៖ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍៖ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍៖ លេខទូរស័ព្ទ អាសយដ្ឋាន) ។

***ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោម៖***

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍៖ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។

edm,lyut|Fm'nig karcgcaM

Ed l CamU daend¾s Man;kg karpSHpSaCat










ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវេ ស៊ុីតដែន និងសហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម/៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 128, August 2010 ◆ Funded by Denmark, Norway, Sweden, and USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.